# អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា

## អង្គបុរេជំនុំជម្រះ

សំណុំរឿងព្រហ្មទណ្ឌ

លេខ: ០០២/១៩-០៩-២០០៧-អវតក-កសចស(អបជ៣២) អៀង សារី

**ថ្ងៃទី១១ ខែកុម្ភៈ ឆ្នាំ២០១០**

**ម៉ោង ០៨: ៥៨ នាទី**

**សវនាការលើបណ្តឹងឧទ្ធរណ៍**

**ចៅក្រមជំនុំជម្រះ៖**

លោក ប្រាក់ គឹមសាន ប្រធានអង្គបុរេ

លោក រ៉ូវ៉ាន់ ដោននីង

លោក ន័យ ថុល

លោកស្រី ខាទីនខា ឡាហ៊ូស

លោក ហួត វុទ្ធី

លោក ប៉ែន ពេជ្រសាលី (បម្រុង)

**ក្រឡាបញ្ជី៖**

លោក ឈន ព្រលឹង

លោកស្រី អង់តេឡា ហ្សស៊ីហ្វី

កញ្ញា សរ ចន្ទរ៉ាត

**ការិយាល័យសហព្រះរាជអាជ្ញា៖**

លោក ច័ន្ទ តារាវស្មី

លោក អានីស អះមេដ

**មេធាវីការពារជនត្រូវចោទឈ្មោះ អៀង សារី៖**

លោក អាង ឧត្តម

លោក ម៉ៃខល កាណាវាស

**មេធាវីដើមបណ្តឹងរដ្ឋប្បវេណី៖**

លោក ហុង គឹមសួន

លោក ឡោ ជុនធី

លោក នី ចាន់ឌី

លោក ដេវីដ ប្លេកមេន

លោក គីម ម៉េងឃី

លោក ពេជ អង្គ

លោកស្រី ជេត វណ្ណលី

លោកស្រី ស៊ីន សុវ៉ន

## បញ្ជីឈ្មោះ អ្នកនិយាយ៖

ភាសា ដែលប្រើប្រាស់ លើកលែងតែបានកំណត់ដាក់លាក់នៅក្នុងប្រតិចារឹក

| **អ្នកនិយាយ** | **ភាសា** |
|---|---|
| លោក អានីស អះមេដ | អង់គ្លេស |
| លោក អាង ឧត្តម | ខ្មែរ |
| លោក ដេវីដ ប្លេកមេន | អង់គ្លេស |
| លោក ឈន ព្រលឹង | ខ្មែរ |
| លោក ច័ន្ទ តាវរស្មី | ខ្មែរ |
| ចៅក្រម រ៉ូវ៉ាន់ ដោននីង | អង់គ្លេស |
| លោក នី ចាន់ឌី | ខ្មែរ |
| ចៅក្រម ខាទីនខា ឡាហ្វ៊ូស | អង់គ្លេស |
| លោក ម៉ៃខល កាណាវាស | បារាំង |
| ចៅក្រម ន័យ ថុល | ខ្មែរ |
| ជនត្រូវចោទ | ខ្មែរ |
| ចៅក្រម ប្រាក់ គឹមសាន (ប្រធានអង្គបុរេ) | ខ្មែរ |

# កិច្ចដំណើរការនីតិវិធី

[០៨:៥៤:៤៧]

**លោក ឈន ព្រលឹង៖**

បទបញ្ជាផ្ទៃក្នុងសវនាការ៖

ដើម្បីរក្សាឲ្យបាននូវរបៀបរៀបរយសាធារណៈ សន្តិសុខ និងដំណើរការល្អក្នុងពេលសវនាការ នៅថ្ងៃទី១១ ខែកុម្ភៈ ឆ្នាំ២០១០ ប្រធានអង្គបុរេជំនុំជម្រះបានដាក់ចេញបទបញ្ជាដូចខាងក្រោម៖

១) អ្នកដែលមានបំណងចូលរួមក្នុងសវនាការទាំងអស់ត្រូវមានវត្តមានក្នុងបរិវេណអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាឲ្យបានមុនប្រាំបួនព្រឹក។

២) មិនអនុញ្ញាតឲ្យយកម៉ាស៊ីនថតរូប ម៉ាស៊ីនថតវីដេអូ ឧបករណ៍ថតសំឡេង និងឧបករណ៍បំពងសំឡេងគ្រប់ប្រភេទពីខាងក្រៅចូលក្នុងសវនាការឡើយ លើកលែងតែមានការអនុញ្ញាតដោយអង្គជំនុំជម្រះ។

៣) មិនអនុញ្ញាតឲ្យជក់បារី ឬយកចំណីអាហារនិងភេសជ្ជៈគ្រប់ប្រភេទចូលក្នុងសាលសវនាការ

៤) មិនអនុញ្ញាតឲ្យយកអាវុធគ្រប់ប្រភេទចូលក្នុងសាលសវនាការ។

៥) មិនអនុញ្ញាតឲ្យប្រើប្រាស់ទូរស័ព្ទគ្រប់ប្រភេទ និងហាមឃាត់នូវរាល់ការថតរូប ឬថតសំឡេងដោយទូរស័ព្ទក្នុងពេលសវនាការ។

៦) មិនអនុញ្ញាតឲ្យប្តូរទីកន្លែងអង្គុយ ឬដើររហេតរហូតក្នុងសាលសវនាការ។

៧) មិនអនុញ្ញាតឲ្យស្រែកឡូឡា ឬបង្កើតសំឡេងរំខានក្នុងសវនាការ។

៨) ការចេញចូលក្នុងសាលសវនាការត្រូវទាក់ទងសន្តិសុខ អ.វ.ត.ក។

៩) មិនអនុញ្ញាតឲ្យអ្នកដែលមានអាយុក្រោម១៨ឆ្នាំចូលក្នុងសាលសវនាការឡើយ។

ប្រធានអង្គបុរេជំនុំជម្រះអាចចាត់វិធានការភ្លាមប្រឆាំងនឹងអ្នកដែលប្រព្រឹត្តបទល្មើស និងបទបញ្ជានេះ ឬអ្នកដែលប្រព្រឹត្តបទល្មើសផ្សេងៗទៀតក្នុងពេលសវនាការតាមទង្វើ ឬបទល្មើសដែលបានប្រព្រឹត្តជាក់ស្តែង។

ភ្នំពេញថ្ងៃទី១១ ខែកុម្ភៈ ឆ្នាំ២០១០

ប្រធានអង្គបុរេជំនុំជម្រះ

ប្រាក់ គឹមសាន

សូមអរគុណ។

*(អ្នកកាសែតចូលថតរូប)*

*(ចៅក្រមចូលក្នុងបន្ទប់សវនាការ)*

**ប្រធានអង្គជំនុំ៖**

សូមអ្នកថតរូបអញ្ជើញចេញ!

តាមនាមប្រជារាស្ត្រខ្មែរ និងតាងនាមអង្គការសហប្រជាជាតិ ថ្ងៃនេះអង្គបុរេជំនុំជម្រះនៃអង្គ-ជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាប្រកាសបើកសវនាការដើម្បីជំនុំជម្រះរឿងព្រហ្មទណ្ឌលេខ០០២/១៩-៩-២០០៧ អវតក-កសចស (អបជ៣២)ចុះថ្ងៃទី១០ ខែវិច្ឆិកា ឆ្នាំ២០០៩ ដែលមានជនត្រូវចោទឈ្មោះ អៀង សារី ហៅ វ៉ាន់ ភេទប្រុស កើតនៅថ្ងៃទី២៤ ខែតុលា ឆ្នាំ១៩២៥ នៅភូមិលឿងវ៉ា ឃុំលឿងវ៉ា ស្រុកត្រាវិញ ខេត្តត្រាវិញ កម្ពុជាក្រោម សញ្ជាតិខ្មែរទីលំនៅមុនពេលចាប់ខ្លួន ផ្ទះលេខ ៤៧បេ ផ្លូវ២១ ក្រុម៣៦ មណ្ឌល៤ សង្កាត់ទន្លេបាសាក់ ខណ្ឌចំការមន ក្រុងភ្នំពេញ ប្រទេសកម្ពុជា។ ឪពុកឈ្មោះ គីម រៀម (ស្លាប់) ម្តាយឈ្មោះ ត្រាន់ ធិឡឺយ (ស្លាប់)។ ត្រូវបានចោទប្រកាន់ពីបទឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ និងរំលោភបំពានធ្ងន់ធ្ងរលើអនុសញ្ញាទីក្រុងហ្សឺណែវ ចុះថ្ងៃទី១២ ខែសីហា ឆ្នាំ១៩៤៩ បទល្មើសដែលមានចែងនិងផ្តន្ទាទោសតាមមាត្រា៥ មាត្រា៦ មាត្រា២៩(ថ្មី) និងមាត្រា៣៩(ថ្មី)នៃច្បាប់ស្តីពីការបង្កើតអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ចុះថ្ងៃទី២៧ ខែតុលា ឆ្នាំ២០០៤។

មេធាវីការពារក្តីលោក អាង ឧត្តម, លោក ម៉ៃខល កាណាវាស។

មេធាវីដើមបណ្តឹងរដ្ឋប្បវេណី៖ លោក ហុង គីមសួន, លោក ឡោ ជុនធី, លោក គង់ ពិសី, លោក យុង ផានិត, លោកស្រី ស៊ីន សុវ៉ន, លោកស្រី ជេត វណ្ណលី,លោក ពេជ អង្គ, កញ្ញា ស៊ីលឃិស្ទួតហ្សីនស្គី, លោក ម៉ាដេវ ម៉ូហេន, លោក ដេវីដ ប្លេកមេន, លោក គីម ម៉េងឃី, កញ្ញា ម៉ុច សុវណ្ណារី, លោកស្រី អ៊ីសាប៊ែល ឌុរេនដ៍, លោកស្រី អេលីហ្សាប៊ែត រ៉ាបេសាន់ជ្រាតាណា, លោក ហ្វីលីព កាណុន, លោកស្រី ម៉ាទីន ហ្សាឃ្វីន, លោកស្រី ហ្វាប៊ីយ៉ែន ទ្រូស្សណាព្រូស។

ក្រឡាបញ្ជី, អ្នកចូលរួមសវនាការមានវត្តមានគ្រប់ចំនួនហើយឬនៅ?

**លោក ឈន ព្រលឹង៖**

[០៩:០៥:១៨]

កញ្ញា ម៉ុច សុវណ្ណារី, លោកស្រី អ៊ីសាប៊ែល ដុរេនដ៍, លោកស្រី អេលីហ្សាប៊ែត រ៉ាបេសាន់

ជ្រាតាណា, លោក ហ្វីលីព កាណុន, លោកស្រី ម៉ាទីន ហ្សាឃ្វីន, លោកស្រី អានី ឌឹឡាហេ, លោកស្រី ហ្វាប៊ីយ៉ែន ទ្រូស្សូណាព្រូស។

សូមអរគុណ។

**ប្រធានអង្គបុរេ៖**

ខ្ញុំសូមប្រកាសសមាសភាពជាថ្មី។ ការជំនុំជម្រះថ្ងៃមានសមាសភាពដូចតទៅ៖

១) លោក ប្រាក់ គឹមសាន ប្រធាន, ២) លោក រ៉ូវ៉ាន់ ដោននីង ចៅក្រម, ៣) លោក ន័យ ថុល ចៅក្រម, ៤) លោកស្រី ខាទីនខា  ឡាហ្ស៊ូស ចៅក្រម, ៥) លោក ហួត វុទ្ធី ចៅក្រម, ៦) លោក ប៉ែន ពេជ្រសាលី ជាចៅក្រមបម្រុង។

ក្រឡាបញ្ជី៖ លោក ឈន ព្រលឹង និងលោកស្រី អង់តេឡា ហ្សូស៊ីហ្វី, កញ្ញា សរ ចន្ទរ៉ាត, កញ្ញា ហ្វៃហ្សា ហ្ស៊ូអាគ្រី។

តំណាងអយ្យការមាន៖ លោក ច័ន្ទតារារស្មី ជាសហព្រះរាជអាជ្ញារង, លោក អានីស អះមេដ ជាសហព្រះរាជអាជ្ញារង។

ជនត្រូវចោទ, លោក អៀង សារី មកឈរមុខក្រចកសេះ !

**ប្រធានអង្គបុរេ៖**

ជនត្រូវចោទ, លោកឈ្មោះអ្វី?

**ជនត្រូវចោទ៖**

អៀង សារី។ ខ្ញុំឈ្មោះ អៀង សារី។

**ប្រធានអង្គបុរេ៖**

មានឈ្មោះហៅក្រៅទេ?

**ប្រធានអង្គបុរេ៖**

អាយុប៉ុន្មាន?

**ជនត្រូវចោទ៖**

ស្តាប់មិនឮ។

**ប្រធានអង្គបុរេ៖**

អាយុប៉ុន្មាន?

**ជនត្រូវចោទ៖**

(មិនឮសំឡេង)

**ប្រធានអង្គបុរេ៖**

សញ្ជាតិអ្វី?

**ជនត្រូវចោទ៖**

(មិនឮសំឡេង)

**ប្រធានអង្គបុរេ៖**

កើតនៅភូមិណា? ឃុំណា?
ដោយមូលហេតុមិនបានបកប្រែក្នុងការសួររបស់ខ្ញុំ ខ្ញុំសូមឆ្លើយ--សូមសួរជាថ្មីម្តងទៀត។
លោកឈ្មោះអ្វី? មានឈ្មោះហៅក្រៅទេ? អាយុប៉ុន្មាន? កើតនៅភូមិណា?

**ជនត្រូវចោទ៖**

(មិនឮសំឡេង)

**ប្រធានអង្គបុរេ៖**

ឃុំណា?

**ជនត្រូវចោទ៖**

(មិនឮសំឡេង)

**ប្រធានអង្គបុរេ៖**

សង្កាត់ណា?

**ជនត្រូវចោទ៖**

(មិនឮសំឡេង)

**ប្រធានអង្គបុរេ៖**

ស្រុកណា?

**ជនត្រូវចោទ៖**

ត្រពាំង។

**ប្រធានអង្គបុរេ៖**

ខេត្តណា?

**ជនត្រូវចោទ៖**

(មិនឮសំឡេង)

**ប្រធានអង្គបុរេ៖**

ធ្វើអ្វី?

**ជនត្រូវចោទ៖**

(មិនឮសំឡេង)

**ប្រធានអង្គបុរេ៖**

មុខរបរធ្វើអ្វី?

**ជនត្រូវចោទ៖**

(មិនឮសំឡេង)

**ប្រធានអង្គបុរេ៖**

ទីលំនៅមុនពេលចាប់ខ្លួននៅឯណា?

**ជនត្រូវចោទ៖**

ជិតវត្តស្វាយពពែ។

**ប្រធានអង្គបុរេ៖**

ឪពុកឈ្មោះអ្វី?

**ជនត្រូវចោទ៖**

(មិនឮសំឡេង)

**ប្រធានអង្គបុរេ៖**

ម្តាយឈ្មោះអ្វី?

**ជនត្រូវចោទ៖**

ធិឡឺយ។

**ប្រធានអង្គបុរេ៖**

ប្រពន្ធឈ្មោះអ្វី?

**ជនត្រូវចោទ៖**

(មិនឮសំឡេង)

**ប្រធានអង្គបុរេ៖**

មានកូនប៉ុន្មាននាក់?

**ជនត្រូវចោទ៖**

(មិនឮសំឡេង)

**ប្រធានអង្គបុរេ៖**

មានពឹងអ្នកការពារឬទេ? ឬពឹងមេធាវីឬទេ?

**ជនត្រូវចោទ៖**

ប្រគល់សិទ្ធិឲ្យគាត់និយាយជំនួសខ្ញុំ។

**ប្រធានអង្គបុរេ៖**

តើលោកមានស្គាល់ឈ្មោះមេធាវីរបស់លោកទេ? ឈ្មោះអី?

**ជនត្រូវចោទ៖**

...និងលោក កាណាវាស។

**ប្រធានអង្គបុរេ៖**

ជនត្រូវចោទ, ខ្ញុំជម្រាបដល់សិទ្ធិរបស់លោកតាមវិធាន២១.១(ឃ) ដូចតទៅ៖

លោកមានសិទ្ធិ លោកត្រូវចាត់ទុកថាគ្មានទោសដរាបពិរុទ្ធភាពរបស់លោកមិនត្រូវបានរកឃើញ លោកមានសិទ្ធិទទួលដំណឹងអំពីបទល្មើសដែលចោទប្រកាន់ចំពោះខ្លួន។ លោកមានសិទ្ធិមានមេធាវីការពារតាមការជ្រើសរើសរបស់លោក និងលោកមានសិទ្ធិនៅស្ងៀមមិនឆ្លើយតប។

សូមអញ្ជើញសហចៅក្រមរបាយការណ៍ អានរបាយការណ៍។

[០៩:១៤:០៦]

**ចៅក្រម ន័យ ថុល៖**

លោកអរគុណលោកប្រធាន។ ខ្ញុំសូមអានរបាយការណ៍ដែលមានខ្លឹមសារដូចតទៅ៖

អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា អង្គបុរេជំនុំជម្រះ សំណុំរឿងព្រហ្មទណ្ឌលេខ០០២/១៩-០៩-២០០៧ អវតក-កសចស(អបជ៣២)។ របាយការណ៍ស្តីពីការត្រួតពិនិត្យសំណុំរឿង។ របាយ-ការណ៍នេះមានចែកជាពីរផ្នែកធំ។ ផ្នែកធំទីមួយ អំពីនីតិវិធី។ ផ្នែកធំទីពីរ ការពិនិត្យសំណុំរឿងរបស់សហចៅក្រមរបាយការណ៍។

I.អំពីនីតិវិធី

ក) សេចក្តីផ្តើម

អនុលោមតាមវិធាន៧៧.១០ នៃវិធានផ្ទៃក្នុងរបស់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ប្រធានអង្គបុរេជំនុំជម្រះបានចាត់តាំងចៅក្រម ន័យ ថុល និងចៅក្រម ខាទីនខា ឡាហ៊ូស ឲ្យធ្វើរបាយ-ការណ៍លម្អិត ពីអង្គហេតុនិងអង្គច្បាប់ ទាក់ទងនឹងដីកាសម្រេចអំពីការបន្តចិរវេលានៃការឃុំខ្លួនបណ្តោះអាសន្ន ចេញដោយសហចៅក្រមស៊ើបអង្កេត ចុះនៅថ្ងៃទី១០ ខែវិច្ឆិកា ឆ្នាំ២០០៩ ដែលដីកាសម្រេចនេះ ត្រូវបានប្តឹងឧទ្ធរណ៍ និងបង្ហាញអង្គហេតុដែលពាក់ព័ន្ធនឹងសំណុំរឿងលេខ០០២/១៩-០៩-២០០៧ អវតក-កសចស (អបជ៣២) អំពីអត្តសញ្ញាណសម្គាល់ជនត្រូវចោទ។ ជនត្រូវចោទឈ្មោះ អៀង សារី ហៅ វ៉ាន់ កេទ ប្រុស កើតនៅថ្ងៃទី២៤ ខែតុលា ឆ្នាំ១៩២៤ នៅភូមិ លឿងវ៉ា ឃុំលឿងវ៉ា ស្រុកត្រាវិញ ខេត្តត្រាវិញ កម្ពុជាក្រោម សញ្ជាតិខ្មែរ ទីលំនៅមុនពេលចាប់ខ្លួន នៅផ្ទះលេខ៤៧បេ ផ្លូវលេខ២១ ក្រុម៣៦ មណ្ឌល៤ សង្កាត់ទន្លេបាសាក់ ខណ្ឌចំការមន ក្រុងភ្នំពេញ ប្រទេសកម្ពុជា។ ឪពុកឈ្មោះ គឹម រៀម (ស្លាប់) ម្តាយឈ្មោះ ត្រាន់ ធិឡឺយ (ស្លាប់)។

លោក អៀង សារី មានសហមេធាវីការពារក្តីគឺលោក អាង ឧត្តម និង លោក ម៉ៃខល កាណាវាស។

**អំពីបទចោទ៖**

អៀង សារី ត្រូវបានចោទប្រកាន់ពីបទឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ និងរំលោភបំពានធ្ងន់ធ្ងរលើអនុសញ្ញាទីក្រុងហ្សឺណែវ ចុះនៅថ្ងៃទី១២ ខែសីហា ឆ្នាំ១៩៤៩ ដែលជាបទល្មើសដែលមានចែង និងផ្តន្ទាទោស តាមមាត្រាទី ៥ មាត្រាទី៦ មាត្រាទី៩ (ថ្មី) និងមាត្រាទី៣៩ (ថ្មី) នៃច្បាប់ស្តីពីការបង្កើតអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ចុះនៅថ្ងៃទី២៧ ខែតុលា ឆ្នាំ២០០៤។ គោលបំណងនៃរបាយ-

ការណ៍នេះ របាយការណ៍របស់សហចៅក្រម របាយការណ៍នេះបង្ហាញលម្អិតពីអង្គហេតុ និងអង្គច្បាប់ទាក់ទងនឹងសេចក្ដីសម្រេច ដែលត្រូវបានប្ដឹងឧទ្ធរណ៍ និងអង្គហេតុដែលពាក់ព័ន្ធផ្សេងៗទៀតនៅក្នុងចំពោះមុខតុលាការ។ របាយការណ៍នេះផ្ដល់ជាជំនួយដល់អ្នកដែលមិនមែនជាភាគីនៃនីតិវិធីឲ្យបានយល់ដឹងអំពីរឿងក្ដីនេះនៅចំពោះមុខតុលាការ។

ចំណុច ខ ដីកាសម្រេចអំពីការបន្តថិរវេលានៃការឃុំខ្លួនបណ្ដោះអាសន្ន របស់សហចៅក្រមស៊ើបអង្កេត។ នៅថ្ងៃទី១០ ខែវិច្ឆិកា ឆ្នាំ២០០៨ សហចៅក្រមស៊ើបអង្កេតរបស់ អ.វ.ត.ក បានចេញដីកាសម្រេចអំពីការបន្តថិរវេលា នៃការឃុំខ្លួនបណ្ដោះអាសន្នលើជនត្រូវចោទ ដែលត្រូវបានឃុំខ្លួនចាប់តាំងពីថ្ងៃទី១៤ ខែវិច្ឆិកា ឆ្នាំ២០០៧ ក្នុងរយៈពេលអតិបរមាចំនួនមួយឆ្នាំ។

[០៩:១៨:៣៣]

សហចៅក្រមស៊ើបអង្កេតបានរកឃើញថា លក្ខខណ្ឌទី១ ដែលមានចែងនៅក្នុងវិធាន៦៣.៣(ក) នៃវិធានផ្ទៃក្នុងនេះ ដើម្បីចេញដីកាសម្រេចឲ្យឃុំខ្លួនបណ្ដោះអាសន្ន ត្រូវបានបំពេញទោះបីជាមានការកន្លងផុតទៅនៃពេលវេលាក្ដី ដោយសារនៅដំណាក់កាលនៃកិច្ចស៊ើបសួរចុងក្រោយនេះ មានការលេចឡើងនូវអង្គហេតុ និងព័ត៌មានបន្ថែមនានាដែលអាចនាំឲ្យអ្នកសង្កេតការណ៍អព្យាក្រឹត្យអាចជឿជាក់ច្បាស់ថានៅក្នុងមុខងារ និងតួនាទីមួយ ឬច្រើនរបស់គាត់ដូចបានបង្ហាញក្នុងដីកាសម្រេចអំពីការបន្តថិរវេលាឃុំខ្លួនជនត្រូវចោទ អៀង សារី រៀបចំផែនការញុះញង់បញ្ជា មិនបានព្យាយាមទប់ស្កាប់ ឬជួយនិងជំរុញឲ្យមានការប្រព្រឹត្តិបទឧក្រិដ្ឋ ដូចមានលើកឡើងនៅក្នុងដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរ។

សហចៅក្រមស៊ើបអង្កេតបានរកឃើញថា ចាប់តាំងពីអង្គបុរេជំនុំជម្រះបានសម្រេចថាការឃុំខ្លួនបណ្ដោះអសន្ន គឺជាវិធានចាំបាច់ដើម្បីធានានអំពីវត្តមានរបស់ជនត្រូវចោទក្នុងអំឡុងពេលនៃណើរការនីតិវិធី ការពារសន្តិសុខឲ្យជនត្រូវចោទ និងរក្សាសណ្ដាប់ធ្នាប់សាធារណៈមកវាមិនមានការប្រែប្រួលនៃកាលៈទេសៈដែលអាចនាំឲ្យមានសេចក្ដីសន្និដ្ឋានខុសផ្សេងពីនេះទេ។

សហចៅក្រមស៊ើបអង្កេតបានយល់ឃើញទៀតថា មូលហេតុទាំងបីដែលបានចែងនៅក្នុងវិធានផ្ទៃក្នុង៦៣.៣(ខ) នៅតែត្រូវបានបំពេញដដែល។ សហចៅក្រមស៊ើបអង្កេតបានបញ្ជាក់ថែមថា ការកន្លងផុតទៅនៃពេលវេលា គឺជាកត្តាកំណត់អំពីនីត្យានុកូលភាព នៃការបន្តការឃុំខ្លួនជនត្រូវចោទ ដោយបានធ្វើការពិនិត្យ និងវាយតម្លៃលើវិធីសាស្ត្រនៃការបំពេញកិច្ចស៊ើបសួរដែលបានអនុវត្តកន្លងមក និងដោយបានធ្វើការប្រៀបធៀបជាមួយនឹងយុត្តិសាស្ត្រនៃតុលាការសិទ្ធិមនុស្សអឺរ៉ុប។ ទាក់ទងថិរវេលាសមរម្យ

នេះ សហចៅក្រមស៊ើបអង្កេតបានពិនិត្យ និងពិចារណាគ្រប់ជ្រុងជ្រោយលើអង្គហេតុនៃសំណុំរឿងទាំងមូល ដោយរួមបញ្ចូលទាំងភាពស្មុគស្មាញ ទាំងផ្នែកអង្គហេតុ និងអង្គច្បាប់ និងបែបបទបំពេញការងាររបស់តុលាការនិងភាគី។

ចៅក្រមស៊ើបអង្កេតយល់ឃើញថែមទៀតថា ការឃុំខ្លួនអស់រយៈជិត២៤ខែមកហើយ វាពិតជាថិរវេលាដ៏យូរមួយ តែទោះបីជាយ៉ាងនេះក្តីវិសាលភាពនៃកិច្ចស៊ើបសួរ ព្រមទាំងភាពធ្ងន់ធ្ងរនៃបទឧក្រិដ្ឋកម្មដែលចោទប្រកាន់ចំពោះជនត្រូវចោទ គឺវាតម្រូវឲ្យមានការរៀបចំនូវកិច្ចស៊ើបសួរដែលមានទំហំធំដែលមានរួមបញ្ចូលក្នុងការស្តាប់ចម្លើយសាក្សីដោយផ្ទាល់ ការរៀបចំកំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី និងភាគីដើមបណ្តឹងរដ្ឋប្បវេណីដើម្បីស្វែងរកភ័ស្តុតាងបញ្ជាក់អំពីតួនាទីរបស់ជនត្រូវចោទក្នុងអំឡុងពេលរបបកម្ពុជាប្រជាធិបតេយ្យ។ ដូច្នេះ លក្ខខណ្ឌនៃការដាក់ជនត្រូវចោទឲ្យឋិតនៅក្នុងការឃុំខ្លួនបណ្តោះអាសន្ន ដែលមានចែងក្នុងវិធាន៦៣.៣ នៃវិធានផ្ទៃក្នុងត្រូវតែបានបំពេញនៅឡើយ។

[០៩:២២:១១]

ចំណុច គ បណ្តឹងឧទ្ធរណ៍របស់ អៀង សារី នៅថ្ងៃទី០៧ ខែធ្នូ ឆ្នាំ២០០៩ សហមេធាវីការពារក្តីរបស់ជនត្រូវចោទ បានដាក់បណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាសម្រេចរបស់សហចៅក្រមស៊ើបអង្កេតបន្តថិរវេលាការឃុំខ្លួនបណ្តោះអាសន្ន ដែលបានស្នើឲ្យអង្គបុរេជំនុំជម្រះបដិសេធដីកាសម្រេចអំពីបន្តថិរវេលានៃការឃុំខ្លួនបណ្តោះអាសន្ន និងបញ្ចប់ការឃុំខ្លួនលោក អៀង សារី បណ្តោះអាសន្ននេះ។

សហមេធាវីការការពារក្តីប្តឹងឧទ្ធរណ៍ដោយផ្អែកលើមូលដ្ឋានថា សហចៅក្រមស៊ើបអង្កេតមានកំហុសក្នុងការសម្រេចថិរវេលានៃការឃុំខ្លួនបណ្តោះអាសន្នចំពោះលោក អៀង សារី និងបានរំលោភបំពាន លើឆន្ទានុសិទ្ធិរបស់ខ្លួនក្នុងការខកខានមិនបានពិចារណាលើវិធានការនានា ក្រៅពីការការឃុំខ្លួនបណ្តោះអាសន្នមុននឹងចេញដីកាសម្រេចបន្តថិរវេលាឃុំខ្លួនបណ្តោះអាសន្នចំពោះ អៀង សារី និងបានរំលោភសិទ្ធិរបស់គាត់ក្នុងការទទួលបាននូវសេរីភាពនិងសច្ចធារណ៍នៃនិរទោស ដោយហេតុថាលក្ខខណ្ឌដែលតម្រូវឲ្យមានការឃុំខ្លួនគាត់ ដូចចែងក្នុងវិធាន៦៣.៣ នៃវិធានផ្ទៃក្នុងមិនត្រូវបានបំពេញឡើយ។

ចំណុច ឃ ចម្លើយតបរបស់មេធាវីដើមបណ្តឹងរដ្ឋប្បវេណី និងបណ្តឹងឧទ្ធរណ៍។

នៅថ្ងៃទី១៦ ខែធ្នូ ឆ្នាំ២០០៩ សហមេធាវីដើមបណ្តឹងរដ្ឋប្បវេណីបានដាក់ចម្លើយតបទៅនឹងបណ្តឹងឧទ្ធរណ៍របស់ អៀង សារី ដែលក្នុងចម្លើយតបនោះសហមេធាវីដើមបណ្តឹងរដ្ឋប្បវេណីស្នើសុំឲ្យអង្គបុរេជំនុំជម្រះបដិសេធចោលបណ្តឹងឧទ្ធរណ៍ ដោយសារតែដីកាសម្រេចអំពីការបន្តថិរវេលានៃ

ការឃុំខ្លួនបណ្តោះអាសន្នរបស់សហចៅក្រមស៊ើបអង្កេត មានហេតុផលសមរម្យនិងត្រឹមត្រូវ ហើយសហចៅក្រមស៊ើបអង្កេតឆន្ទានុសិទ្ធិរបស់ខ្លួនបានត្រឹមត្រូវ។

ចំណុច ង ចម្លើយតបរបស់សហព្រះរាជអាជ្ញាទៅនឹងបណ្តឹងឧទ្ធរណ៍។

នៅថ្ងៃទី១៧ ខែធ្នូ ឆ្នាំ២០០៩ សហព្រះរាជអាជ្ញាបានដាក់ចម្លើយរបស់ខ្លួនដោយស្នើសុំឲ្យអង្គបុរេជំនុំជម្រះឲ្យធ្វើការបដិសេធនូវបណ្តឹងឧទ្ធរណ៍នេះ ដោយផ្អែកលើមូលហេតុមួយចំនួនក្នុងចំណោមទឡ្ហីករណ៍ផ្សេងៗទៀតថា ដើមបណ្តឹងឧទ្ធរណ៍ខកខានមិនបានបង្ហាញឲ្យឃើញអំពីការផ្លាស់ប្តូរកាលៈទេសៈជាក់ស្តែងណាមួយចាប់តាំងពីរូបគាត់ត្រូវបានសហចៅក្រមស៊ើបអង្កេត សម្រេចឃុំខ្លួនដំបូងនៅថ្ងៃទី១៤ ខែវិច្ឆិកា ឆ្នាំ២០០៧ មក ជាពិសេសទៅទៀត គាត់មិនបានអំពីការផ្លាស់ប្តូរកាលៈទេសៈជាក់ស្តែងណាមួយ ចាប់តាំងពីមានការបញ្ជាក់អះអាងអំពីការឃុំខ្លួនបណ្តោះអាសន្នលើរូបគាត់ ដោយអង្គបុរេជំនុំជម្រះនៅថ្ងៃទី១៧ ខែតុលា ឆ្នាំ២០០៨ ចាប់តាំងពីការបន្តចិរវេលា នៃការឃុំខ្លួនបណ្តោះអាសន្នលើកទី១ ចុះនៅថ្ងៃទី១១ ខែធ្នូ ឆ្នាំ២០០៨ ឬក៏ការតម្កល់ដីកាសម្រេចនោះ ដោយអង្គបុរេជំនុំជម្រះចុះនៅថ្ងៃទី២៦ ខែមិថុនា ឆ្នាំ២០០៩។

[០៩:២៦:០៩]

II. ការពិនិត្យសំណុំរឿងដោយសហចៅក្រមរបាយការណ៍

ចំណុច ក៖ សេចក្តីសម្រេចបន្តឃុំបណ្តោះអាសន្ន តាមវិធាន៦៣.៣ (ក)នៃវិធានផ្ទៃក្នុង គឺត្រឹមត្រូវដោយសារមានហេតុផលដែលនាំឲ្យជឿជាក់យ៉ាងច្បាស់ថា ជនត្រូវចោទធ្លាប់បានប្រព្រឹត្តល្មើសមួយ ឬច្រើនដូចមានចែងក្នុងដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរ។ សហមេធាវីការពារក្តីរបស់ជនត្រូវចោទបានលើកឡើងថា កិច្ចស៊ើបអង្កេតបានអនុវត្តដោយមិនយកចិត្តទុកដាក់ និងមានកំហុស មូលហេតុដោយសារតែមានកំហុសនៅក្នុងកិច្ចស៊ើបអង្កេតរបស់ ក.ស.ច.ស គឺថា មិនមានភស្តុតាងដោះបន្ទុកគ្រប់គ្រាន់នៅក្នុងសំណុំរឿងនោះ គឺអាចបណ្តាលមកពីបញ្ហាមួយចំនួននៅក្នុងកិច្ចស៊ើបអង្កេត ដែលរួមមាន៖

១) ភាពលម្អៀងរបស់សហចៅក្រមស៊ើបអង្កេត ២) ភាពលម្អៀងដែលអាចមានក្នុងចំណោមបុគ្គលិក ក.ស.ច.ស ៣) ការជ្រៀតជ្រែកកិច្ចការរដ្ឋបាលរបស់តុលាការ ៤) កង្វះខាតដែលអាចមានក្នុងផែនការនៃកិច្ចស៊ើបសួរនិងនីតិវិធីក្នុងការស្វែងរកភស្តុតាងដោះបន្ទុក និង៥) ការប្រើប្រាស់ភស្តុតាងដែលពាក់ព័ន្ធទៅនឹងអំពើទារុណកម្មរបស់ ក.ស.ច.ស។ បញ្ហាខាងលើទាំងនេះពាក់ព័ន្ធទៅនឹងកិច្ចស៊ើប

សួរមិនត្រូវអនុញ្ញាតឲ្យមានឡើយ ដើម្បីចៀសវាងការធ្វើឲ្យប៉ះពាល់ដល់សិទ្ធិទទួលបានសេរីភាពជាសារវន្តរបស់លោក អៀង សារី ឬសិទ្ធិទទួលបាននូវសច្ចធារណ៍នៃនិរទោសរបស់គាត់។

នៅក្នុងសេចក្តីសន្និដ្ឋានតបវិញរបស់សហព្រះរាជអាជ្ញានិងភាគីដើមបណ្តឹងរដ្ឋប្បវេណី បានលើកឡើងថា ដើមបណ្តឹងឧទ្ធរណ៍បានលើកឡើងថា កំហុសនៅក្នុងការស៊ើបសួររបស់ ក.ស.ច.ស មានដូចជា ការមិនអាចមានលទ្ធភាពក្នុងការកំណត់ពីក្នុងសំណុំរឿង ថាតើមូលហេតុដែលធ្វើឲ្យជឿជាក់យ៉ាងច្បាស់មានអាទិភាពដែរឬទេ? ដើមបណ្តឹងឧទ្ធរណ៍គាំទ្រដល់ការតវ៉ានេះ ដោយយោងទៅលើញត្តិស្នើសុំនានា ដែលគាត់បានដាក់នៅចំពោះមុខអង្គបុរេជំនុំជម្រះប្រឆាំងនឹង ក.ស.ច.ស។ ដើមបណ្តឹងឧទ្ធរណ៍មិនបានបង្ហាញឲ្យឃើញថា តើសារណានានារបស់ខ្លួនស្តីពីប្រតិបត្តិការការងាររបស់ ក.ស.ច.ស និងលទ្ធផលដែលមិនបានទទួលជោគជ័យរបស់ខ្លួនមកទល់នឹងពេលនេះ អាចមានភាពគ្រប់គ្រាន់សម្រាប់បង្ហាញអំពីកំហុសណាមួយនោះទេ។ ដើមបណ្តឹងឧទ្ធរណ៍ ក៏មិនបានបង្ហាញឲ្យឃើញទៀតថា តើការចោទប្រកាន់អំពីការមានកំហុសនៅក្នុងការស៊ើបសួរបែបនេះ មុខជារារាំងដល់ការវាយតម្លៃអំពីភាពចាំបាច់នៃការឃុំខ្លួនរបៀបណានោះដែរ។

[០៩:២៩:៣០]

នៅក្នុងករណីណាក៏ដោយ សហព្រះរាជអាជ្ញាសន្និដ្ឋានថា ភាពខ្វះខាតនៃការយកចិត្តទុកដាក់ពីសំណាក់សហចៅក្រមស៊ើបអង្កេត គឺគ្មានពាក់ព័ន្ធគ្នាជាមួយនឹងការសម្រេចលើការដោះលែងបណ្តោះអាសន្ន អនុលោមតាមវិធាន៦៣.៣(ខ) នៃវិធានផ្ទៃក្នុងនោះទេ។ សហព្រះរាជអាជ្ញាបានសន្និដ្ឋានថែមទៀតថា សនិទានភាពដែលបានលើកឡើងនូវសាលដីកាលើបណ្តឹងឧទ្ធរណ៍ ប្រឆាំងនឹងការបន្តថិរវេលានៃការខ្លួនលើកទីមួយ គឺកំពុងនៅមានសុពលភាពនៅឡើយ ហើយគួរតែត្រូវបានតម្កល់ទុកជាបានការដើម្បីការពារនូវស្មារតីនៃវិធាន៦៣.៣(ខ)។

ចំណុច ខ ៖ អំពីភារកិច្ចរកភស្តុតាង

សហមេធាវីការពារក្តីរបស់ជនត្រូវចោទ បានលើកឡើងថា សហចៅក្រមស៊ើបអង្កេតមានភារកិច្ចរកភស្តុតាង ដើម្បីបង្ហាញថា លក្ខខណ្ឌនៃវិធាន៦៣.៣(ខ)ត្រូវបានបំពេញ និងថាអ.វ.ត.ក មានយុត្តាធិការដែលខុសប្លែកពីតុលាការព្រហ្មទណ្ឌអន្តរជាតិ តុលាការព្រហ្មទណ្ឌអន្តរជាតិសម្រាប់អតីតយូហ្គោស្លាវី ឬតុលាការព្រហ្មទណ្ឌអន្តរជាតិ សម្រាប់ប្រទេសរវ៉ាន់ដា អាចចេញដីកាចាប់ខ្លួននៅពេលណាក៏បាន បើយោងទៅលើស្ថានភាពរបស់ជនត្រូវចោទ។ ផ្ទុយទៅវិញ សហព្រះរាជអាជ្ញាសន្និដ្ឋានថា

ដើមបណ្តឹងឧទ្ធរណ៍មិនបានបង្ហាញអត្ថសញ្ញាណអំពី មានការផ្លាស់ប្តូរកាលៈទេសៈជាក់ស្តែង ដែលចាំបាច់តម្រូវឲ្យធ្វើការពិចារណាឡើងវិញ ទៅលើការឃុំខ្លួននោះឡើយ ឬសូម្បីតែមានការផ្លាស់ប្តូរណាមួយនៅក្នុងលក្ខខណ្ឌនៃការឃុំខ្លួននោះក្តី ក៏មិនបានបង្ហាញអត្ថសញ្ញាណដែរ។

ចំណុច គៈ លក្ខខណ្ឌនៃការឃុំខ្លួន

១)ការឃុំខ្លួនបណ្តោះអាសន្នស្ថិតនៅជាវិធានការចាំបាច់មួយ សម្រាប់ធានាឲ្យប្រាកដអំពីវត្តមានរបស់វត្តមានរបស់ដើមបណ្តឹងឧទ្ធរណ៍នៅក្នុងពេលសវនាការ ដោយយោងតាមវិធានផ្ទៃក្នុង៦៣.៣(ខ)(៣) សហមេធាវីមេធាវីការពារក្តីរបស់ជនត្រូវចោទបានលើកឡើងថា ស្ថានភាពនៅក្នុងពេលនេះរបស់ជនត្រូវចោទគឺវាខុសពីមុន ពីព្រោះគាត់មានអាយុ៨៤ឆ្នាំហើយ និងមានសុខភាពមិនល្អទៀតផង។ បញ្ហាសុខភាពធ្ងន់ធ្ងររបស់គាត់ ធ្វើឲ្យគាត់ពិបាកធ្វើចលនាណាស់ កុំថាឡើងដល់ការរត់គេចខ្លួន សូម្បីតែដើរក៏គាត់ស្ទើរតែដើរមិនរួចផង។ ម្យ៉ាងវិញទៀត គាត់ជាឥស្សរជនដ៏ល្បីឈ្មោះមួយរូប និងទំនងជាមិនអាចរត់គេចខ្លួនចេញពីយុត្តាធិការ ដោយមិនអាចដឹងជាមុនបានទេ។ លើសពីនេះទៀត អ.វ.ត.ក មាននគរបាលយុត្តិធម៌ និងមានអំណាចចេញដីកាចាប់ខ្លួន ដែលខុសប្លែកពីតុលាការព្រហ្មទណ្ឌអន្តរជាតិ។ តុលាការព្រហ្មទណ្ឌអន្តរជាតិសម្រាប់អតីតយូហ្គោស្លាវី ឬតុលាការព្រហ្មទណ្ឌអន្តរជាតិសម្រាប់ប្រទេសរវ៉ាន់ដា។

[០៩:៣៣:០០]

សហព្រះរាជអាជ្ញា និងដើមបណ្តឹងរដ្ឋប្បវេណីនានា បានឆ្លើយតបថា វ័យដ៏ចំណាស់របស់ដើមបណ្តឹងឧទ្ធរណ៍ ហើយតាមស្មាន គឺអំពីសេចក្តីកង្វល់ពីបញ្ហាសុខភាព ដែលអមជាមួយនឹងវ័យជរាផងនោះ ត្រូវបានពិចារណា និងត្រូវបានកំណត់រួចហើយ និងត្រូវបានចាត់ទុកដោយអង្គបុរេជំនុំជម្រះថាជាកាលៈទេសៈមួយនៃស្ថានទម្ងន់ទោស គឺមិនមែនជាស្ថានសម្រាលនោះទេ។ នៅពេលពិចារណាអំពីហានិភ័យនៃការរត់គេចខ្លួនជាងនេះទៅទៀត ការជជែកតវ៉ាដែលថា ដើមបណ្តឹងឧទ្ធរណ៍គឺជាឥស្សរជនដ៏ល្បីឈ្មោះមួយក៏អាចចាត់ទុកថាជាស្ថានទម្ងន់ដែរ គឺមិនមែនចាត់ទុកជាស្ថានសម្រាលនោះទេ ពីព្រោះដោយសារគាត់មិនទំនងជាមនុស្សដែលគ្មានទំនាក់ទំនងសោះ ដើម្បីឲ្យជួយគាត់ក្នុងការរត់គេចខ្លួននោះទេ។ ស្រដៀងគ្នានេះដែរ ភាពផ្ទុយគ្នារវាង អ.វ.ត.ក ហើយនិងតុលាការព្រហ្មទណ្ឌអន្តរជាតិនានា ទាក់ទងទៅនឹងការមានស្រាប់នូវនគរបាលយុត្តិធម៌ និងដីកាបង្គាប់ឲ្យនាំខ្លួននានា គឺអ.វ.ត.ក មិនអាចជួយធ្វើអ្វីបាននោះទេ ពីព្រោះអ.វ.ត.ក គឺជាតុលាការខុសពីគេ មានតែមួយគត់នៅក្នុងប្រទេសកម្ពុជា ដែលទទួលខុសត្រូវក្នុងកាត់ទោសចំពោះបទល្មើស ចំពោះបទឧក្រិដ្ឋកម្មអន្តរជាតិធ្ងន់ធ្ងរនានាដែលមានទំហំ

មិនធ្លាប់មានពីមុនមក ត្រូវដោះស្រាយអំពីការរត់គេចខ្លួនដែលមានស្ថានទម្ងន់ផ្សាភ្ជាប់ទៅនឹងភាពជិតដិតនៃទំនាក់ទំនងនានា និងភាពងាយស្រួលក្នុងការរត់គេចខ្លួន ដែលនៅតុលាការក្នុងក្រុមផ្សេងៗទៀតមិនមានដូច។

លើសពីនេះ បញ្ហាអំពីនគរបាលយុត្តិធម៌ និងដីកាបង្គាប់ឲ្យនាំខ្លួន ដែលដើមបណ្តឹងឧទ្ធរណ៍បានលើកឡើង គឺគ្រាន់តែទាក់ទងនឹងការរត់គេចខ្លួនរបស់គាត់ហើយប៉ុណ្ណោះ ហើយមិនអាចធ្វើអ្វីបាន ដើម្បីធានាអះអាងសាជាថ្មី ចំពោះតុលាការនេះ ថាការរត់គេចខ្លួនបែបនេះមិនអាចមានលទ្ធភាពធ្វើទៅរួចនោះឡើយ។

២) ការឃុំខ្លួនបណ្តោះអាសន្នជាវិធានចាំបាច់ ដើម្បីធានាសន្តិសុខរបស់លោក អៀង សារី

សហមេធាវីរបស់ជនត្រូវចោទ បានលើកឡើងអំពីការសន្និដ្ឋានពីមុនៗរបស់សហចៅក្រមស៊ើបអង្កេតថា ការឃុំខ្លួនលោក អៀង សារី ជាបណ្តោះអាសន្ន គឺជាវិធានការចាំបាច់ ដើម្បីការពារសុវត្ថិ-ភាពរបស់លោក។ ប៉ុន្តែ សហមេធាវីការពារក្តីរបស់ជនជាប់ចោទបានគូសបញ្ជាក់បន្ថែមថា ការសន្និដ្ឋានបែបនេះហាក់ដូចជាសំអាងទៅលើភាពតានតឹងនៅក្នុងសង្គមកម្ពុជា និងឈរលើមូលដ្ឋានអង្គហេតុថាមានហានិភ័យនៃការប្រើអំពើហិង្សាមកលើឌុច។ សហមេធាវីការពារក្តីរបស់ជនត្រូវចោទបានពន្យល់ថាគ្មានហេតុផលណាដែលនាំឲ្យមានការព្រួយបារម្ភចំពោះសុវត្ថិភាពរបស់លោក អៀង សារី ដោយសារតែហានិភ័យដែលមានចំពោះ ឌុច នោះទេ ប្រសិនបើមានការប្រើអំពីហិង្សាមកលើ ឌុច ក៏នេះដោយសារតែ ឌុច បានសារភាពចំពោះឧក្រិដ្ឋកម្មរបស់ខ្លួននៅក្នុងអំឡុងពេលសវនាការ ដែលត្រូវបានផ្សព្វផ្សាយយ៉ាងច្បាស់លាស់នោះដែរ។ លោក អៀង សារី មិនបានសារភាពចំពោះឧក្រិដ្ឋកម្មនោះទេ ហើយដោយសារការជំនុំជម្រះមកលើរូបគាត់មិនទាន់ចាប់ផ្តើម។ ហេតុដូច្នេះ ការគំរាមកំហែងមកលើ ឌុច មិនអាចយកមកប្រៀបធៀបជាមួយនឹងការគំរាមកំហែងមកលើ អៀង សារី នេះបានទេ។

សហមេធាវីការពារក្តីរបស់ជនត្រូវចោទបានលើកឡើងបន្ថែមទៀតថា សវនាការជំនុំជម្រះក្តីមកលើ ឌុច ឥឡូវនេះឈានដល់ទីបញ្ចប់ហើយ ហើយប្រសិនបើត្រូវតុលាការផ្តន្ទាទោសនោះ រំពឹងថាចំណុចនេះនឹងជួយសម្រាលអារម្មណ៍នៃការខឹងសម្បា ឬក៏សងសឹងដែលអាចមានក្នុងចំណោមសាធារណជនឲ្យមានការធូរស្រាលឡើងវិញ។ លទ្ធផលនៃការជំនុំជម្រះក្តីមកលើ ឌុច នឹងពិតជាជួយលើកសច្ចភាព និងជំនឿទុកចិត្តរបស់សាធារណជន មកលើប្រពន្ធ័យុត្តិធម៌ ហើយជាទូទៅនឹងជឿជាក់ចំពោះយុត្តិធម៌។ ចំណុចនេះអាចជួយបន្ធូរបន្ថយហានិភ័យនៃអំពើហិង្សាណាមួយ មកលើលោក អៀង សារី។

[០៩:៣៨:០០]

សហព្រះរាជអាជ្ញាបានឆ្លើយតបថា ការឃុំខ្លួនបណ្តោះអាសន្នតាមការកំណត់របស់អង្គបុរេជំនុំជម្រះកាលពីថ្ងៃទី២៦ ខែកក្កដា ឆ្នាំ២០០៩ នៅមន្ទីរឃុំឃាំង អ.វ.ត.ក គឺជាការចាំបាច់ទៅតាមវិធាន ៦៣.៣(ខ)(៤) នៃវិធានផ្ទៃក្នុងនេះ ដោយមានមូលដ្ឋាននៅលើការចោទប្រកាន់អំពីការជាប់ទាក់ទងគ្នារវាងជនត្រូវចោទឈ្មោះ កាំង ហ្គេកអ៊ាវ ហៅ ឌុច និងដើមបណ្តឹងឧទ្ធរណ៍ មានន័យថា ហានិភ័យនៃអាកប្បកិរិយារំលោភពីសំណាក់ពីសាធារណជន ដែលបញ្ចេញដាក់ចំពោះអ្នកមុន ក៏អាចត្រូវបានបង្ហាញ និងបញ្ចេញដាក់ចំពោះអ្នកក្រោយៗដែរ។ សហព្រះរាជអាជ្ញាបានគូសបញ្ជាក់ទៀតថា ការពន្យល់របស់សហមេធាវីការពារក្តីជនត្រូវចោទដែលថាគ្មានហេតុផលណា ដែលនាំឲ្យមានការព្រួយបារម្ភចំពោះសុវត្ថិភាពរបស់ អៀង សារី ដោយសារតែហានិភ័យដែលមានចំពោះ ឌុច នោះ មិនអាចទទួលយកបានទេ ពីព្រោះដើមបណ្តឹងឧទ្ធរណ៍ពុំមែនជាអ្នកត្រូវកំណត់យ៉ាងដូច្នេះ។ សហព្រះរាជអាជ្ញាបានពន្យល់ទៀតថាការលើកឡើងដោយដើមបណ្តឹងឧទ្ធរណ៍ ដែលថាវាអាចនឹងមានការផ្លាស់ប្តូរកាលៈទេសៈមួយជាមួយនឹងការកាត់ទោស ឌុច ការណ៍នេះបានផ្តល់ជាទ្រឹស្តីក្នុងការប្រែប្រួលអារម្មណ៍នៅក្នុងសង្គមកម្ពុជា ដែលជាការប៉ាន់ស្មានយ៉ាងសុទ្ធសាធ ហើយការកាត់ទោសដែលបានរំពឹងទុក នឹងអាចត្រូវបានគេចាត់ទុកជាការផ្លាស់ប្តូរកាលៈទេសៈមួយបានទេ ដោយហេតុថា វាមិនទាន់កើតមានឡើងនូវរឿងនេះ។

[០៩:៣៩:៥១]

មេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី បានកត់សម្គាល់ឃើញថា ករណីលោក កាំង ហ្គេកអ៊ាវ និងលោក អៀង សារី មិនដូចគ្នាទេ។ ប៉ុន្តែយ៉ាងណាក៏ដោយ រឿងក្តីទាំងពីរអាចយកមកធ្វើការប្រៀបធៀបគ្នាបាន ដោយសារជនទាំងពីរនេះត្រូវចោទប្រកាន់ពីបទឧក្រិដ្ឋធ្ងន់ធ្ងរស្រដៀងគ្នាទៅនៅក្រោមយុត្តាធិការ អ.វ.ត.ក។ លោក អៀង សារី ត្រូវបានចោទប្រកាន់ពីបទឧក្រិដ្ឋកម្មច្រើនជាងលោក កាំង ហ្គេកអ៊ាវ ដោយសារជនរូបនេះត្រូវបានគេចោទប្រកាន់ជាមេដឹកនាំខ្ពស់បំផុត។ លោក កាំង ហ្គេកអ៊ាវ បានទទួលស្គាល់នូវការទទួលខុសត្រូវរបស់ខ្លួន ហើយបានផ្តល់ការសហការជាមួយនឹងតុលាការ ដែលវាខុសពីករណីលោក អៀង សារី។ ទោះបីជាមានកត្តាទាំងនេះ ដែលគុណប្រយោជន៍ចំពោះជនជាប់ចោទ កាំង ហ្គេកអ៊ាវ ក៏ដោយ ក៏ជនជាប់ចោទរូបនេះ មិនត្រូវបានដោះលែងឲ្យនៅក្រៅឃុំ ដោយអង្គជំនុំជម្រះសាលាដំបូងដែរ។

៣) ការឃុំខ្លួនបណ្តោះអាសន្ន ជាវិធានចាំបាច់ ដើម្បីរក្សាសណ្តាប់ធ្នាប់សាធារណៈ

សុំទោស, ខ្ញុំអានឡើងវិញចំណុចទី៣តូច-- ការឃុំខ្លួនបណ្តោះអាសន្នជាវិធានចាំបាច់ដើម្បីរក្សាសណ្តាប់ធ្នាប់សាធារណៈ។ សហមេធាវីការពារក្តីបានលើកឡើងថា សាធារណជនបានទទួលរងការឈឺចាប់ពីអំឡុងពេលនៃរបបកម្ពុជាប្រជាធិបតេយ្យ ហើយពួកគាត់មានចំណាប់អារម្មណ៍ចំពោះដំណើរការនីតិវិធី អ.វ.ត.ក មិនអាចយកធ្វើជាមូលដ្ឋាននៃការចេញសេចក្តីសម្រេចបន្តការឃុំខ្លួនលោក អៀង សារី បាននោះទេ។ ម្យ៉ាងវិញទៀត ការឃុំខ្លួនមុនការជំនុំជម្រះក្តីមិនអាចត្រូវបានយកមកពិចារណាជាការផ្តន្ទាទោសមុនកាត់សេចក្តីនោះទេ ហើយមិនត្រូវយកមកប្រើសម្រាប់គោលបំណងដាក់ទណ្ឌកម្មនោះឡើយ។ លោក អៀង សារី អាចឃុំខ្លួនបណ្តោះអាសន្នយ៉ាងត្រឹមត្រូវបានតែក្នុងករណីដែលការដោះលែងរូបគាត់អាចបង្កឲ្យមានការគំរាមកំហែងដល់សណ្តាប់ធ្នាប់សាធារណៈ។

សហមេធាវីការពារក្តីបានបង្ហាញថា ក្រៅពីការអះអាងថា ការស៊ើបអង្កេតទៅលើជនសង្ស័យទាំង៥ អាចនឹងនាំឲ្យមានសង្គ្រាមស៊ីវិលនោះ មិនមានអ្នកណាម្នាក់យកចិត្តទុកដាក់អំពីការគំរាមកំហែងអស្ថិរភាពឲ្យបានខ្លាំងក្លានោះទេ បើទោះបីជាការជំនុំជម្រះក្តីថ្មីៗទៀតអាចនឹងចាប់ផ្តើមឡើងក៏ដោយ។ សហព្រះរាជអាជ្ញាបានឆ្លើយតបថា ការលើកឡើងដោយដើមបណ្តឹងឧទ្ធរណ៍ ដែលថាការជឿចាប់របស់សាធារណជននៅក្នុងសម័យកម្ពុជាប្រជាធិបតេយ្យមិនអាចយកមកធ្វើជាមូលដ្ឋានដើម្បីសម្រេចអំពីការបន្តថិរវេលាឃុំខ្លួនបាននោះទេ គឺស្ថិតនៅក្រោមការយល់ច្រឡំថា ការឃុំខ្លួនត្រូវបានគេយកមកប្រើប្រាស់ជាគោលបំណងក្នុងការដាក់ទណ្ឌកម្ម។ យ៉ាងនេះក៏ដោយ សាលដីកាលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងការបន្តថិរវលានៃការឃុំខ្លួនលើកទីមួយ មិនត្រូវបានគេធ្វើឡើងជាវិធានការ ការដាក់ទណ្ឌកម្មទេ ក៏ប៉ុន្តែវាជាសេចក្តីសម្រេចមួយដែលស្វែងរកនូវការរារាំង ដើម្បីកុំឲ្យខូចដល់សណ្តាប់ធ្នាប់សាធារណៈ។

សហព្រះរាជអាជ្ញាបានបង្ហាញទៀតថា ការជំទាស់ដោយដើមបណ្តឹងឧទ្ធរណ៍ ដែលថាមិនមានអ្នកណាម្នាក់យកចិត្តទុកដាក់អំពីការគំរាមកំហែងអស្ថិរភាពឲ្យបានខ្លាំងក្លានោះទេ គឺជាការប៉ុនប៉ងយកសេចក្តីវិនិច្ឆ័យរបស់ខ្លួន ដោយពុំបានចង្អុលភ័ស្តុតាងទៅជំនួសឲ្យសេចក្តីវិនិច្ឆ័យរបស់អង្គបុរេជំនុំជម្រះ។ លើសពីនេះទៀតវាមិនច្បាស់នៅឡើយអំពីសេចក្តីសំអាងដែលថា ពុំមានខូចដល់សណ្តាប់ធ្នាប់សាធារណៈ នៅពេលមានប្រកាសអំពីការស៊ើបសួរបន្ថែមទៀតទៅលើជនសង្ស័យចំនួន៥រូបបន្ថែមទៀតនោះនឹងមានសម្ពាធអ្វីខ្លះ ដែលមានឥទ្ធិពលប្រកបដោយសក្តានុពលទៅលើសណ្តាប់ធ្នាប់សាធារណៈ ដែលថាការដោះលែងជនត្រូវចោទត្រូវបានគេដឹងឮយ៉ាងទូលំទូលាយ ដូចដែលដើមបណ្តឹងឧទ្ធរណ៍ និងអ្នកចូលរួមជាមួយ ឌុច អាចនឹងមានគេដឹងឮបាន។

[០៩:៥០:០០]

ចំណុច ឃ៖ ការពិចារណាពីជម្រើសនៃឃុំខ្លួនដែលមានលក្ខណៈធូរស្រាល

សហមេធាវីការពារក្តីបានលើកឡើងទៀតថា សហចៅក្រមស៊ើបអង្កេតបានរំលោភលើឆន្ទានុសិទ្ធិនិងកាតព្វកិច្ចរបស់ខ្លួនតាមវិធាន២១.១ និង ២១.២ ដោយខកខានមិនបានពិចារណាអំពីជម្រើសឃុំខ្លួនដែលមានលក្ខណៈធូរស្រាល។ មុននឹងសម្រេចសេចក្តីពន្យារការឃុំនេះ សហមេធាវីការពារក្តីបានគូសបញ្ជាក់ថា ចំពោះករណីនេះការព្រួយបារម្ភមុនៗរបស់សហចៅក្រមស៊ើបអង្កេត និងអង្គបុរេជំនុំជម្រះទាក់ទងទៅនឹងភាពដែលអាចមានហានិភ័យនៃការរត់គេចខ្លួនរបស់លោក អៀង សារី ការគំរាមកំហែងដល់សុវត្ថិភាពរបស់គាត់ និងការរក្សាសណ្តាប់ធ្នាប់សាធារណៈអាចត្រូវបានដោះស្រាយតាមរយៈវិធានការដែលមានលក្ខណៈធូរស្រាលជាងការឃុំខ្លួន។

សហមេធាវីការពារក្តីបានលើកឡើងនូវវិធាន ៦៣.១ នៃវិធានផ្ទៃក្នុង ដែលក្នុងនោះបានចែងថា សហចៅក្រមស៊ើបអង្កេតអាចបង្គាប់ឲ្យជនត្រូវចោទមានសេរីភាពឡើងវិញ ឬត្រូវដោះលែងពីការឃុំខ្លួន។ ជនត្រូវចោទអាចដាក់ឲ្យនៅក្រោមការត្រួតពិនិត្យតាមផ្លូវតុលាការ ដីកាដែលចេញដោយសហចៅក្រមស៊ើបអង្កេតនេះត្រូវមានការបញ្ជាក់ឲ្យបានច្បាស់អំពីប្រាក់ធានានិងលក្ខខណ្ឌមួយចំនួនដើម្បីធានាអំពីវត្តមានរបស់ជនត្រូវចោទក្នុងកិច្ចដំណើរការនីតិវិធី និងដើម្បីការពារអ្នកដទៃទៀត។

សហមេធាវីការពារក្តីបានគូសបញ្ជាក់ថា វិធាន៦៥.១ នៃវិធានផ្ទៃក្នុងកំណត់ច្បាស់ថាដោយសារតែសហចៅក្រមស៊ើបអង្កេតសម្រេចថា លក្ខខណ្ឌមួយនៅក្នុងចំណោមលក្ខខណ្ឌនានាដែលបានរៀបរាប់នៅក្នុងវិធាន៦៣.៣ (ខ) មិនមានន័យថា សហចៅក្រមស៊ើបអង្កេតត្រូវតែចេញដីកាឃុំខ្លួននោះទេ។ សហព្រះរាជអាជ្ញាបានឆ្លើយតបថា គ្មានការបង្ហាញភស្តុតាងថ្មីចាប់តាំងពីអង្គបុរេជំនុំជម្រះបានកំណត់នូវថ្ងៃទី២៦ ខែកក្កដា ឆ្នាំ២០០៩ថា ការឃុំខ្លួននៅមន្ទីរឃុំខ្លួនរបស់អ.វ.ត.ក គឺជាការចាំបាច់ទៅតាមវិធាន៦៣.៣ ហើយថាជម្រើសផ្សេងៗទៅនឹងការឃុំខ្លួនគឺមិនសមស្របតាមភាពចាំបាច់សម្រាប់ការឃុំខ្លួនបណ្តោះអាសន្នជនត្រូវចោទនោះទេ។ ដូចដែលបានសំអាងនៅខាងដើម ដោយហេតុថាភាពចាំបាច់នៅក្នុងការឃុំខ្លួនបណ្តោះអាសន្នមិនបានកាត់បន្ថយអ្វីទេ នោះជម្រើសនៅក្នុងការឃុំខ្លួន គឺនៅបន្តមានទម្ងន់ច្រើនជាងដដែល។ សហព្រះរាជអាជ្ញាបានសន្និដ្ឋានថា សនិទានភាពដែលបានលើកឡើងនៅក្នុងសាលដីកាលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងការបន្តថិរវេលានៃការឃុំខ្លួនលើកទីមួយ គឺកំពុងនៅមានសុពលភាពនៅឡើយ ហើយគួរតែត្រូវបានតម្កល់ទុកជាបានការដើម្បីការពារនូវស្មារតីវិធាន៦៣.៣(ខ)។

លើសពីនេះ ដោយសារវាពុំមានការប្រែប្រួលកាលៈទេសៈណាមួយដែលអាចមានឥទ្ធិពលនៅលើភាពសមរម្យនៃជម្រើសផ្សេងទៅនឹងការឃុំខ្លួនទេនោះ សហចៅក្រមស៊ើបអង្កេតមិនបានបំពានទៅលើឆន្ទានុសិទ្ធិរបស់ខ្លួន ឬមានការខកខាននៅក្នុងការទទួលខុសត្រូវរបស់ខ្លួនទៅតាមវិធាន២១.១ និងវិធាន២១.២នៃវិធានផ្ទៃក្នុងនេះទេ។

ភ្នំពេញ, នៅថ្ងៃទី៨ ខែកុម្ភៈ ឆ្នាំ២០១០

សហចៅក្រមរបាយការណ៍

ហត្ថលេខា

ចៅក្រមន័យ ថុល, ចៅក្រម ខាទីនខា ឡាហ៊្វូស

ហើយបន្ទាប់ពីនេះសូមប្រគល់ភារកិច្ចសហការីដើម្បីមានយោបល់បន្ត។

[០៩:៤៩:២៩]

**ចៅក្រម ខាទីនខា ឡាហ៊្វូស៖**

បន្ថែមទៅលើរបាយការណ៍ ស្តីពីការពិនិត្យសំណុំរឿងដែលបានអានដោយសហចៅក្រមរបាយ-ការណ៍ បានលើកឡើងថា ក្រុមដើមបណ្តឹងរដ្ឋប្បវេណីទីពីរបានដាក់ចម្លើយតបទៅនឹងសារណា ហើយវាទាក់ទងទៅនឹងព័ត៍មានទៅលើដីកា ហើយយោងទៅលើដីការបស់សហចៅក្រមស៊ើបអង្កេតថា នៅក្នុងការស៊ើបអង្កេតនោះគឺមានបញ្ចូលបទប្រល័យពូជសាសន៍។ ដីកានេះគឺចុះថ្ងៃទី២០ ខែកញ្ញា ឆ្នាំ២០០៩ ហើយវាបានបញ្ចូលទៅជាលក្ខខណ្ឌនៃការឃុំខ្លួនផងដែរនៅក្នុងថ្ងៃទី១០ ខែវិច្ឆិកា ឆ្នាំ២០០៩។

**ប្រធានអង្គបុរេ៖**

ជនត្រូវចោទលោក អៀង សារី, តើលោកចង់និយាយដោយផ្ទាល់ខ្លួនអំពីហេតុផលនានាទាក់ទងនឹងបណ្តឹងឧទ្ធរណ៍របស់លោក?

អត់ឮទេអី?

លោកអៀង សារី ឮដែរ?

បាទៗ, តើលោកចង់និយាយមូលហេតុនានាដែលទាក់ទងនឹងបណ្តឹងឧទ្ធរណ៍របស់លោកដោយផ្ទាល់ខ្លួន ឬមួយលោកប្រគល់សិទ្ធិជូនមេធាវីរបស់លោកនិយាយក្នុងនាមលោក?

**ជនត្រូវចោទ៖**

សូមគោរពលោកប្រធាន, ខ្ញុំប្រគល់សិទ្ធិឲ្យមេធាវីរបស់ខ្ញុំនិយាយជំនួសខ្ញុំ។

**ប្រធានអង្គបុរេ៖**

អ៊ីចឹងតទៅនេះសូមអញ្ជើញសហមេធាវីជនត្រូវចោទឡើងធ្វើសេចក្តីសន្និដ្ឋានក្នុងរយៈពេលមួយម៉ោង ទាំងពីរនាក់ហ្នឹងបាទ។ សូមអញ្ជើញ!

លោក អៀង សារី មានយោបល់អ្វី?

ស្នើសុំអង្គុយកន្លែងហ្នឹង ឬមួយ? សុំសម្រាក? បាទៗ សុំលោកមេធាវីមានប្រសាសន៍ទៅមើលថាតើគាត់ស្នើសុំអី?

**លោក អាង ឧត្តម៖**

ជាបឋមខ្ញុំបាទ អាង ឧត្តម សូមគោរពលោកប្រធាន សូមគោរពលោក លោកស្រីចៅក្រម។ ដូចសព្វរាល់ដងមុននឹងខ្ញុំចាប់ផ្តើមសូមអនុញ្ញាតលោកប្រធាន អនុញ្ញាតឲ្យលោក អៀង សារី មកអង្គុយក្បែរយើងខ្ញុំដើម្បីងាយប្រាស្រ័យទាក់ទង ព្រោះអម្បាញ់មិញនេះគាត់ក៏បានសុំសម្រាក។ ខ្ញុំក៏អត់ទាន់យល់ពាក្យសម្រាករបស់គាត់ គាត់សម្រាកយ៉ាងម៉េច ខ្ញុំអត់ទាន់ដឹង ព្រោះជាទូទៅគាត់មិនអាចអង្គុយលើសកន្លះម៉ោងបានទេ។ ក្នុងការធ្វើការងាររបស់ខ្ញុំជាមួយគាត់ គាត់អង្គុយបានជួនកាលកន្លះម៉ោង ឬ ១៥នាទី គាត់ទៅបន្ទប់ទឹកអ៊ីចឹងជាធម្មតា ប៉ុន្តែឥឡូវនេះយើងបានដល់មួយម៉ោងហើយ គាត់ត្រូវការសម្រាក។ ខ្ញុំមិនដឹងថា សម្រាក គាត់ចង់ទៅបន្ទប់ទឹក ឬក៏សម្រាកដោយសារគាត់មានអាការៈយ៉ាងម៉េចខ្ញុំអត់ទាន់ដឹង ខ្ញុំសូមធ្វើការប្រាស្រ័យទាក់ទងជាមួយគាត់សិន។

**ប្រធានអង្គបុរេ៖**

អញ្ជើញ។

*(មេធាវីការពារក្តីធ្វើការប្រាស្រ័យនឹងជនត្រូវចោទ)*

**លោក អាង ឧត្តម៖**

សុំអនុញ្ញាតលោកប្រធានឲ្យលោក អៀង សារី សម្រាកដើម្បីបន្ទោបង់ទាន គាត់ត្រូវការបន្ទោបង់។

**ប្រធានអង្គបុរេ៖**

អ៊ីចឹង តុលាការអនុញ្ញាតតាមសំណើរបស់លោក។

តុលាការសម្រាក១៥នាទី។

[០៩:៥៤:២២]

*(សវនាការសម្រាកពីម៉ោង ០៩:៥៤នាទី ដល់ម៉ោង ១០:១៥នាទី)*

**លោក ឈន ព្រលឹង៖**

សូមអញ្ជើញក្រោកឈរ! តុលាការចូលកាន់សាលសវនាការ។

[១០:១៦:៥២]

**ប្រធានអង្គបុរេ៖**

សូមបន្តនីតិវិធី។ មុននឹងយើងបន្តទៅទៀត ខ្ញុំសូមលើកយកសំណើរបស់សហព្រះរាជអាជ្ញាសុំដាក់បញ្ចូលក្នុងសំណុំរឿងនូវរបាយការណ៍ឆ្នាំ២០០៩ ស្ដីពីសន្ទស្សន៍នៃសន្តិភាពពិភពលោក *Global Peace Index*។ សំណើនេះ អង្គបុរេជំនុំជម្រះបានទទួលម្សិលមិញ នៅរសៀលម្សិលមិញ។

ដូច្នេះអង្គបុរេជំនុំជម្រះសូមស្នើដល់ភាគីមានយោបល់ចំពោះសំណើរបស់សហព្រះរាជអាជ្ញានេះ សូមអញ្ជើញ!

លោកសហមេធាវី ខ្ញុំសូមបញ្ជាក់ថា ជនត្រូវចោទលោក អៀង សារី អម្បាញ់មិញលោកបានស្នើថាសុំឲ្យនៅអង្គុយជាប់នឹងលោក។

**លោក អាង ឧត្ដម៖**

បាទ, ទានបាទ។

**ប្រធានអង្គបុរេ៖**

ប៉ុន្តែខ្ញុំសូមជម្រាបថា នៅពេលដែលតុលាការអញ្ជើញគាត់មកឆ្លើយនូវសម្ដីចុងក្រោយ គាត់ត្រូវមកអង្គុយក្នុងក្រចកសេះវិញ។

**លោក អាង ឧត្ដម៖**

បាទទាន។

**ប្រធានអង្គបុរេ៖**

ខ្ញុំសូមកែតម្រូវ។ អង្គបុរេជំនុំជម្រះគឺថា សុំឲ្យជនត្រូវចោទលោក អៀង សារី ទៅអង្គុយខាងម្ខាងវិញ មិនមែនអង្គុយជាប់នឹងលោកទេ។ ទៅខាងណោះ បាទ។

[redacted]

[redacted]

[១០:២៥:១៧]

**ប្រធានអង្គបុរេ៖**

តុលាការសុំបន្តនីតិវិធី។ សូមអញ្ជើញសហមេធាវីធ្វើសេចក្តីសន្និដ្ឋានរយៈពេលមួយម៉ោង។

**លោក អាង ឧត្តម៖**

ជាថ្មីម្តងទៀត ខ្ញុំសូមគោរពលោកប្រធាន សូមគោរពលោក លោកស្រី ចៅក្រមទាំងអស់ សូមគោរពអង្គសវនាការ និងសាធារណជនផង។ មុននឹងចូលដល់ស្ថានការពាររបស់យើងខ្ញុំ ដូចដែលលោកប្រធាននឹងលើកអម្បាញ់មិញនេះថា មានសំណើរមួយរបស់សហព្រះរាជអាជ្ញា ដែលនៅហ្នឹងដៃខ្ញុំទើបដាក់ពីម្សិលមិញថ្ងៃទី១០ វេលាម៉ោងមួយ ហើយទាក់ទងនឹងឯកសារនេះទៀត មានតែភាសាអង់គ្លេសនិងភាសាបារាំង។ ទោះជាខ្ញុំអាចយល់ភាសាអង់គ្លេសបាន ក៏ខ្ញុំអត់មានពេលពិនិត្យពិចារណាដែរ។

អ៊ីចឹង ខ្ញុំបាទលោកប្រធានមេត្តាច្រានចោលនូវលិខិតដែលសុំដាក់ចូលនេះ ដោយមានមូលហេតុពីរ។ ទីមួយ ទាក់ទងនឹងរឿងការភាពស្មើគ្នាចំពោះមុខច្បាប់ គឺខ្ញុំបាទយើងខ្ញុំខាងការពារមិនមានពេលវេលាគ្រប់គ្រាន់ដើម្បីឆ្លើយតបនឹងសំណើរនេះជាប្រក្រតី។ ទីពីរ ដោយសារខ្ញុំមិនទាន់បានពិនិត្យ និង

ពិចារណាលើឯកសារនេះ ខ្ញុំយល់ថាឯកសារនេះមិនពាក់ព័ន្ធ។ អ៊ីចឹង សូមតុលាការមេត្តាច្រានចោលសំណើរសុំដាក់ឯកសារនេះមកក្នុងសំណុំរឿង។ សូមតុលាការមេត្តាសម្រេចលើចំណុចនេះសិន។

[២៧:២៨:២៤]

**ប្រធានអង្គបុរេ៖**

លោកមេធាវី លោកចង់បានឯកសារហ្នឹងជាភាសាខ្មែរទេ?

**លោក អាង ឧត្តម៖**

ជាទូទៅ ខ្ញុំត្រូវការឯកសារជាភាសាខ្មែរ ត្រូវការពេលវេលាគ្រប់គ្រាន់ ដើម្បីពិនិត្យ និងវិភាគ ហើយក្នុងទីនេះ យើងឃើញមានភ្ជាប់ដោយឧបសម្ព័ន្ធមួយផង ប្រគល់មកឲ្យខ្ញុំបាទ យើងខ្ញុំនៅទីនេះអម្បាញ់មិញនេះ អត់ឃើញមានឧបសម្ព័ន្ធហ្នឹងទៀត។ ខ្ញុំមិនដឹងឧបសម្ព័ន្ធមួយនេះ Annex1 នេះវានៅឯណា វាជារឿងអី ខ្ញុំអត់ដឹង។ សូមតុលាការពិចារណា ខ្ញុំនៅតែទាមទារសូមតុលាការច្រានចោលសំណើនេះដដែល។ សូមអរគុណ។

[១០:៣០:០០]

ជាលើកទីបី ខ្ញុំបាទសូមគោរពលោកប្រធាន លោក លោកស្រីចៅក្រមនៃអង្គជំនុំអង្គបុរេជំនុំជម្រះ។ ក្នុងនាមជាសហមេធាវីការពារក្តីជូនលោក អៀង សារី។ លោក ម៉ែខល កាណាវាស ដែលជាសហភាតារបស់យើងខ្ញុំ មានកិត្តិយស និងមានមោទនភាពក្រៃលែងដោយបានការពារក្តីជូនលោក អៀង សារី ហើយជួយកិច្ចការរបស់យើងខ្ញុំនៅថ្ងៃនេះ យើងមានអ្នកគ្រប់គ្រងឯកសារសំណុំរឿងរបស់យើងគឺលោក សូ មូសេនី យើងមានទីប្រឹក្សារបស់យើងគឺ អ្នកស្រី តាន់ញ៉ា ប៉េតៃ យើងមានលោក និរិលស្វរាប ផងដែរ ជាអ្នកជំនួយការ និងជាទីប្រឹក្សារបស់យើង។

លោកប្រធានជាទីគោរព, សំណើសុំការពិចារណារបស់យើងខ្ញុំនាថ្ងៃនេះ គឺមានសណ្ឋានសង្ខេបខ្លី ព្រោះថាបញ្ហានៃការឃុំខ្លួនបណ្តោះអាសន្នឥឡូវនេះត្រូវបានយើងទាំងអស់គ្នាយល់ជ្រួតជ្រាបយ៉ាងជាក់ច្បាស់ហើយ។ គោលបំណងរបស់យើងខ្ញុំបានកំណត់យ៉ាងជាក់លាក់រួចហើយ នៅក្នុងសារណានៃបណ្តឹងឧទ្ធរណ៍របស់យើងខ្ញុំ។

តុលាការជាទីគោរព, លោក អៀង សារី ត្រូវបានឃុំខ្លួនដោយការិយាល័យសហចៅក្រមស៊ើបអង្កេតក្រោយលក្ខណៈវិនិច្ឆ័យបីចំណុច ក្នុងចំណោមលក្ខណៈនៃវិនិច្ឆ័យទាំងប្រាំដែលកំណត់ដោយវិធាន ៦៣.៣(ខ) នៃវិធានផ្ទៃក្នុង។ ជាពិសេសការឃុំខ្លួនបណ្តោះអាសន្នចាំបាច់ដើម្បី៖

១) ធានាអំពីវត្តមានរបស់លោក អៀង សារី នៅក្នុងដំណើរការនីតិវិធី

២) ការពារសន្តិសុខផ្ទាល់ខ្លួនរបស់គាត់ និង៣) ដើម្បីរក្សាសណ្ដាប់ធ្នាប់សាធារណៈ។

អង្គបុរេជំនុំជម្រះធ្លាប់បានយល់ឃើញកាលពីលើកមុនថា នៅក្នុងការប៉ាន់ប្រមាណមើលថាតើមានភ័ស្តុតាងជាក់លាក់ដើម្បីគាំទ្រដល់ហានិភ័យជាក់ស្ដែងចំពោះសណ្ដាប់ធ្នាប់សាធារណៈឬទេ? នោះតម្រូវឲ្យមានវិធានការទស្សទាយមួយ។ សូមពិនិត្យមើលនៅក្នុងកថាខណ្ឌទី១១ នៃសាលដីការបស់អង្គបុរេជំនុំជម្រះលើបណ្ដឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាសម្រេចលើការឃុំខ្លួនបណ្ដោះអាសន្នលោក អៀង សារី ចុះថ្ងៃទី១៧ ខែតុលា ឆ្នាំ២០០៨។

តាមពិតទៅវិធានការទស្សទាយនេះអនុវត្តចំពោះការប៉ាន់ប្រមាណ មើលគោលបំណងទាំងអស់ក្រោមវិធាន៦៣ ពីព្រោះប្រសិនបើជនត្រូវចោទត្រូវបានឃុំខ្លួនបណ្ដោះអាសន្នក្រោមវិធាននេះ នោះគាត់ត្រូវបានឃុំខ្លួនមិនមែនដោយសារតែអ្វីដែលគាត់បានប្រព្រឹត្តនោះទេ ក៏ប៉ុន្តែគាត់ត្រូវបានឃុំខ្លួនព្រោះមកពីការិយាល័យសហចៅក្រមស៊ើបអង្កេត ឬអង្គបុរេជំនុំជម្រះទស្សទាយថា គាត់អាចប្រព្រឹត្ត ឬមិនបានប្រព្រឹត្តអ្វី ឬសំខាន់ជាងនេះទៅទៀតនោះ ព្រោះមកពីអ្វីដែលគាត់អាចនឹងត្រូវបានប្រព្រឹត្តចំពោះគាត់នូវពេលអនាគតទៅវិញទេ។

[១០:៣៤:៤៩]

និយាយបែបម្យ៉ាងទៀតគឺថា អង្គបុរេជំនុំជម្រះ ឬការិយាល័យសហចៅក្រមស៊ើបអង្កេតត្រូវតែទស្សទាយថា លោក អៀង សារី ប្រសិនបើត្រូវត្រូវបានដាក់ឲ្យនៅក្រៅឃុំ តើគាត់នឹងព្យាយាមរត់គេច និងមិនចូលមកសវនាការដែរឬទេ? ឬថាតើការដាក់គាត់ឲ្យនៅក្រៅឃុំ និងបង្កការគំរាមកំហែងដល់សណ្ដាប់ធ្នាប់សាធារណៈ ឬពិតជានឹងមានការគំរាមកំហែងដល់សន្តិសុខផ្ទាល់ខ្លួនរបស់គាត់ដែរឬទេ? ទាក់ទងនឹងចំណុចនេះ ខ្ញុំសូមបើករង្វង់ក្រចកបន្តិច។ សូមជម្រាបជាពិសេសសាធារណជនប្រហែលមិនទាន់យល់ច្បាស់ ឬយល់មិនទាន់ដល់ស៊ីជម្រៅថា គោលជំហរបស់មេធាវីការពារតាំងពីដើមដំបូង ជាពិសេសចាប់តាំងពីសវនាការលើកទីមួយ ទីពីរ នៅទីនេះ ទីបី យើងខ្ញុំមិនដែលបានសុំឲ្យលោក អៀង សារី នៅក្រៅឃុំបណ្ដោះអាសន្នទេ សំណើសុំរបស់យើងខ្ញុំគឺសុំតុលាការផ្លាស់ប្ដូរលក្ខខណ្ឌនៃការឃុំខ្លួនពីការឃុំខ្លួននៅពន្ធនាគារឬមន្ទីរឃុំឃាំង អ.វ.ត.ក នេះទៅជាការឃុំខ្លួនគាត់នៅឯគេហដ្ឋានដែលលោក អៀង សារី ជ្រើសរើស ឬឃុំខ្លួននៅមន្ទីរពេទ្យក្នុងករណីដែលលោក អៀង សារី មានជំងឺធ្ងន់ធ្ងរ។ ខ្ញុំសូមបិទរង្វង់ក្រចកវិញ។

ក្នុងការទស្សទាយពីការប្រព្រឹត្តិនាពេលអនាគតរបស់លោក អៀង សារី ក្រោមវិធាន៦៣.៣(ខ) អង្គបុរេជំនុំជម្រះត្រូវតែប្រុងប្រយ័ត្ន ដោយតាមពិតទៅមិនត្រូវជ្រើសរើសយកសេចក្តីបង្គាប់ណាដែលផ្តល់ផលអនុគ្រោះតិចតួចដល់ជនត្រូវចោទឡើយ។ ការជ្រើសរើសដែលផ្តល់ផលអនុគ្រោះតិចតួចនេះទំនងជាត្រូវបានអនុវត្តរួចមកហើយកាលពីលើកមុន។

ឧទាហរណ៍ ខណៈដែលអាចមានភ័ស្តុតាងគាំទ្រដល់ការទស្សទាយថា លោក អៀង សារី អាចប៉ុនប៉ងរត់គេចខ្លួន ក៏ប៉ុន្តែខណៈនោះប្រសិនបើមានភ័ស្តុតាង ឬកត្តានានាដែលប្រឆាំងសម្មតិកម្មនេះនោះនៅក្នុងការអនុវត្តគោលការណ៍វិមតិសង្ស័យ *អ៊ិនឌូ ប៊ីអូ ប្រូរេអូ* ផលប្រយោជន៍ត្រូវតែបានដល់ជនត្រូវចោទ។ ដូច្នេះហើយគាត់មិនគួរត្រូវបានឃុំខ្លួនក្រោមមូលដ្ឋាននេះឡើយ។ ធម្មតាពិតជាមិនមានភ័ស្តុតាងណាសម្រាប់ពឹងផ្អែកដើម្បីសន្និដ្ឋានថា ការដោះលែងលោក អៀង សារី ឲ្យនៅក្រៅឃុំបណ្តោះអាសន្ននឹងបង្កនូវហានិភ័យជាក់ស្តែងដល់គោលបំណងណាមួយនៃគោលបំណងទាំងនេះឡើយ។

ការសន្និដ្ឋានរបស់សហចៅក្រមស៊ើបអង្កេតទៅលើបញ្ហានេះ គឺបានពឹងផ្អែកទៅលើអាកប្បកិរិយាព្យាបាទរបស់មនុស្សមួយចំនួន។ ពឹងផ្អែកទៅលើការបកស្រាយមិនសមគួរទៅលើភ័ស្តុតាងដែលមិនពាក់ព័ន្ធ និងពឹងផ្អែកទៅលើការជឿទុកចិត្តទៅលើការបកស្រាយចំពោះការពិចារណាជាសម្មតិកម្មស្មានៗដែលមានផលប្រយោជន៍អនុគ្រោះតិចតួច ដូចដែលបានពន្យល់ខាងលើរួចហើយ។

[១០:៣៩:២៦]

យោងតាមវិធាន ៦៣.៣ (ខ)(៣) លោក អៀង សារី អាចត្រូវបានឃុំខ្លួនប្រសិនបើការឃុំខ្លួននេះ គឺចាំបាច់ដើម្បីធានានូវអំពីវត្តមានរបស់គាត់នៅពេលសវនាការ។ សហចៅក្រមស៊ើបអង្កេត និងអង្គបុរេជំនុំជម្រះលើកមុនបានយល់ឃើញថា មានហានិភ័យនៃការរត់គេចខ្លួនប្រសិនបើលោក អៀង សារី មិនត្រូវបានឃុំខ្លួនបណ្តោះអាសន្នទេនោះ។ ហើយថា ដូច្នេះការឃុំខ្លួនគឺចាំបាច់ស្របតាមវិធាន ៦៣.៣(ខ)(៣)។ លោក អៀង សារី មានអាយុ៨៤ឆ្នាំ ហើយអាចឈានចូលដល់៨៥ឆ្នាំ ឆ្នាំនេះ។ គាត់មានសុខភាពយ៉ាងធ្ងន់ធ្ងរដែលដាក់កម្រិតយ៉ាងខ្លាំងដល់ការធ្វើចល័តទីរបស់គាត់ គាត់ស្ទើរតែដើរដោយខ្លួនឯងមិនរួចផង កុំថាឡើយដល់ទៅរត់គេចខ្លួន។

ដូចដែលមេធាវីការពារបានថ្លែងដដែលច្រើនដងរួចមកហើយថា អ្នកស្រី អៀង ធីរិទ្ធ ដែលជាភរិយាលោក អៀង សារី អស់រយៈពេល៥០ឆ្នាំមកហើយ ក៏ត្រូវបានឃុំខ្លួននៅមន្ទីរឃុំឃាំងរបស់ អ.វ.ត.ក នេះផងដែរ។ អ៊ីចឹងប្រសិនបើលោក អៀង សារី រត់គេចខ្លួននោះ គាត់និងមិនមានឱកាស

អាចជួបមុនភរិយាគាត់តទៅទៀតទេ។ នេះជាចំណុចមួយដែលសូមទាញអារម្មណ៍និងការពិចារណា។ កត្តាទាំងនេះ ត្រូវតែបានយកមកពិចារណានៅក្នុងការប្រមាណស្ទង់មើលហានិភ័យជាសក្តានុពលនៃការរត់គេចខ្លួន។ ម្យ៉ាងវិញទៀត យើងទាំងអស់គ្នា សាធារណជនសឹងតែទូទៅ បានដឹង បានស្គាល់ រូបរាងរាង្គកាយ របស់លោក អៀង សារី ច្បាស់ណាស់។ វាជាការពិតប្រាកដទេ? មានការប្រាកដនិយមទេ ក្នុងលើកឡើងថា គាត់នឹងអាចរត់គេចខ្លួនពីប្រទេសកម្ពុជាដោយគ្មានអ្នកណាគេដឹងនោះ។ ជាពិសេសបើគិតទៅដល់ស្ថានភាពសុខភាពរបស់គាត់។

[១០:៤២:៤១]

ដើមបណ្តឹងរដ្ឋប្បវេណីជឿជាក់ថា សេចក្តីថ្លែងដែលត្រូវបានរាយការណ៍របស់សម្តេចអគ្គមហាសេនាបតី ហ៊ុន សែន នាយករដ្ឋមន្ត្រីថា “សម្តេចសង្ឃឹមថា អ.វ.ត.ក អស់លុយឲ្យឆាប់ទៅដើម្បីឲ្យប្រព័ន្ធតុលាការកម្ពុជាបន្តនីតិវិធី និងពន្លឿនរឿងក្តីបច្ចុប្បន្ន គឺយ៉ាងណាក្តីវាជាការបង្ហាញពីការគាំទ្រដោយផ្ទាល់ដល់លោក អៀង សារី។ នេះជាការអានមួលបង្កាច់ជាក់ច្បាស់ទៅលើសេចក្តីថ្លែងការណ៍របស់សម្តេចនាយករដ្ឋមន្ត្រី។ តាមពិតសេចក្តីថ្លែងការណ៍នោះ អត់ថ្លែង ទស្សទាយដោយផ្ទាល់ ឬប្រយោលគាំទ្រលោក អៀង សារី សោះ គឺលោកថ្លែងទាក់ទងតែរឿងតុលាការ។

[១០:៤៤:០៤]

ពិចារណាពីបរិបទនៅក្នុងសេចក្តីថ្លែងការណ៍របស់សម្តេចនាយករដ្ឋមន្ត្រី វាបញ្ជាក់យ៉ាងច្បាស់ក្រឡែតថា សម្តេចមិនបានបង្ហាញពីការគាំទ្រដល់លោក អៀង សារី នោះទេ។ ប៉ុន្តែ ផ្ទុយទៅវិញសម្តេចបានថ្លែងថា សម្តេចបានជំទាស់ទៅនឹងចោទប្រកាន់បន្ថែម។ ប្រយោគបន្ទាប់របស់សម្តេច ដូចដែលនៅក្នុងអត្ថបទមួយ ដែលដកស្រង់ដោយដើមបណ្តឹងរដ្ឋប្បវេណីគឺថា “ខ្ញុំសុខចិត្ត (សូមទោសក្រែងលោសម្តីហ្នឹងមិនដូចទាំងអស់*)* តែតាមន័យគឺថា “ខ្ញុំសុខចិត្តឲ្យតុលាការនេះបរាជ័យ ប៉ុន្តែខ្ញុំមិនព្រមឲ្យប្រទេសកម្ពុជា ធ្លាក់ចូលទៅក្នុងភ្លើងសង្គ្រាមម្តងទៀតឡើយ”។ នេះគឺជាជំហរដាច់ខាត។ “សូមទោសតែមនុស្សប៉ុន្មាន-- សូមកាត់ទោសតែមនុស្សប៉ុន្មាននាក់បានហើយ”។ នេះជាសម្តីដែលពិតប្រាកដដែលសម្តេចនាយករដ្ឋមន្ត្រីបានថ្លែង។

[១០:៤៥:២២]

អ៊ីចឹងគ្មានចំណុចណាថាលោកគាំទ្រលោក អៀង សារី ទេ។ ចុងបំផុតមិនដូចតុលាការព្រហ្ម-អន្តរជាតិនានា ដូចជា អាយ.ស៊ី.ស៊ី, អាយ.ស៊ី.ធី.វ៉ាយ ឬក៏ អាយ.ស៊ី.ធី.អ ទេ។ អ.វ.ត.ក របស់យើង

មាននគរបាលយុត្តិធម៌ និងមានអំណាចចេញដីកាបង្គាប់ឲ្យនាំខ្លួន។ បាទ សូមមើលវិធាន១៥, ៤២, ៤៤ និង៤៥។ ដូច្នេះ សេចក្តីត្រូវការសម្រាប់ការឃុំខ្លួន ដើម្បីធានាវត្តមានក្នុងដំណើរការនីតិវិធីនៅទីនេះ មិនសំខាន់ដូចនៅតុលាការអន្តរជាតិនានានោះទេ។ សហចៅក្រមស៊ើបអង្កេត និងអង្គបុរេជំនុំជម្រះពីមុនធ្លាប់បានយល់ឃើញថា ការឃុំខ្លួន គឺចាំបាច់ដើម្បីការពារសុវត្ថិភាពរបស់លោក អៀង សារី ហៅថា ដូច្នេះការឃុំខ្លួនបណ្តោះអាសន្ន គឺចាំបាច់ ដោយអនុលោមវិធាន ៦៣.៣ (ខ៤)។ ការសន្និដ្ឋានបែបនេះ ទំនងជាពឹងផ្អែកទៅលើភាពតានតឹងនៅក្នុងសង្គមកម្ពុជា និងលើហេតុដែរថា មានហានិភ័យនៃការគំរាមបំពានទៅលើលោក កាំង ហ្កេកអ៊ាវ ហៅ ឌុច។ ដីការបស់សហចៅក្រមស៊ើបអង្កេត ស្តីពីការបន្តចិរវេលានៃការឃុំខ្លួនបណ្តោះអាសន្នបានកត់សម្គាល់ថា ពុំមានការផ្លាស់ប្តូរនៅក្នុងកាលៈទេសៈនានាទេ ចាប់តាំងពីមានការសម្រេចចុងក្រោយបំផុតរបស់អង្គបុរេជំនុំជម្រះ។

ហេតុដូច្នេះ ការគំរាមកំហែងប្រឆាំងនឹងលោក កាំង ហ្កេកអ៊ាវ មិនអាចប្រៀបធៀបទៅនឹងការគំរាមកំហែងចំពោះលោក អៀង សារី នោះទេ។ ប្រសិនបើមានការគំរាមកំហែងលើលោក កាំង ហ្កេកអ៊ាវ នោះអាចមក-- អាចព្រោះមកពីគាត់បានសារភាពពីឧក្រិដ្ឋកម្មរបស់គាត់នៅឯសវនាការជំនុំជម្រះក្តី ដែលត្រូវបានធ្វើការផ្សព្វផ្សាយទូលំលាយ។ លោក អៀង សារី មិនបានសារភាពពីការប្រព្រឹត្តិបទឧក្រិដ្ឋណាមួយនោះទេ ដោយសារតែការជំនុំជម្រះលើរឿងក្តីរបស់គាត់មិនទាន់បានចាប់ផ្តើមនៅឡើយ។

ការផ្សព្វផ្សាយនៅជុំវិញបទឧក្រិដ្ឋដែលត្រូវបានចោទប្រកាន់ចំពោះគាត់ គឺមានចំនួនតិចជាងចំនួនការផ្សព្វផ្សាយជុំវិញឧក្រិដ្ឋកម្មរបស់លោក កាំង ហ្កេកអ៊ាវ។ សហចៅក្រមស៊ើបអង្កេត ក៏មានកំហុសដោយខកខានមិនបានពិចារណា ថាតើការឃុំខ្លួននៅផ្ទះដោយមានការយាមកាមពីក្រុមប្រដាប់អាវុធមានសមត្ថកិច្ច និងការពារលោក អៀង សារី ក៏ដូចគ្នានឹងការពារការឃុំខ្លួនគាត់ដែរឬទេ? នៅចំណុចនេះ គឺសហចៅក្រមស៊ើបអង្កេតគាត់មិនបានពិចារណា។ វិធានការនានាគួរតែត្រូវបានប្រកាន់យកដើម្បីបន្ធូរបន្ថយ និងសម្រាលក្តីកង្វល់ដែរថា គាត់នឹងអាចទទួលគ្រោះនៅពេលធ្វើដំណើរពីតុលាការ និងត្រឡប់ពីតុលាការវិញ។ មកដល់ពេលនេះ ពុំមានកិច្ចខិតខំប្រឹងប្រែងណាមួយដើម្បីស្វែងយល់ ថាតើការឃុំខ្លួននៅផ្ទះ ជាវិធានការការពារមួយអាចអនុវត្តបានដែរឬយ៉ាងណា?

[១០:៥០:១៤]

មូលហេតុពិតជាក់ស្តែងដែលងាយយល់នោះ អាចថា ដោយគ្មានស្ថិតនៅក្នុងកាលៈទេសៈណាសោះ ដែលសហចៅក្រមស៊ើបអង្កេត ឬអង្គបុរេជំនុំជម្រះធ្លាប់បានពិចារណារកវិធានការណាមួយ បើ

ទោះជាវិធានការនោះសមស្រប និងគ្រប់គ្រាន់ក៏ដោយ ដែលនឹងអនុញ្ញាតឲ្យលោក អៀង សារី ទទួលបានអ្វីដែលប្រហាក់ប្រហែលនឹងការមានសេរីភាពរបស់គាត់ឡើយ។ ហេតុដែរថា សាធារណជនបានទទួលរងគ្រោះពីរបបកម្ពុជាប្រជាធិបតេយ្យ និងការដែលថា ដូច្នេះហើយទើបពួកគេមានការចាប់អារម្មណ៍ពីដំណើរការនីតិវិធីនៅអ.វ.ត.ក។ នោះ មិនអាចយកជាមូលដ្ឋាន ដើម្បីបង្គាប់ឲ្យបន្តថិរវេលានៃការឃុំខ្លួនលោក អៀង សារី ឡើយ។ យើងត្រូវតែរងចាំ ដូចដែលបានកត់សម្គាល់ដោយអង្គបុរេជំនុំជម្រះរបស់ អាយ.ស៊ី.ស៊ី ថាការឃុំខ្លួនបណ្តោះអាសន្ន ចំណុចនេះយើងត្រូវតែចាំ រង់ចាំ ចាំទាំងអស់គ្នាដឹងឮទាំងអស់គ្នាថា អាយ.ស៊ី.ស៊ី គាត់បញ្ជាក់អ៊ីចឹងថា ការឃុំខ្លួនបណ្តោះអាសន្នមិនត្រូវបានចាត់ទុកថាជាការដាក់ទណ្ឌកម្មនូវជំណាក់កាលស៊ើបអង្កេតនោះទេ ហើយក៏មិនត្រូវប្រើប្រាស់វាសម្រាប់គោល-បំណងដាក់ទណ្ឌកម្មនោះដែរ។ សូមពិនិត្យមើលរឿងក្តីរដ្ឋអាជ្ញាតទល់នឹង *ប៊ិមបា ហ្គាំបូ* អាយ.ស៊ី.ស៊ី ០០១/០៥/៨៨ កថាខណ្ឌទី៣៨ នៃសេចក្តីសម្រេចលើសំណើសុំដោះលែងបណ្តោះអាសន្នដល់លោកហ្សង់ព្យែរ ប៊ិមបាហ្គាំបូ និងការជួបប្រជុំសវនាការមួយធ្វើឡើងដោយរាជាណាចក្រប៊ែលហ្ស៊ិក សាធារណរដ្ឋព័រទុយហ្គាល់ សាធារណរដ្ឋបារាំង សាធារណរដ្ឋអាល្លឺម៉ង់ សាធារណរដ្ឋអ៊ីតាលី និងសាធារណរដ្ឋអាហ្វ្រិចខាងត្បូង នាថ្ងៃទី១៤ ខែសីហា ឆ្នាំ២០០៩។

លោក អៀង សារី អាចសមនឹងត្រូវឃុំខ្លួន តែប្រសិនណាការដាក់ឲ្យគាត់នៅក្រៅឃុំនឹងបង្កការគំរាមកំហែងដល់សណ្តាប់ធ្នាប់សាធារណៈតែប៉ុណ្ណោះ។ ករណីនៅទីនេះ ពិតជាមិនមែនដូច្នេះឡើយ។ សូមពិចារណាថា តាមការជំទាស់តវ៉ារបស់សហព្រះរាជអាជ្ញានានាថ្មីនេះៗ ថាកិច្ចស៊ើបសួរនានានឹងត្រូវចាប់ផ្តើមពាក់ព័ន្ធដល់ជនសង្ស័យចំនួនប្រាំនាក់បន្ថែមទៀត។ ជនសង្ស័យទាំងនេះនៅតែជាចំនួនច្រើនហើយអត្តសញ្ញាណរបស់ពួកគេមិនទាន់ត្រូវបានបង្ហាញឡើយ បើទោះជាអត្តសញ្ញាណជនសង្ស័យពីរនាក់ត្រូវបានគេស្គាល់ជាទូទៅហើយក្តី។ សង្គមកម្ពុជាមិនបានរងការគំរាមកំហែងឡើយ ដោយការប្រកាសថាសវនាការជំនុំជម្រះទោសថ្មីៗប្រហែលនឹងអាចចាប់ផ្តើម។

[១០:៥៤:៣៣]

លោកប្រធាន លោក លោកស្រី ជាទីគោរព អង្គសវនាការ, ទាក់ទងនឹងការគំរាមកំហែងដល់សណ្តាប់ធ្នាប់សាធារណៈ និងការគំរាមកំហែងដល់សុវត្ថិភាពរបស់លោក អៀង សារី ទាំងនេះជាធាតុផ្សំចំនួនពីរនៃវិធាន ៦៣.៣ (ខ) ដែលមិនតម្រូវឲ្យមានកិរិយាប្រព្រឹត្តគួរស្តីបន្ទោសណាមួយរបស់លោក អៀង សារី ដើម្បីធ្វើយុត្តិកម្មថាត្រូវតែបន្តការឃុំខ្លួនគាត់នោះឡើយ។ តាមពិត ការពឹងផ្អែកលើលក្ខណៈ

វិនិច្ឆ័យទាំងនេះ ហ៊ុមព័ទ្ធទៅដោយការរំលោភលើសច្ចធារណ៍និរទោស គឺការសន្មតជាមុនថាគ្មានទោសរបស់លោក អៀង សារី។ លក្ខណៈវិនិច្ឆ័យទាំងនេះ ត្រូវបានគេមកពឹងអាស្រ័យ ដើម្បីធ្វើយុត្តិកម្មតម្រូវឲ្យបន្តការឃុំខ្លួនលោក អៀង សារី នៅពេលដែលគាត់មិនបានបង្កនូវ-- បង្កឡើយនូវកត្តាទាំងនេះ និងគាត់គ្មានអំណាចនឹងធ្វើអ្វីឡើយ ដើម្បីទប់ស្កាត់នូវការកកើតឡើងនូវកត្តាទាំងនេះ។

អាស្រ័យហេតុនេះ មូលដ្ឋានសម្រាប់ការឃុំខ្លួនត្រូវតែបានប្រើប្រាស់ប្រកបដោយការប្រុងប្រយ័ត្នជាសំខាន់បំផុត។ ទោះបីជាលោកប្រធាន លោក លោកស្រីចៅក្រម ពិចារណាថាទម្រង់នៃការឃុំខ្លួនមួយចំនួន គឺចាំបាច់ដើម្បីការពារគោលបំណងនានា ដូចដែលមានការកំណត់នៅក្នុងវិធាន ៦៣.៣ ដូចមេធាវីការពារបានគូសបញ្ជាក់ជាច្រើនដងរួចហើយ នោះគឺជាការឃុំខ្លួននៅផ្ទះ ដែលជាវិធានសមស្របបំផុត។ ការឃុំខ្លួននៅផ្ទះត្រូវបានអនុញ្ញាតដោយវិធានផ្ទៃក្នុង និងក្រមនីតិវិធីព្រហ្មទណ្ឌរបស់កម្ពុជា ដែលតុលាការនឹងចំណាយអស់តិចសម្រាប់ការឃុំខ្លួនបែបនេះ មិនសូវរំលោភលើសិទ្ធិក្នុងការមានសេរីភាពរបស់លោក អៀង សារី និងលើសន្តិសុខផ្ទាល់ខ្លួនរបស់បុគ្គលម្នាក់ ដែលមិនទាន់ត្រូវបានកាត់ឲ្យជាប់ទោសចំពោះបទឧក្រិដ្ឋណាមួយនៅឡើយ និងពិតជាបង្កើនឱកាសឲ្យលោក អៀង សារី អាចមានលទ្ធភាព ដើម្បីទទួលបានការជំនុំជម្រះក្តីដោយតុលាការនេះទៀតផង។ ក្នុងការប៉ាន់ប្រមាណមើលថា តើការឃុំខ្លួន គឺចាំបាច់ ឬយ៉ាងណា? នោះសហចៅក្រមស៊ើបអង្កេត មានកាតព្វកិច្ចបង្គាប់ឲ្យចេញនូវមធ្យោបាយដែលមានការរឹតត្បិតតិចតួច ដែលចាំបាច់ដើម្បីឲ្យបានការសម្រេចតាមគោលបំណង ដែលតម្រូវដោយវិធាន ៦៣.៣។ ហេតុដូច្នេះ ការឃុំខ្លួននៅផ្ទះ គឺជាមធ្យោបាយដែលមានការរឹតត្បិតតិចតួចបំផុត។

លោកប្រធាន លោក លោកស្រីចៅក្រម មុននឹងជូនតួនាទីបន្តដល់សហភាតារបស់ខ្ញុំ លោកកាណាវាស។ ខ្ញុំសូមលើកចំណុចមួយ និងទាញការចាប់អារម្មណ៍ពីតុលាការ ពីអង្គសវនាការ និងក៏ដូចជាពីសាធារណជនផង ថាគោលបំណងទូទៅរបស់អ្នកតាក់តែងច្បាប់ របស់ពលរដ្ឋកម្ពុជា ដូចជាសហគមន៍អន្តរជាតិផងដែរ ចង់ឃើញតួនាទីនៃតុលាការនេះជាគំរូសម្រាប់តុលាការផ្សេងទៀត។ ជាពិសេសតុលាការក្នុងស្រុក ក៏ប៉ុន្តែបើយើងពិនិត្យមើលថា ទាក់ទងនឹងការរឹតត្បិតសិទ្ធិសេរីភាព សិទ្ធិក្នុងការមានសេរីភាពរបស់លោក អៀង សារី តើតុលាការយើងបានកំណត់អ្វីជាគំរូសម្រាប់តុលាការផ្សេងទៀតហើយឬនៅ? សូមពិនិត្យថា នៅតុលាការព្រហ្មទណ្ឌអន្តរជាតិនានា ជាពិសេសនៅតុលាការព្រហ្មទណ្ឌនៃអតីតប្រទេសយូហ្គោស្លាវី តាមពិតមានជនត្រូវចោទ ឯកសារយើងមានដាក់ជូនតាំងពី

សវនាការលើកទីមួយមកម៉្លេះ នៅថ្ងៃទី៣ ខែមករា ឆ្នាំ២០០៨។ បញ្ជាក់ថា នៅតុលាការនោះមានជនត្រូវចោទច្រើនគួរសមដែរ ត្រូវបានតុលាការឲ្យនៅក្រៅឃុំបណ្តោះអាសន្ន មិនមែនដូចលក្ខណៈនៃការឃុំខ្លួនដូចយើងខ្ញុំសុំទេ។ មានច្រើន ខ្ញុំមិនសូមលើកទេ មានករណីខ្លះឲ្យនៅក្រៅឃុំហើយ យកមកឃុំវិញ អ្នកខ្លះឲ្យឃុំ ដាក់ឃុំហើយឲ្យនៅក្រៅឃុំវិញ មានផ្លាស់គ្នាអ៊ីចឹង ច្រើន។ ខ្ញុំមិនសូមលើកឈ្មោះក្នុងបញ្ជីដែលបានដាក់ជូនរួចមកហើយនោះទេ។ នេះទាក់ទងនឹងតុលាការអន្តរជាតិ ប្រហែលជាចំណុចនេះសហភាតារបស់ខ្ញុំ លោក កាណាវាស អាចបញ្ជាក់បន្ថែមទៀត។

[១១:០០:៥៤]

បើយើងក្រឡេក និងប្រៀបធៀបទៅមើលតុលាការក្នុងស្រុកវិញ រឿងក្តីដែលលេចធ្លោមួយជាងគេ ខ្ញុំក៏អាចថាជាងគេទៅចុះ នៅក្នុងប្រទេសកម្ពុជា គឺរឿងឧក្រិដ្ឋកម្មមនុស្សឃាតទៅលើមេដឹកនាំសហជីពសេរីកម្មករ លោក ជា វិជ្ជា។ សាលាដំបូង សាលាឧទ្ធរណ៍បានសម្រេចបន្តការឃុំខ្លួន ក៏ប៉ុន្តែចុងក្រោយបំផុត តុលាការកំពូលបានសម្រេចឲ្យជនត្រូវចោទ ប៊ន សំណាង និង សុខ សំអឿន នៅក្រៅឃុំបណ្តោះអាសន្ន ចុះតុលាការយើងនេះមានអីទាក់ទងរឿងការកម្រិតសិទ្ធិសេរីភាពរបស់ជនត្រូវចោទនឹងប្រសើរជាងតុលាការអន្តរជាតិនានា និងតុលាការក្នុងស្រុកហើយឬនៅ?

ខ្ញុំសូមសន្និដ្ឋានថា នៅ។ មិនទាន់បាន។ អ៊ីចឹងទីនេះដូចខ្ញុំបានជម្រាបដដែលៗ ថាយើងមិនដែលបានសុំឲ្យលោក អៀង សារី នៅក្រៅឃុំបណ្តោះអាសន្ន ដូចករណីដែលបានលើកអម្បាញ់មិញទេ យើងគ្រាន់តែសូមប្តូរលក្ខខណ្ឌនៃការឃុំខ្លួនទេ ព្រោះយើងមានការព្រួយបារម្ភ ផ្ទុយពីការព្រួយបារម្ភរបស់សហព្រះរាជអាជ្ញា ឬក៏ការព្រួយបារម្ភរបស់ដើមបណ្តឹងរដ្ឋប្បវេណីថា លោក អៀង សារី មុនមកតុលាការនេះ សុខភាពគាត់ ទោះជាគាត់មានជំងឺធ្ងន់ធ្ងររ៉ាំរ៉ៃកន្លងមកហើយ ក៏ប៉ុន្តែនៅផ្ទះសុខភាពគាត់ប្រសើរជាងនេះឆ្ងាយណាស់ ជាងពេលគាត់មកនៅទីនេះឆ្ងាយណាស់។ បើចង់ប្រៀបធៀប សូមពិនិត្យមើលរបាយការណ៍ពេទ្យ ឬក៏ពិនិត្យមើលរូបភាពខាងក្រៅ ក៏យើងដឹងថា គាត់ចុះទម្ងន់ច្រើន។

អ៊ីចឹងយើងសុំឲ្យប្តូរលក្ខខណ្ឌនៃការឃុំខ្លួន យើងសុំអ្វីដែលតុលាការមិនពិបាកនឹងពិចារណាទេ គឺស្រាលបំផុត។ មិនមែនថា ពេលតុលាការឲ្យនៅក្រៅឃុំហើយ មិនមែនថាមិនអាចយកគាត់មកឃុំវិញបានទេ តុលាការគួរតែព្យាយាមប្រឹងប្រែងឲ្យអស់ពីលទ្ធភាពមើលថា គួរតែសាកល្បងឲ្យលោក អៀង សារី ឃុំខ្លួននៅផ្ទះ។ ទាក់ទងនឹងពាក្យ សុំថាសាកល្បងនេះ ប្រហែលជា សហព្រះរាជអាជ្ញា ឬដើមបណ្តឹងរដ្ឋប្បវេណីនឹងលើកឡើងថា តុលាការមិនមែនជាកន្លែងសាកល្បងទេ បើសិនជាលើកចំណុចនេះ

វិញ ខ្ញុំសូមជំទាស់។ អ្វីទាំងអស់ អ្វីក៏ដោយសុទ្ធតែមានការសាកល្បងជាបឋម និងសុទ្ធតែចេញពីលេខមួយ ចេញដំបូងទាំងអស់។ អ៊ីចឹងតុលាការអាចសាកល្បងឲ្យគាត់នៅឃុំមើល តើ-- ហើយចាំពិនិត្យមើល។ ដោយសារមានក្រុមសមត្ថកិច្ច មានប្រដាប់អាវុធ ឃុំគ្រងយាមកាមនៅទីនោះគត់មុតហើយមានអីកើតឡើងទៀត។ បើមានករណីសង្ស័យថា សមត្ថភាពផ្ទាល់របស់គាត់ អាចរងការគំរាមកំហែងហើយ អ៎គាត់ត្រៀមរៀបចំរត់គេចខ្លួនហើយ ហ៎! របបសាធារណៈត្រូវបានគំរាមកំហែង ឧទាហរណ៍។ តុលាការអាចចេញដីកានាំខ្លួនគាត់មកឃុំវិញបាន មិនមែនថាឲ្យចេញហើយ ចូលវិញមិនរួចទេ យើងសុំការសាកល្បងអ៊ីចឹង បើយើងចង់បាន ហើយថ្ងៃក្រោយតុលាការថា តុលាការអាចបញ្ជាក់ថា នែ៎! លោកមេធាវីយើងបានព្យាយាមតាមសំណើរសំណូមពររបស់លោកហើយ ក៏ប៉ុន្តែកាលៈទេសៈ ស្ថានការណ៍ពិត វាមិនតម្រូវឲ្យបន្តឃុំខ្លួនគាត់នៅផ្ទះបានទៀត អ៊ីចឹងតុលាការសម្រេចនាំគាត់មកឃុំនៅ អ.វ.ត.ក វិញ។

[១១:០៥:៣៦]

រយៈពេលសាកល្បង ខ្ញុំមិនទាមទារទេ អាចថារយៈពេលណាមួយដែលតុលាការយល់ឃើញថាសមគួរ នោះអាចឆ្លើយតបហើយ ថ្ងៃក្រោយតុលាការក្នុងស្រុកទាក់ទងនឹងការឃុំខ្លួនជនត្រូវនានា ទៅយកលើកអាហ្នឹងជាគំរូ ថានែ៎ គ្រាន់តែ អ.វ.ត.ក ជាតុលាការពិសេស តុលាការវិសាមញ្ញ ជនត្រូវក៏គេអនុញ្ញាតឲ្យនៅក្រៅឃុំបណ្ដោះអាសន្នដែរ ចុះតុលាការក្នុងស្រុក រឿងអីធ្វើតាមមិនបាន ប៉ុន្តែផ្ទុយទៅវិញតុលាការក្នុងស្រុកគេបានដើរទៅមុខធ្វើគំរូរួចទៅហើយ។

អ៊ីចឹង ខ្ញុំសូមមុននឹងបន្តកិច្ចនេះជូនដល់សហភាតារបស់ខ្ញុំ ខ្ញុំសុំតុលាការមេត្តាពិចារណាលើចំណុចនេះ ហេតុអីបានជាតុលាការយើងត្រូវតែខុសគេពីតុលាការជាតិ និងអន្តរជាតិនានាជាពិសេសទាក់ទងនឹងការរឹតត្បិតសិទ្ធិ និងការមានសេរីភាពរបស់ជនត្រូវចោទ។

សូមអរគុណ។

**ប្រធានអង្គបុរេ៖**

សូមអញ្ជើញលោកសហមេធាវីជនត្រូវចោទឡើងបន្តទៀត។

**លោក ម៉ៃខល កាណាវាស៖**

អរុណសួស្តីលោក លោកស្រីចៅក្រម អង្គសវនាការទាំងមូល និងសាធារណជននៅទីនេះ។ ខ្ញុំសូមបន្តចំណុចដែលសហសេវិករបស់ខ្ញុំបានបញ្ឈប់ការសន្និដ្ឋាននេះ។ យើងដឹងហើយសវនាការនេះ គឺ

ធ្វើយ៉ាងណា គឺយើងលើកកម្ពស់ទៅដល់ដើមបណ្តឹងរដ្ឋប្បវេណី ហើយនិងធ្វើការបំពេញទៅលើសង្គមស៊ីវិល ដែលមាននៅក្នុងប្រទេសកម្ពុជា។ ដូច្នេះហើយខ្ញុំដឹងហើយថា មិនមែនតែសហគមន៍អន្តរជាតិនោះទេ ទាំងជាតិផងដែរ កំពុងតែមើលថាតុលាការនេះនឹងក្លាយទៅជាតុលាការគំរូសម្រាប់ប្រទេសកម្ពុជា នៅក្នុងរឿងក្តីនានា។

ខ្ញុំចាប់ផ្តើមចំណុចនេះដោយសារតែអង្គសវនាការនេះគួរតែបញ្ជាក់ទៅលើចំណុចនេះ ហើយត្រូវយល់ឲ្យបានច្បាស់អំពីនីតិវិធីស្វែងរកយុត្តិធម៌ និងនីតិវិធីទាំងឡាយ ដែលរួមទាំងការចាប់ខ្លួន និងឃុំខ្លួនលោក អៀង សារី ផងដែរនោះ។ មុនពេលដែលខ្ញុំចូលទៅដល់សេចក្តីសន្និដ្ឋានរបស់ខ្ញុំមួយចំនួន ខ្ញុំនឹងលើកឡើងអំពីការដោះលែងបណ្តោះអាសន្ន ហើយខ្ញុំនឹងមិននិយាយនូវអ្វីដែលសហព្រះរាជអាជ្ញាគាត់បានដាក់ស្នើជូនកាលពីម្សិលមិញនោះទេ គឺខ្ញុំលើកនិយាយអំពីយុត្តិធម៌។ យើងដឹងហើយកាលពីសប្តាហ៍មុន គឺយើងមានការរវល់ទៅនឹងកិច្ចប្រជុំពេញអង្គ ហើយមានការទទួលតំណែងថ្មី ហើយខ្ញុំដឹងហើយគាត់មានការរវល់ក្នុងការដាក់ឯកសារនោះឲ្យបានទាន់ពេល។ ហើយយើងដឹងហើយឯកសារនេះ គឺចុះឆ្នាំ២០០៩ គឺបានដាក់មុនសវនាការ ហើយមានភាពសង្ស័យ ខ្ញុំមានភាពសង្ស័យទៅលើឯកសារនេះ។ ដូច្នេះអ្វីដែលសហព្រះរាជអាជ្ញាបានធ្វើឡើងនេះ គឺជាតាក់ទិករបស់សហព្រះរាជអាជ្ញា ហើយមិនបានដាក់ជូនអង្គបុរេជំនុំជម្រះ និងភាគីឲ្យបានដឹងទៅលើឯកសារនេះ ឲ្យបានលឿនជាងពេលនេះ។

ដូច្នេះហើយខ្ញុំសូមលើកឡើងថា បញ្ហានេះ គឺគ្រាន់តែជាការចង់ដាក់ឯកសារចូលតាមតាក់ទិករបស់គាត់ ហើយខ្ញុំសង្ឃឹមថា នៅពេលដែល-- នៅថ្ងៃអនាគត គឺសហព្រះរាជអាជ្ញានឹងចៀសវាងតាក់ទិកបែបនេះដើម្បីឲ្យការអនុវត្តសិទ្ធិឲ្យបានរឹងប៉ឹង ដើម្បីឲ្យខ្ញុំអាចឆ្លើយតបទៅនឹងឯកសារនោះបាន។ ដូច្នេះ យើងធ្វើអ្វីឲ្យមានភាពច្បាស់លាស់ មិនមែនជាតាក់ទិកនៅក្នុងការអនុវត្តនីតិវិធីរបស់យើងនោះទេ។

ខ្ញុំចូលទៅដល់នីតិវិធីក្នុងការស្វែងរកយុត្តិធម៌របស់យើង នៅក្នុងការសង្ខេបរបាយការណ៍របស់ចៅក្រម គឺបានលើកឡើងផងដែរថា យើងបានលើកឡើងអំពីភ័ស្តុតាងដោះបន្ទុក និងការខ្វះការយកចិត្តទុកដាក់ពីការិយាល័យសហចៅក្រមស៊ើបអង្កេត។ ចំណុចនេះហើយដែលយើងបានលើកឡើង និងខ្ញុំសូមសន្និដ្ឋានថា វាមិនមែនជាការពាក់ព័ន្ធទេ ដែលលើកឡើងដូច្នោះ។

លោក អៀង សារី នៅក្នុងប្រទេសកម្ពុជា ក្រោយពីគាត់ទទួលបានការលើកលែងទោស ហើយគាត់នៅតែនៅក្នុងប្រទេសកម្ពុជា ហើយគាត់មានមុខនៅក្នុងទីសាធារណៈ ហើយខ្ញុំដឹងថា តុលាការ

ក្រោយមក គឺបានបង្កើត ហើយក៏មិនមានភ័ស្តុតាងណាមួយបង្ហាញអំពីការគំរាមកំហែងទៅលើសាធារណជន ឬរបៀបរៀបរយ ហើយគាត់នឹងរត់គេចខ្លួន ឬក៏គាត់នឹងលាក់ខ្លួននោះទេ។

[១១:១០:៣៦]

លោក អៀង សារីត្រូវបានចាប់ខ្លួន ហើយចាប់មកទីនេះ។ ដូច្នេះ យើងត្រូវគិតទៅលើការធ្វើសេចក្ដីសម្រេចនេះ។ យើងដឹងហើយថា តុលាការនេះមានអំណាចក្នុងការស៊ើបអង្កេត ហើយការស៊ើបអង្កេតនោះ គឺធ្វើឡើងដោយហ្មត់ចត់ និងត្រឹមត្រូវ ហើយខ្ញុំលើកឡើងបញ្ហានេះកាលពីរបីឆ្នាំមុន ដែលយើងលើកហេតុផលថា នៅក្នុងការិយាល័យចៅក្រមស៊ើបអង្កេត យើងមានធាតុមួយចំនួន ភ័ស្តុតាងមួយចំនួន ដែលគេត្រូវបានស្វែងរក ប៉ុន្តែមិនមានការលើកឡើងស្វែងរកភ័ស្តុតាងទាំងអស់នោះ ដោយភាពត្រឹមត្រូវ ដូចដែលមន្ត្រីច្បាប់គាត់បានលើកឡើងអំពីករណីទាំងអស់នេះ។ មុនពេលដែលបង្កើតតុលាការនេះ យើងត្រូវគិតពិចារណាអំពីការលើកលែងទោសផងដែរ ហើយវាមានភាពស្រពិចស្រពិលទាក់ទងទៅនឹងការស៊ើបអង្កេតទាំងអស់នេះ។ យើងក៏បានលើកឡើងទាក់ទងទៅនឹងលើក ឡឺម៉ុងដ៍ ទាក់ទងករណីលោក ឡឺម៉ុងដ៍ ដែលគាត់បានគេចោទប្រកាន់ថា ចង់ឲ្យរកភ័ស្តុតាងដាក់បន្ទុក ហើយលោកចៅក្រម ឡឺម៉ុងដ៍ គឺគាត់បានបដិសេធចោលទៅលើចំណុចទាំងអស់នេះ គាត់មិនមែនលើកឡើងដូច្នេះជាក់លាក់នោះទេ គាត់គ្រាន់ចង្អុលបញ្ជាក់។ ដូច្នេះ យើងគ្រាន់តែចង់ឲ្យមានវត្តមានបង្ហាញអំពីករណីទាំងអស់នេះដែលយើងលើកឡើងចង់ឲ្យមានសវនាការទៅលើករណីទាំងអស់នោះ ហើយវាពាក់ព័ន្ធទៅនឹងបញ្ហានៃការរកភ័ស្តុតាងដោះបន្ទុក ហើយរឿងក្ដីរបស់សហព្រះរាជអាជ្ញាវាមិនមានភាពរឹងមាំ ប្រសិនបើមិនដូច្នោះនោះទេ។ ហើយដូច្នេះហើយហេតុផលទាំងអស់នេះហើយ សហចៅក្រមស៊ើបអង្កេតមិនមានការអនុវត្តកិច្ចរបស់ខ្លួនឲ្យមានការប្រុងប្រយ័ត្ន ហើយដូច្នេះយើងត្រូវមើលទៅទិដ្ឋភាពទាំងអស់នេះនៅក្នុងការចោទប្រកាន់។

ដូច្នេះយើងត្រូវបង្ហាញរឿងក្ដីនេះយ៉ាងម៉េច នៅពេលដែលវាមិនមានភ័ស្តុតាងរឹងមាំ ដែលសហចៅក្រមស៊ើបអង្កេត យើងដឹងហើយថាគាត់មិនមានការអនុវត្តត្រឹមត្រូវនៅក្នុងការស៊ើបអង្កេត។ ហើយពេលខ្លះទៅយើងដឹងថា សហចៅក្រមស៊ើបអង្កេតដើរតួហាក់ដូចជា តួនាទីរបស់អយ្យការ ដែលគាត់ចង់ឲ្យរកភ័ស្តុតាងដាក់បន្ទុក។ យើងដឹងហើយថាសហព្រះរាជអាជ្ញា គឺគាត់ធ្វើដីកាសន្និដ្ឋានបញ្ជូនឲ្យស៊ើបសួរ ហើយគាត់បញ្ជូនរឿងនោះទៅកាន់ការិយាល័យសហចៅក្រមស៊ើបអង្កេត។

[១១:១៣:០៧]

ដូច្នេះប្រសិនបើចៅក្រមស៊ើបអង្កេត-- សហព្រះរាជអាជ្ញា គាត់ធ្វើការងារដូច្នោះ គឺវាមិនមានបញ្ហានោះទេ ប៉ុន្តែគាត់ធ្វើការងារផ្សេងទៅវិញ។ ដូច្នេះយើងឃើញអំពីការភាពអនិយតភាពទាំងអស់នេះ ហើយដែលវានាំឲ្យធ្វើការមិនរកភ័ស្តុតាងដោះបន្ទុក ហើយមិនមានការអនុវត្តកាតព្វកិច្ចរបស់ខ្លួនឲ្យបានត្រឹមត្រូវ។ ដូច្នេះ យើងដឹងហើយសហចៅក្រមស៊ើបអង្កេតត្រូវមានកាតព្វកិច្ចស៊ើបអង្កេតឲ្យបានត្រឹមត្រូវ ហើយយ៉ាងហោចណាស់នៅក្នុងដំណាក់ស៊ើបអង្កេតនោះត្រូវធ្វើយ៉ាងណាធ្វើឲ្យវិធានការនៃការឃុំខ្លួននេះមានលក្ខណៈធូរស្រាល។ ខ្ញុំកត់សម្គាល់ចំណុចនេះដោយសារតែនៅពេលអនាគត យើងនឹងទទួលបាន-- ការទទួលបាននូវសវនាការជាសាធារណៈ ដើម្បីឲ្យសាធារណជនយល់ថា មានអ្វីកើតឡើងនៅទីនេះ។ យើងមិនចង់ឲ្យគ្រាន់តែមានការចោទប្រកាន់ទៅលើការស៊ើបអង្កេតយ៉ាងម៉េចនោះទេ យើងចង់ឲ្យលើកឡើងផ្តល់ជូនដល់សាធារណជនឲ្យបានដឹង។ យើងដឹង ដើម្បីឲ្យគេយល់ថា ហេតុអ្វីបានជាកូនក្តីរបស់ខ្ញុំជាប់ឃុំ។

**ការរត់គេចខ្លួន**

ខ្ញុំលើកដោយសង្ខេប បុគ្គលទាំងឡាយដែលគាត់ឃើញលោក អៀង សារី ថ្ងៃនេះនៅព្រឹកមិញនេះ គឺគាត់ហាក់ដូចជាងោកនៅពេលដែលគាត់អង្គុយ ហើយយើងឃើញហើយ លោក អៀង សារី គាត់មានការលំបាកក្នុងការដើរ បើសិនមិនមានការជួយជ្រុមជ្រែងនោះទេ។ ដូច្នេះហើយវាមានលក្ខណៈខុសពីបុគ្គលដែលមានអាយុម្ភៃ-សាមសិបឆ្នាំ ដែលគាត់មានសុខភាពរឹងប៉ឹង។ ខ្ញុំបានកត់សម្គាល់មុនហ្នឹងហើយ គាត់ប្រហែលជារត់គេចខ្លួនតាំងពីមុននោះប្រសិនបើគាត់ចង់រត់ មុនពេលដែលតុលាការនេះបានបង្កើត។ ប៉ុន្តែគាត់មិនធ្វើដូច្នោះនោះទេ ហើយគាត់អនុញ្ញាតឲ្យសវនាការនេះ ឬការជំនុំជម្រះនេះបន្តទៅមុខ ហើយគាត់សុខចិត្តនៅមិនរត់គេចខ្លួន។

កាលពីប៉ុន្មានឆ្នាំមុន លោក អៀង សារី ត្រូវធ្វើដំណើរទៅកាន់មន្ទីរពេទ្យ នៅមន្ទីរពេទ្យខ្ញុំព្យាយាមទៅសួរសុខទុក្ខគាត់ ហើយខ្ញុំក៏មិនអាចចូលទៅជួបគាត់ ហេតុអ្វី? ដោយសារតែមានការអ្នកយាមដោយមានអាវុធការពារ ដែលគាត់រារាំងមេធាវីការពារក្តី សូម្បីតែសហចៅក្រមស៊ើបអង្កេតហ្នឹងគាត់បានផ្តល់ការបង្គាប់ណែនាំទៅដល់អ្នកយាមនៅមន្ទីរឃុំឃាំងក៏ដោយ ដែលថាយើងត្រូវជួបជាមួយនឹងកូនក្តី ប៉ុន្តែនៅមន្ទីរពេទ្យយើងមិនអាចចូលសួរសុខទុក្ខកូនក្តីរបស់ខ្ញុំ។ ហេតុអ្វីបានខ្ញុំលើកចំណុចនេះ យើងមានលទ្ធភាពធ្វើទៅបាន។ យើងអាចបញ្ជាឲ្យអ្នកយាម ធ្វើការយាម ហើយកុំឲ្យមានការចេញចូលពីបុគ្គលផ្សេង ដូច្នេះហើយយើងអាចធ្វើទៅបានតើ ដូចដែលខ្ញុំឃើញនៅមន្ទីរពេទ្យដូច្នោះដែរ។

[១១:១៦:២២]

ដូច្នេះហើយវាមិនមានអ្វី មាននៃការបែកបាក់នៅក្នុងសង្គមកម្ពុជានោះទេ ប្រសិនបើអនុញ្ញាតឲ្យគាត់ឃុំនៅក្នុងផ្ទះ បានន័យថា ការដាក់ឃុំនៅផ្ទះដោយមានអ្នកយាមនៅផ្ទះ។ ដូច្នេះហើយ គឺថាចំណុចនេះវាមិនមានអ្វីអាក្រក់នោះទេ ហើយនឹងមិនមានសង្គ្រាមស៊ីវិល ឬក៏មិនមានការចលាចលនោះទេ ហើយយើងដឹងហើយ យើងអាចធ្វើដូច្នេះទៅបាន។ យើងបានឃើញ យើងដឹងហើយកាលពីប៉ុន្មានថ្ងៃមុន សម្តេចនាយករដ្ឋមន្ត្រីបានទៅព្រំដែន ហើយកម្ពុជាត្រៀមខ្លួនប្រឈមជាមួយនឹងប្រទេសជិតខាង។ អ៊ីចឹងប្រទេសកម្ពុជា គឺអាចមានលទ្ធភាព សមត្ថភាពក្នុងការការពារដីរបស់ខ្លួនទៅនឹងប្រទេសជិតខាង។ ដូច្នេះប្រទេសនេះក៏អាចមានលទ្ធភាពក្នុងការដាក់ជនឲ្យនៅឃុំនៅផ្ទះ ដើម្បីឲ្យគាត់នោះអាចដើរនៅផ្ទះ ហើយអាចទៅបន្ទប់ទឹកអីផ្សេងក៏ធ្វើទៅបាននោះដែរ។ យើងដឹងហើយថា ការស៊ើបអង្កេតមានរយៈពេលយូរ ហើយយើងចង់ឲ្យការស៊ើបអង្កេតនេះឲ្យបានឆាប់តាមដែលអាចធ្វើទៅបាន យើងមិនចង់ឲ្យមានឆាប់ទេ ហើយក៏មិនចង់ឲ្យមានការផ្លាស់ប្តូរនោះដែរ។ ដោយសារតែបើសិនជាការស៊ើបអង្កេតមិនឲ្យមានភាពត្រឹមត្រូវនឹងយុត្តិធម៌នោះទេ វាមានបញ្ហា ដោយសារវាជាកាតព្វកិច្ចរបស់ចៅក្រមស៊ើបអង្កេត។ ដូច្នេះ ខ្ញុំនិយាយនេះក្នុងនាមភាគីទាំងពីរ ទាំងអន្តរជាតិ និងជាតិ គឺថាភាគីទាំងអស់ត្រូវមានកាតព្វកិច្ចបំពេញកិច្ចដូចគ្នា។ ដូច្នេះ ត្រូវរកភ័ស្តុតាងដោះបន្ទុកផងដែរ នៅពេលដែលយើងដាក់សំណើរឲ្យគេបង្ហាញអំពីគំរូនៃការរកភ័ស្តុតាងនោះ ថាតើគេធ្វើយ៉ាងម៉េច? តែសហចៅក្រមស៊ើបអង្កេតបានសម្រេច ហើយឆ្លើយតបថា កុំភ័យ យើងដឹងនូវអ្វីដែលយើងត្រូវធ្វើ ប៉ុន្តែឲ្យយើងត្រូវឲ្យមានភាពនិយតភាព ដោយសារតែពេលវេលានៅក្នុងសវនាការរបស់យើងនៃការជំនុំជម្រះ។ យើងត្រូវដឹងថា តើយើងត្រូវដាក់លក្ខខណ្ឌអ្វីខ្លះ ដើម្បីកុំឲ្យកើតមានផលប៉ះពាល់ទៅដល់លោក អៀង សារី និងទៅដល់អ្នកផ្សេង ដើម្បីឲ្យអ្នកទាំងអស់នេះចូលរួមនៅក្នុងសវនាការ។ ដូច្នេះ យើងអាចឲ្យគាត់ឃុំខ្លួននៅក្នុងផ្ទះបាន។

[១១:១៨:៥៧]

ខ្ញុំសូមសង្កត់ទៅលើចំណុច បញ្ជាក់ទៅលើចំណុចខ្ញុំម្តងទៀត ដែលសហសេវិករបស់ខ្ញុំបានលើកឡើងទាក់ទងទៅនឹងតុលាការព្រហ្មទណ្ឌអន្តរជាតិ។ ខ្ញុំនិយាយជាក់លាក់ទៅលើ អាយ.ស៊ី.ធី.វ៉ាយ។ ចំពោះជនជាប់ចោទនៅពេលនោះ ដែលស្ថិតនៅក្នុងដំណាក់កាលជំនុំជម្រះពាក់កណ្តាលទៅហើយ។ យើងមិនបានបញ្ជាក់ទេ ថាតើដំណាក់កាលណាវាអាចដំណាក់កាលចោទប្រកាន់ ឬក៏ដំណាក់កាលស៊ើប

អង្កេត។ នៅពេលដែលសាលាដំបូងគាត់បានពិភាក្សាទៅលើភ័ស្តុតាង គឺគេមានស្ថានភាពមួយចំនួន ហើយខ្ញុំបានធ្វើតំណាងទៅដល់កូនក្តីទាំងអស់នោះ នៅក្នុងដំណាក់កាលនុំងគេបានដោះលែងឲ្យមានសេរីភាពចាកចេញពីប្រទេសហុល្លង់ ទៅប្រទេសដើមរបស់គេបាន សម្រាប់រយៈពេលពីរអាទិត្យ ប្រាំថ្ងៃ ឬដប់ថ្ងៃ ដើម្បីទៅលេងមិត្តភក្តិ ឬក៏បងប្អូន ហើយត្រឡប់មកវិញ។

យើងមិននិយាយថា ចង់ឲ្យលោកអៀង សារី ចង់ទៅប្រទេសផ្សេងនោះទេ។ យើងចង់ឲ្យលោកអៀង សារី នៅកណ្តាលទីក្រុងភ្នំពេញ មានអ្នកយាម ហើយគាត់អាចមានលទ្ធភាពទៅមន្ទីរពេទ្យផងដែរ។ ដូច្នេះលក្ខខណ្ឌនេះអាចធ្វើទៅបាន។ ខ្ញុំជឿថា ខ្ញុំមិនចង់និយាយចំណុចផ្សេងទៀតទេ។ ខ្ញុំដឹងថា ខ្ញុំបានបញ្ជាក់ច្បាស់លាស់ហើយវាមានភាពពិស្តារ ហើយវាមានលក្ខណៈជាក់លាក់នៅពេលដែលខ្ញុំបង្ហាញនៅក្នុងសេចក្តីសន្និដ្ឋានរបស់ខ្ញុំ។ ដូច្នេះ ខ្ញុំសង្ឃឹមនិងចាំស្តាប់នូវសេចក្តីសន្និដ្ឋានរបស់ភាគី ហើយនិងខ្ញុំឆ្លើយតបទៅវិញ។

សូមថ្លែងអំណរគុណដល់ចៅក្រម និងអង្គសវនាការ ដែលអនុញ្ញាតឲ្យខ្ញុំថ្លែងសេចក្តីសន្និដ្ឋាន។

**លោក អាង ឧត្តម៖**

...បន្ទោរបង់ បាទ គាត់ត្រូវការបន្ទោរបង់ទាន។

[១១:២០:៤៥]

**ប្រធានអង្គបុរេ៖**

សម្រាកដប់នាទី។

*(សវនាការសម្រាករយៈពេល១០នាទី)*

**លោក ឈន ព្រលឹង៖**

សូមអញ្ជើញក្រោកឈរ! តុលាការ!

**លោក ឈន ព្រលឹង៖**

សូមអរគុណ។ តាមសំណើរបស់មេធាវីជនត្រូវចោទស្នើសុំដល់អង្គបុរេជំនុំជម្រះសម្រេចផ្អាករហូតដល់ម៉ោងមួយ។ ផ្អាកសម្រាកអាហារថ្ងៃត្រង់ និងម៉ោងមួយគត់ចាប់ផ្តើម ដោយយោងទៅមូលហេតុថា ជនត្រូវចោទអស់កម្លាំង និងដល់អាហារថ្ងៃត្រង់របស់គាត់។ អ៊ីចឹងអង្គជំនុំជម្រះសម្រេចថា ផ្អាករហូតដល់អាហារថ្ងៃត្រង់ និងម៉ោងមួយគត់ចាប់ផ្តើម។ សូមអរគុណ។

*[សវនាការសម្រាកពីម៉ោង១១:៣៦នាទី ដល់ម៉ោង ១៣:០១នាទី]*

**ប្រធានអង្គបុរេ៖**

សូមអញ្ជើញអង្គុយចុះ!

យើងបន្តនីតិវិធីរបស់យើងបន្តទៅទៀត។ ជាបន្តទៅសូមអញ្ជើញសហព្រះរាជអាជ្ញាធ្វើសេចក្តីសន្និដ្ឋានតបដោយមានរយៈមួយម៉ោង។ សូមអញ្ជើញ!

**លោក ច័ន្ទ តារាស្មី៖**

សូមគោរពលោកប្រធាន សូមគោរព លោក លោកស្រីចៅក្រមជាតិ និងអន្តរជាតិ។ សូមគោរពអង្គសវនាការទាំងមូល។ នៅថ្ងៃនេះ ក្នុងនាមសហព្រះរាជអាជ្ញា យើងសូមបង្ហាញនូវការយល់ឃើញ និងសេចក្តីសន្និដ្ឋានរបស់សហព្រះរាជអាជ្ញានៃ អ.វត.ត.ក ចំពោះបណ្តឹងឧទ្ធរណ៍របស់ជនត្រូវចោទ អៀង សារី ស្តីពីការបន្តថិរវេលានៃការឃុំខ្លួនបណ្តោះអាសន្នចំពោះជនត្រូវចោទរូបនេះ។ ខ្ញុំនឹងបកស្រាយខ្លឹមសារនៃសេចក្តីសន្និដ្ឋានពីចំណុចទីមួយដល់ចំណុចទី៨ រីឯចំណុចទី៩ដល់ចំណុចទី១៩ នឹងត្រូវបកស្រាយដោយសហការីរបស់ខ្ញុំ គឺលោក អានីស អះមេដ។

លោកប្រធានជាទីគោរព លោក លោកស្រីចៅក្រមជាតិ និងអន្តរជាតិជាទីគោរព។

នាពេលនេះខ្ញុំសូមបង្ហាញប្រវត្តិអង្គហេតុបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងការឃុំខ្លួនជនត្រូវចោទ អៀង សារី ដូចតទៅ៖

នៅថ្ងៃទី១៨ ខែកក្កដា ឆ្នាំ២០០៧ សហព្រះរាជអាជ្ញាបានសេចក្តីសន្និដ្ឋានបានចេញសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរ ដែលក្នុងនោះសហព្រះរាជអាជ្ញាបានបង្ហាញឈ្មោះជនត្រូវចោទ អៀង សារី និងជនសង្ស័យ៤នាក់ផ្សេងទៀតថាបានបទឧក្រិដ្ឋ ដែលស្ថិតនៅក្រោមយុត្តាធិការរបស់អង្គជំនុំជម្រះវិសាមញ្ញ។

នាថ្ងៃទី១៤ ខែវិច្ឆិកា ឆ្នាំ២០០៧ បន្ទាប់ពីមានការជជែកតទល់ សហចៅក្រមស៊ើបអង្កេតបានសម្រេចឲ្យមានការឃុំខ្លួនបណ្តោះអាសន្នជនត្រូវចោទ អៀង សារី ក្នុងថិរវេលាអតិបរិមាចំនួនមួយឆ្នាំ។

នាថ្ងៃទី១២ ខែធ្នូ ឆ្នាំ២០០៧ ជនត្រូវចោទ អៀង សារី បានធ្វើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាសម្រេចឃុំខ្លួនបណ្តោះអាសន្ន។ បន្ទាប់ថ្ងៃសវនាការដែលបានប្រព្រឹត្តឡើងនៅថ្ងៃទី៣០ ខែមិថុនា និងថ្ងៃទី១ ថ្ងៃទី២ និងថ្ងៃទី៣ ខែកក្កដា ឆ្នាំ២០០៨ អង្គបុរេជំនុំជម្រះបានយល់ស្របជាឯកច្ឆន្ទលើដីកាសម្រេចឃុំខ្លួនបណ្តោះអាសន្នរបស់សហចៅក្រមស៊ើបអង្កេត។

[១៣:០៤:៤៣]

នាថ្ងៃទី១៣ ខែតុលា ឆ្នាំ២០០៨ សហចៅក្រមស៊ើបអង្កេតបានជូនដំណឹងដល់ជនត្រូវចោទ និងមេធាវីរបស់ខ្លួនថា សហចៅក្រមស៊ើបអង្កេត គ្រោងនឹងធ្វើការបន្តថិរវេលានៃការឃុំខ្លួនជនត្រូវចោទ អៀង សារី ហើយថា ពួកគេមានថិរវេលា១៥ថ្ងៃ ដើម្បីធ្វើការកត់សម្គាល់ និងតវ៉ាចំពោះការសម្រេចនេះ។

បន្ទាប់មក នៅថ្ងៃទី២៨ ខែតុលា ឆ្នាំ២០០៨ ដោយសារតែមានមូលហេតុមិនពេញចិត្តចំពោះការគ្រោងនឹងការធ្វើការបន្តថិរវេលានៃការឃុំខ្លួនជនត្រូវចោទ អៀង សារី សហមេធាវីរបស់ជនត្រូវចោទ អៀង សារី បានដាក់នូវការកត់សម្គាល់របស់ខ្លួន ដោយទាមទារឲ្យសហចៅក្រមស៊ើបអង្កេតដោះលែងកូនក្តីរបស់ខ្លួនឲ្យមានសេរីភាព ឬធ្វើការជំនួសការឃុំខ្លួនដោយការឃុំខ្លួននៅក្នុងគេហដ្ឋានក្នុងលក្ខខណ្ឌដែលស្របទៅនឹងគោលបំណងនៃវិធាន៦៣ នៃវិធានផ្ទៃក្នុង។

នាថ្ងៃទី១០ ខែវិច្ឆិកា ឆ្នាំ២០០៨ សហចៅក្រមស៊ើបអង្កេតបានចេញដីកាសម្រេចបន្តរយៈពេលនៃការឃុំខ្លួនបណ្តោះអាសន្នជនត្រូវចោទ អៀង សារី ក្នុងរយៈពេលអតិបរមាចំនួន១ឆ្នាំបន្ថែមទៀតដោយអនុលោមតាមបទប្បញ្ញត្តិនៃវិធាន៦៣.៦(ក) នៃវិធានផ្ទៃក្នុង។

នាថ្ងៃទី២៦ ខែមិថុនា ឆ្នាំ២០០៩ អង្គបុរេជំនុំជម្រះបានយល់ស្របជាឯកច្ឆន្ទលើដីកាសម្រេចបន្តការឃុំខ្លួនបណ្តោះអាសន្នរបស់សហចៅក្រមស៊ើបអង្កេត។

ដោយឡែកនាថ្ងៃទី៥ ខែតុលា ឆ្នាំ២០០៩ សហចៅក្រមស៊ើបអង្កេតបានជូនដំណឹងដល់ជនត្រូវចោទ និងមេធាវីរបស់ខ្លួនថា សហចៅក្រមស៊ើបអង្កេតកំពុងពិចារណាពីការបន្តថិរវេលានៃការឃុំខ្លួនហើយពួកគេមានថិរវេលា១៥ថ្ងៃ ដើម្បីធ្វើការកត់សម្គាល់។

នាថ្ងៃទី២០ ខែតុលា ឆ្នាំ២០០៩ សហមេធាវីរបស់ជនត្រូវចោទ អៀង សារី បានដាក់ការកត់សម្គាល់របស់ខ្លួន។

នាថ្ងៃទី១០ ខែវិច្ឆិកា ឆ្នាំ២០០៩ សហចៅក្រមស៊ើបអង្កេតបានចេញដីកាសម្រេចបន្តរយៈពេលនៃការឃុំខ្លួនបណ្តោះអាសន្នជនត្រូវចោទ អៀង សារី ក្នុងរយៈពេលអតិបរមាចំនួនមួយឆ្នាំបន្ថែមទៀតដោយអនុលោកតាមបទប្បញ្ញត្តិនៃវិធាន៦៣.៦(ក) នៃវិធានផ្ទៃក្នុង។ ដោយការមិនពេញចិត្តចំពោះការបន្តការឃុំខ្លួនបណ្តោះអាសន្នមួយឆ្នាំបន្ថែមទៀតលើជនត្រូវចោទ អៀង សារី ដោយសម្រេច ដោយសហចៅក្រមស៊ើបអង្កេតកាលពីថ្ងៃទី១០ ខែវិច្ឆិកា ឆ្នាំ២០០៩ នេះ សហមេធាវីរបស់ជនត្រូវចោទបានធ្វើការដាក់បណ្តឹងឧទ្ធរណ៍ អៀង សារី ប្រឆាំងនឹងដីកាសម្រេចបន្តថិរវេលានៃការឃុំខ្លួនបណ្តោះ

អាសន្នទៅអង្គបុរេជំនុំជម្រះកាលពីថ្ងៃទី៧ ខែធ្នូ ឆ្នាំ២០០៩។

[១៣:០៨:១៨]

នាថ្ងៃ១៦ ខែធ្នូ ឆ្នាំ ២០០៩ ក្រុមមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណីបានដាក់ចម្លើយតបរបស់សហមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណីទៅនឹងបណ្តឹងឧទ្ធរណ៍របស់ជនត្រូវចោទ អៀង សារី ប្រឆាំងនឹងការបន្តថិរវេលានៃការឃុំខ្លួនបណ្តោះអាសន្ន ដោយស្នើសុំឲ្យអង្គបុរេជំនុំជម្រះបដិសេធចោលនូវបណ្តឹងឧទ្ធរណ៍របស់សហមេធាវីការពារក្តីរបស់ជនត្រូវចោទ អៀង សារី និងបានសន្និដ្ឋានថា ដីកាបន្តថិរវេលានៃការឃុំខ្លួនរបស់ចៅក្រមស៊ើបអង្កេតមានហេតុផលសមរម្យនិងត្រឹមត្រូវ ហើយសហចៅក្រមស៊ើបអង្កេតបានអនុវត្តឆន្ទានុសិទ្ធិរបស់ខ្លួនបានត្រឹមត្រូវទៀតផង។ នៅក្នុងគោលបំណងដ៏ចម្បងគឺរារាំងកុំឲ្យជនត្រូវចោទកៀបសង្កត់ទៅលើសាក្សី ឬជនរងគ្រោះ ធានាវត្តមានរបស់ជនត្រូវចោទនៅក្នុងដំណាក់កាលនៃនីតិវិធី ការពារសន្តិសុខជនត្រូវចោទ និងរក្សាសណ្តាប់ធ្នាប់សាធារណៈ។

នាថ្ងៃទី១៧ ខែធ្នូ ឆ្នាំ២០០៩ សហព្រះរាជអាជ្ញាបានដាក់ចម្លើយតបរបស់ខ្លួនទៅនឹងបណ្តឹងឧទ្ធរណ៍របស់ អៀង សារី ស្តីពីការបន្តថិរវេលានៃការឃុំខ្លួនបណ្តោះអាសន្នទៅអង្គបុរេជំនុំជម្រះ ដោយនៅក្នុងនោះសហព្រះរាជអាជ្ញាបានស្នើសុំឲ្យបដិសេធបណ្តឹងឧទ្ធរណ៍របស់ជនត្រូវចោទ អៀង សារី ចោលទាំងស្រុង។

អង្គសវនាការជាទីគោរព, ជនត្រូវចោទ អៀង សារី បានដាក់បណ្តឹងឧទ្ធរណ៍មួយដោយស្វែងរកឲ្យមានការផ្លាស់ប្តូរនូវដីកាសម្រេចរបស់សហចៅក្រមស៊ើបអង្កេត ដែលបន្តថិរវេលានៃការឃុំខ្លួនបណ្តោះអាសន្នលើរូបគាត់សម្រាប់រយៈពេលបន្ថែមមិនឲ្យលើសពីមួយឆ្នាំ។ គាត់អះអាងថា សិទ្ធិរបស់គាត់ក្នុងការទទួលបានសេរីភាពនិងសច្ចធារណ៍នៃទោស ត្រូវបានរំលោភតាមរយៈការបន្តថិរវេលានៃការឃុំខ្លួន។ ដោយហេតុថា លក្ខខណ្ឌដែលតម្រូវឲ្យមានសម្រាប់ការឃុំខ្លួនគាត់ ដូចមានចែងក្នុងវិធាន៦៣ ចំណុច៣ នៃវិធានផ្ទៃក្នុង មិនបានបំពេញឡើយ។ សហចៅក្រមស៊ើបអង្កេត បានរំលោភលើឆន្ទានុសិទ្ធិរបស់ខ្លួន ក្នុងការខកខានមិនបានពិចារណាលើវិធានផ្សេងពីនេះ ដែលមានលក្ខណៈស្រាលជាងការឃុំខ្លួនដែលអាចយកមកប្រើ ដើម្បីធានាថាដើមបណ្តឹងនឹងមានវត្តមាននៅពេលកាត់សេចក្តីដោយមិនមានហានិភ័យដល់សន្តិសុខផ្ទាល់ខ្លួនរបស់គាត់ ឬការរំខានដល់សណ្តាប់ធ្នាប់សាធារណៈផងដែរ។

[១៣:១១:១៣]

ចំពោះការអះអាងខាងលើរបស់ជនត្រូវចោទ អៀង សារី សហព្រះរាជអាជ្ញាស្នើឲ្យអង្គបុរេជំនុំ

ជម្រះច្រានចោលបណ្តឹងឧទ្ធរណ៍នេះ ដោយសារមូលហេតុខាងក្រោមនេះ នៅក្នុងចំណោមទឡ្ហីករណ៍ផ្សេងៗទៀតដូចតទៅ៖

ដើមបណ្តឹងឧទ្ធរណ៍ខកខានមិនបានបង្ហាញឲ្យឃើញ អំពីការផ្លាស់ប្តូរកាលៈទេសៈជាក់ស្តែងណាមួយតាំងពីដើមដំបូងនៃការឃុំខ្លួនរូបគាត់ ដោយចៅក្រមស៊ើបអង្កេតនៅថ្ងៃទី១៤ ខែវិច្ឆិកា ឆ្នាំ២០០៧ ជាពិសេស គាត់មិនបានបង្ហាញអំពីការផ្លាស់ប្តូរកាលៈទេសៈជាក់ស្តែងណាមួយឡើយ តាំងពីមានការបញ្ជាក់ការអះអាងអំពីការឃុំខ្លួនបណ្តោះអាសន្នលើរូបគាត់ ដោយអង្គបុរេជំនុំជម្រះនៃថ្ងៃទី១៧ ខែតុលា ឆ្នាំ២០០៨ មកម្ល៉េះ។ តាំងពីមានការបន្តថិរវេលានៃការឃុំខ្លួនបណ្តោះអាសន្នលើកទីមួយ ចុះថ្ងៃទី១១ ខែធ្នូ ឆ្នាំ២០០៨ ឬការកម្កល់ដីកាសម្រេចនោះដោយអង្គជំនុំជម្រះសាលាដំបូង ចុះថ្ងៃទី២៦ ខែមិថុនា ឆ្នាំ ២០០៩។ នៅក្នុងសាលដីកាលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាសម្រេចឃុំខ្លួនដើម ដែលបានវាយតម្លៃលើភ័ស្តុតាងទាំងអស់នៅលើសំណុំរឿងដែលមានបច្ចុប្បន្នភាពដល់ពេលសវនាការ អង្គបុរេជំនុំជម្រះបានកត់សម្គាល់ឃើញថា លក្ខខណ្ឌតម្រូវនៃវិធាន៦៣.៣(ក) និង៦៣.៣(ខ) ចំណុច៣ ដល់ចំណុចទី៥ត្រូវបានបំពេញរួចហើយ ហើយការឃុំខ្លួនបណ្តោះអាសន្ននៅតែជាវិធានការចាំបាច់ ដោយឈរលើទឡ្ហីករណ៍ដែលមានកំណត់ក្នុងសាលដីកាលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាសម្រេចឃុំខ្លួនដើមនេះ។

នៅក្នុងសាលដីកាលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងការបន្តថិរវេលាឃុំខ្លួនលើកទីមួយ អង្គបុរេជំនុំជម្រះបានកត់សម្គាល់ឃើញថា នៅពេលមានអត្ថិភាពនៃមូលហេតុដែលត្រូវបានរកឃើញ និងជឿជាក់យ៉ាងច្បាស់រួចហើយថា លក្ខខណ្ឌនៃវិធាន៦៣.៣(ក) នៅក្នុងដំណាក់ការនៃដំណើរការនីតិវិធីមុនពេលជំនុំជម្រះនៅតែត្រូវបានបំពេញ វាលែងតែមានភ័ស្តុតាងដោះបន្ទុកត្រូវបានរកឃើញផ្សេងពីនេះទៅវិញ។

[១៣:១៤:០០]

សព្វថ្ងៃនេះ សំណុំរឿងមានបន្ទុកភ័ស្តុតាងដែលមានលទ្ធភាពបំពេញបានសម្រាប់អ្នកអង្កេត-ការណ៍ឯករាជនៅក្នុងដំណាក់ការនៃកិច្ចស៊ើបសួរនេះ ដែលថា ដើមបណ្តឹងឧទ្ធរណ៍អាចប្រព្រឹត្តឧក្រិដ្ឋកម្មនានាដែលគាត់បាន និងកំពុងស្ថិតនៅក្រោមកិច្ចស៊ើបសួរ គឺពុំមានភ័ស្តុតាងដោះបន្ទុកជាក់ស្តែង ត្រូវបានរកឃើញដើម្បីរំលាយចោលនូវភ័ស្តុតាងនេះទេ។ កំហុសនៅក្នុងកិច្ចស៊ើបសួរដែលមេធាវីការពារក្តីបានតវ៉ាថា ជាឧបសគ្គដល់ការវាយតម្លៃអំពីអត្ថិភាពនៃមូលហេតុនៃការឃុំខ្លួន គឺគ្រាន់តែជាភ័ស្តុតាងដែលបានអះអាងដោយមេធាវីការពារក្តី ដែលតវ៉ាចំពោះប្រតិបត្តិការនៃការិយាល័យសហចៅក្រមស៊ើបអង្កេតតែប៉ុណ្ណោះ។ ដែលក្នុងចំណោមភ័ស្តុតាងទាំងនោះ គ្មានភ័ស្តុតាងណាមួយត្រូវបានអង្គបុរេជំនុំ

ជម្រះរកឃើញថា មានសុពលភាពនោះឡើយ។

ជាការបន្ថែម លក្ខខណ្ឌបីក្នុងចំណោមលក្ខខណ្ឌដាច់ៗពីគ្នាទាំងប្រាំ ដែលមានចែងក្នុងវិធាន ៦៣.៣(ខ) នៃវិធានក្នុងនៅតែបំពេញដដែល។ អាស្រ័យហេតុនេះ ការចេញដីកាសម្រេចឃុំខ្លួនបណ្តោះអាសន្ន ជាវិធានការចាំបាច់តែមួយគត់ ជាពិសេសការឃុំខ្លួនបណ្តោះអាសន្នលើដើមបណ្តឹងឧទ្ធរណ៍ គឺជាការចាំបាច់ ព្រោះមានមូលហេតុដ៏ចាំបាច់មួយចំនួនដូចខាងក្រោម៖

ទីមួយ គឺដើម្បីធានាវត្តមានរបស់គាត់ក្នុងអំឡុងពេលនៃកិច្ចដំណើរការនីតិវិធី។ ទីពីរ ដើម្បីការពារសន្តិសុខរបស់គាត់។ ទីបី ដើម្បីថែរក្សាសណ្តាប់ធ្នាប់សាធារណៈ។

អង្គបុរេជំនុំជម្រះសាលាដំបូងបានសង្កេតឃើញថា ការឃុំខ្លួនក្នុងផ្ទះ ឬសូម្បីតែឃុំខ្លួននៅមន្ទីរពេទ្យក៏ដោយសម្រាប់ដើមបណ្តឹងឧទ្ធរណ៍រូបនេះ គឺមិនត្រូវបានអនុញ្ញាតឡើយ ដោយសារមិនមានការផ្លាស់ប្តូរកាលៈទេសៈជាក់ស្តែងណាមួយ ដើម្បីយកធ្វើជាអង្គសេចក្តីសម្រាប់ធ្វើការផ្លាស់ប្តូរការសម្រេចនេះបានទេ។ មន្ទីរឃុំឃាំង អ.វ.ត.ក នៅតែជាកន្លែងដែលមានការបំពាក់សម្ភារៈឧបករណ៍ដ៏សមស្របសម្រាប់ការឃុំខ្លួនជនត្រូវចោទ អៀង សារី បន្តទៅទៀត។

គោលការណ៍ច្បាប់ស្តីពីលក្ខខណ្ឌចាំបាច់សម្រាប់ការឃុំខ្លួន៖

ផ្អែកតាមវិធាន ៦៣.៣ សហចៅក្រមស៊ើបអង្កេតអាចសម្រេចឃុំខ្លួនបណ្តោះអាសន្នបាន ប្រសិនបើមានមូលហេតុដែលត្រូវរកឃើញនិងជឿជាក់យ៉ាងច្បាស់ថា ជនត្រូវចោទអាចប្រព្រឹត្តបទឧក្រិដ្ឋដែលបានចែងនៅក្នុងដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរ។ សហចៅក្រមស៊ើបអង្កេតពិចារណាថា ការឃុំខ្លួនបណ្តោះអាសន្ន គឺជាវិធានការចាំបាច់ដើម្បី៖

១) រារាំងកុំឲ្យជនដែលត្រូវចោទនោះគៀបសង្កត់ទៅលើសាក្សី ឬជនរងគ្រោះ ឬរារាំងកុំឲ្យមានការត្រូវរ៉ូវគ្នារវាងជនត្រូវចោទ និងអ្នកសមគំនិត។ ថែរក្សាភ័ស្តុតាង ឬការពារមិនឲ្យបំផ្លាញភ័ស្តុតាង។ ធានាអំពីវត្តមានរបស់ជនត្រូវចោទនៅក្នុងដំណើរការនៃនីតិវិធី។ ការពារសន្តិសុខឲ្យជនដែលត្រូវចោទ។ រក្សាសណ្តាប់ធ្នាប់សាធារណៈ។

[១៣:១៨:១៣]

ទង្វើករណ៍ទាំងប្រាំ ដែលមានចែងនៅក្នុងវិធាន ៦៣.៣(ខ) នៃវិធានផ្ទៃក្នុងគឺដាច់ៗពីគ្នា ពុំមានលក្ខខណ្ឌតម្រូវណាមួយ ដែលថាសហចៅក្រមស៊ើបអង្កេត ត្រូវតែរកឲ្យឃើញថា គ្រប់ទង្វើករណ៍ទាំងអស់ត្រូវបានបំពេញ មុននឹងពិចារណាអំពីការឃុំខ្លួនបណ្តោះអាសន្ន ដែលជាវិធានការចាំបាច់នោះទេ

ឬក៏ថា ការបន្តថិរវេលានៃការឃុំខ្លួនរបស់សហចៅក្រមស៊ើបអង្កេតត្រូវបានអនុញ្ញាតនោះទេ។ ផ្ទុយទៅមកវិញ ប្រសិនបើសហចៅក្រមស៊ើបអង្កេតពិចារណាថា មានទទ្បីករណ៍មួយក្នុងចំណោមទទ្បីករណ៍ទាំងប្រាំ នោះការសាកល្បងសម្រាប់ការឃុំខ្លួន គឺត្រូវបានបំពេញហើយ។

អភិក្រមនេះ ត្រូវបានអនុវត្តដោយបណ្ដាសាលាក្ដីព្រហ្មទណ្ឌដទៃទៀត ដែលធ្វើការដោះស្រាយចំពោះឧក្រិដ្ឋកម្មអន្តរជាតិធ្ងន់ធ្ងរស្រដៀងគ្នានេះ។ អាជ្ញាធរមួយរបស់តុលាការ អាចអនុវត្តឆន្ទានុសិទ្ធិក្នុងការកំណត់ថា តើការឃុំខ្លួនគឺជាវិធានការមួយដ៏ចាំបាច់ដែរឬទេ ឬមួយក៏ការបន្តថិរវេលានៃការឃុំខ្លួនត្រូវបានអនុញ្ញាតឆន្ទានុសិទ្ធិបែបនេះ តាមធម្មតាគឺត្រូវបានអនុវត្តដោយយកចិត្តទុកដាក់ទៅលើរាល់ឯកសារទាំងអស់នៅក្នុងសំណុំរឿង និងទៅលើរាល់អង្គហេតុដែលពាក់ព័ន្ធទាំងអស់នៃករណីរឿង ដែលនៅក្នុងនោះរាប់បញ្ចូលទាំងឋានទម្ងន់នៃបទចោទប្រកាន់ ភាពសមហេតុសមផលនៃភ័ស្តុតាង អត្តចរិតនិងអាកប្បកិរិយាកន្លងមក និងបច្ចុប្បន្នភាពរបស់ជនចុងចោទផងដែរ។ ផលប្រយោជន៍របស់សាក្សី និងជនរងគ្រោះនានា ព្រមទាំងផលប្រយោជន៍នៃយុត្តិធម៌ទាំងមូលផងដែរ ដែលគេត្រូវពិចារណាគិតគូរឲ្យបានយ៉ាងយកចិត្តទុកដាក់ជាទីបំផុត។ នេះគឺជាការស្របទៅតាមទម្លាប់អនុវត្តនៅក្នុងតុលាការអន្តរជាតិនានា ដែលតុលាការនេះបានអនុវត្តយកតាមនាពេលកន្លងមក។

ចំពោះការបន្តថិរវេលានៃការឃុំខ្លួន យោងតាមវិធាន ៦៣.៦ នៃវិធានផ្ទៃក្នុងដែលបានចែងអំពីការពិនិត្យជាថ្មីឡើងវិញ ជាស្វ័យប្រវត្តិមួយតាមការកំណត់អំពីការឃុំខ្លួនរបស់ជនត្រូវចោទ បញ្ញត្តិបែបនេះ គឺមិនឃើញមាននៅក្នុងឯកសារជាមូលដ្ឋានរបស់តុលាការព្រហ្មទណ្ឌអន្តរជាតិ សម្រាប់ប្រទេសយូហ្គោស្លាវី តុលាការព្រហ្មទណ្ឌអន្តរជាតិសម្រាប់ប្រទេស រ៉្វាន់ដា និងតុលាការពិសេសសម្រាប់ប្រទេសសេរ៉ាឡេអូននោះទេ។ ក៏ប៉ុន្តែ តុលាការទាំងនេះតម្រូវថា ដើម្បីឲ្យមានការធ្វើពាក្យសាជាថ្មីឡើងវិញក្នុងការសុំដោះលែងបានទទួលជោគជ័យនោះ ចុងចោទត្រូវតែបង្ហាញឲ្យឃើញថា មានការផ្លាស់ប្ដូរកាលៈទេសៈជាក់ស្ដែងណាមួយ ក៏ប៉ុន្តែស្រដៀងគ្នានឹងវិធានការរបស់តុលាការនេះ វិធាន១១៨ នៃវិធានស្ដីពីនីតិវិធីនិងភ័ស្តុតាងរបស់តុលាការព្រហ្មទណ្ឌអន្តរជាតិ តម្រូវឲ្យអង្គបុរេជំនុំជម្រះត្រូវតែធ្វើការពិនិត្យសាជាថ្មីឡើងវិញរបស់ខ្លួន លើការឃុំខ្លួនបណ្ដោះអាសន្នរបស់ជនត្រូវចោទឲ្យបានយ៉ាងហោចណាស់ក៏នៅរៀងរាល់ ១២០ថ្ងៃម្ដងដែរ។

[១១:២២:២២]

អង្គបុរេជំនុំជម្រះរបស់តុលាការព្រហ្មទណ្ឌអន្តរជាតិមានកាតព្វកិច្ចឯករាជ្យ និងខុសពីគេមួយ

ក្នុងការធានាឲ្យប្រាកដថា មិនមានជនណាម្នាក់ត្រូវបានគេឃុំខ្លួនមុនពេលក្នុងរយៈពេលមួយ ដែលមិនសមហេតុសមផលនោះទេ។ អង្គបុរេជំនុំជម្រះអាចធ្វើការកែប្រែសេចក្ដីសម្រេចរបស់ខ្លួនស្ដីពីការឃុំខ្លួនបាន បើសិនជាមានការបង្ហាញគ្រប់គ្រាន់តាមលក្ខខណ្ឌថា ការផ្លាស់ប្ដូរខាងកាលៈទេសៈ តម្រូវឲ្យធ្វើយ៉ាងដូច្នេះ។ នៅឯតុលាការព្រហ្មទណ្ឌអន្តរជាតិ អយ្យការ គឺជាអ្នកត្រូវមានបន្ទុកក្នុងការបង្ហាញភ័ស្តុតាងទាក់ទងទៅនឹងអត្ថិភាព ដែលមានជាបន្តទៅទៀតនៃលក្ខខណ្ឌស្ដីពីការឃុំខ្លួនមុនពេលសវនាការ។ នៅឯតុលាការនេះ វិធានមិនបានតម្រូវឲ្យសហចៅក្រមស៊ើបអង្កេត ត្រូវស្ដាប់សហព្រះរាជអាជ្ញា ឬភាគីណាមួយផ្សេងទៀត លើកលែងតែជនត្រូវចោទ នៅពេលធ្វើការកំណត់អំពីការបន្តនៃការឃុំខ្លួន។

អត្ថិភាពនៃការពិនិត្យសាឡើងវិញជាថ្មី តាមការកំណត់ជាស្វ័យប្រវត្តិអំពីការឃុំខ្លួន គឺជាការផ្ដល់ដល់ជនត្រូវជាប់ឃុំនូវឱកាសដើម្បីលើកឡើងពីជំហររបស់ខ្លួន និងបើសិនជាត្រូវបានអនុញ្ញាតគឺក្នុងការអនុវត្តសិទ្ធិក្នុងការប្ដឹងឧទ្ធរណ៍របស់ខ្លួន។

លោកប្រធានជាទីគោរព លោក លោកស្រីចៅក្រមជាតិ និងអន្តរជាតិជាទីគោរព អង្គសវនាការទាំងមូលជាទីគោរព។ សហព្រះរាជអាជ្ញានៅតែយល់ឃើញថា ការឃុំខ្លួនបណ្ដោះអាសន្ន ចំពោះជនត្រូវចោទ អៀង សារី ជាបន្តទៀត គឺនៅតែជាជម្រើសដ៏ល្អបំផុតដូចដែលសហព្រះរាជអាជ្ញាបានស្នើសុំរួចហើយ ទៅសហចៅក្រមស៊ើបអង្កេត និងបានដាក់ចម្លើយតបរបស់សហព្រះរាជអាជ្ញាទៅអង្គបុរេជំនុំជម្រះរួចហើយ កាលពីថ្ងៃទី១៧ ខែធ្នូ ឆ្នាំ២០០៩ ព្រោះសហព្រះរាជអាជ្ញាមានមូលហេតុ និងយល់ឃើញថា ការឃុំខ្លួនបន្តចំពោះជនត្រូវចោទ គឺដើម្បីធានានូវចំណុចសំខាន់ៗដូចខាងក្រោម៖

ជនត្រូវចោទ មិនអាចគេចខ្លួនបានពីតុលាការ។

ជនត្រូវចោទមិនបានបង្ហាញភ័ស្តុតាងថ្មីណាមួយ ដើម្បីគាំទ្រដល់ការអះអាងរបស់ខ្លួនទេ គឺបានត្រឹមតែរំឭកឡើងវិញនិងគ្រាន់តែបានធ្វើការអត្ថាធិប្បាយបន្ថែមពីលើការកត់សម្គាល់របស់ខ្លួនតែប៉ុណ្ណោះ។

[១១:២៥:៣២]

ការឃុំខ្លួនបណ្ដោះអាសន្ន ចំពោះជនត្រូវចោទគឺជាការចាំបាច់ណាស់ ព្រោះអង្គហេតុនិងអង្គច្បាប់នៃរឿងក្ដីនេះមានភាពស្មុគស្មាញខ្លាំង និងមានការលំបាកដល់អាជ្ញាធរតុលាការ និងឥរិយាបថរបស់ភាគីដែលពាក់ព័ន្ធទៀតផង។ ម្យ៉ាងទៀត ការឃុំខ្លួន គឺដើម្បីបញ្ចៀសរាល់អំពើសងសឹកពីសំណាក់ជនរងគ្រោះ និងដើម្បីជៀសវាងការដាក់សម្ពាធទៅលើសាក្សី និងជនរងគ្រោះ។

ការឃុំខ្លួនមានប្រយោជន៍ ពីព្រោះអង្គហេតុទាំងនេះ មានលក្ខណៈធ្ងន់ធ្ងរទោះបីជាមានរយៈពេល

សាមសិបឆ្នាំក្រោយពេលបទឧក្រិដ្ឋបានកើតឡើងក៏ដោយ ក៏នៅតែបង្កជាបញ្ហាធ្ងន់ធ្ងរដល់សណ្តាប់ធ្នាប់សាធារណៈដដែល។

លោកចៅក្រមជាទីគោរព អង្គសវនាការទាំងមូលជាទីគោរព, ជាកិច្ចបន្តទៀត ខ្ញុំស្នើសុំឲ្យអង្គបុរេជំនុំជម្រះអនុញ្ញាតឲ្យលោក អានីស អះមេដ ឡើងបកស្រាយបន្តចំពោះចំណុចសំខាន់ៗជាបន្តទៅទៀត។ សូមអរគុណ។

**ប្រធានអង្គបុរេ៖**

សូមអញ្ជើញលោកសហព្រះរាជអាជ្ញាអន្តរជាតិឡើងធ្វើសេចក្តីសន្និដ្ឋានជាបន្តទៀត។

**លោក អានីស អះមេដ៖**

សូមអរគុណអង្គបុរេជំនុំជម្រះ ដោយហេតុថាសហសេវិករបស់ខ្ញុំបានផ្តល់សេចក្តីពន្យល់ពីអង្គហេតុ និងអង្គច្បាប់នៃរឿងក្តីនេះ ខ្ញុំនឹងនិយាយដោយសង្ខេប ហើយខ្ញុំនឹងនិយាយដោយសង្ខេប ពីព្រោះមេធាវីការពារនោះក៏បាននិយាយសង្ខេបដែរ។ អ៊ីចឹងខ្ញុំនឹងឆ្លើយតបទៅនឹងចំណុចមួយចំនួនដែលមេធាវីការពារបានលើកឡើង។ ប៉ុន្តែ មុននឹងចូលទៅដល់ចំណុចទាំងអស់នោះ ខ្ញុំសូមអនុញ្ញាតដើម្បីធ្វើសេចក្តីសន្និដ្ឋានដោយសង្ខេបជូនអង្គបុរេជំនុំជម្រះ។

ដោយសេចក្តីគោរពខ្ពស់បំផុតនៅពេលនេះ ថ្ងៃនេះ អង្គបុរេជំនុំជម្រះដើម្បីពិចារណាអំពីបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងការបន្តថិរវេលាការឃុំខ្លួន មិនមែនដើម្បីពិចារណាបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងការឃាត់ខ្លួន ឬក៏ការឃុំឃាំងតាំងពីខែកញ្ញា ឆ្នាំ២០០៧ នោះទេ។ ការឃុំខ្លួននៅពេលនោះ គឺត្រូវបានតម្កល់នៅក្នុងខែតុលា ឆ្នាំ២០០៨ រួចហើយ។

[១១:២៨:១៣]

ក៏ប៉ុន្តែ នៅក្នុងការបន្តថិរវេលាក៏បានតម្កល់នៅក្នុងអង្គបុរេជំនុំជម្រះនៅថ្ងៃទី២៦ មិថុនា ឆ្នាំ២០០៩ ដែរ។ បញ្ហាថ្ងៃនេះ នៅថ្ងៃនេះ ថាតើសហចៅក្រមស៊ើបអង្កេតបានបន្តថិរវេលាឃុំខ្លួនបណ្តោះអាសន្ននេះត្រឹមត្រូវដែរឬអត់ ដែលចុះថ្ងៃទី១០ វិច្ឆិកា ឆ្នាំ២០០៩ នោះ? យើងយល់ថា មិនមានអ្វីនៅក្នុងឯកសារ ហើយមិនមានកាលៈទេសៈសំខាន់ណាដែលបញ្ជាក់ថា អង្គបុរេជំនុំជម្រះត្រូវពិចារណាឡើងវិញនូវសេចក្តីសម្រេច ២៦ មិថុនា ២០០៩ ឡើងវិញនោះទេ ដោយហេតុថាសហចៅក្រមស៊ើបអង្កេតមិនបានរកឃើញនៅមានភ័ស្តុតាង ឬកាលៈទេសៈអ្វីដើម្បីឲ្យផ្លាស់ប្តូរទស្សនៈនោះទេ ឬក៏ឲ្យងាកចេញពីមតិ ដើម្បីឲ្យសម្រេចខុសពីអង្គបុរេជំនុំជម្រះ ដែលថា បីខែមុននោះទេ គឺថ្ងៃទី២៦ មិថុនា ឆ្នាំ២០០៩។

ដូច្នេះ អ្វីដែលថា សហចៅក្រមស៊ើបអង្កេតធ្វើអ្វី គឺមិនរកឃើញពីកាលៈទេសៈកែប្រែនោះទេ។ ហើយមេធាវីការពារកាណាវាសនោះបានបញ្ជាក់នៅក្នុងពាក្យបណ្តឹងឧទ្ធរណ៍ថា គឺជំទាស់ទៅលើសេចក្តីសម្រេចដែលថា ខកខានមិនបានរកឃើញអំពីការកែប្រែកាលៈទេសៈសំខាន់ៗចាប់តាំងពីថ្ងៃទី២៦ ខែមិថុនា ដែលអង្គបុរេជំនុំជម្រះសម្រេចថា គម្បីតែបន្តនោះ។ ប៉ុន្តែ នៅចាប់ពីថ្ងៃនោះមក មូលហេតុដែលគួរឲ្យជឿជាក់បានថាជននេះបានប្រព្រឹត្តបទឧក្រិដ្ឋនោះគឺនៅតែមានដដែល។ តាមពិតក៏ក្លាយទៅជាភ័ស្តុតាងដ៏រឹងមាំ។ ជនត្រូវចោទនេះ គឺនៅថ្ងៃទី២៦ ខែធ្នូ ឆ្នាំ២០០៩ ត្រូវបានចោទបន្ថែមទៀតពីបទឧក្រិដ្ឋប្រល័យពូជសាសន៍ ហើយនិងបទឧក្រិដ្ឋជាតិមួយចំនួនតាមក្រមឆ្នាំ១៩៥៦ របស់កម្ពុជា។

ពីទម្រង់នៃការទទួលខុសត្រូវនៃសហកម្មឧក្រិដ្ឋកម្មរួមដែលយើងលើកឡើងនៅក្នុងបណ្តឹងឧទ្ធរណ៍ ប៉ុន្តែដល់ពេលនេះ គឺថាយើងបានរកឃើញថា អាចនឹងអនុវត្តបានទៅលើអង្គហេតុដែលទាក់ទងទៅនឹងជនត្រូវចោទរូបនេះ។ ការស៊ើបអង្កេតត្រូវបានបិទទៅហើយនៅថ្ងៃទី១៤ ខែមករា។

សហចៅក្រមស៊ើបអង្កេតនៅក្នុងសេចក្តីប្រកាសព័ត៌មានបានបញ្ជាក់ថា ជាផ្នែកនៃសំណុំរឿងដែរ ខ្ញុំមិនបាច់បញ្ជាក់ឡើងវិញទេ ថាមាន៧សាក្សី ចម្លើយសាក្សី៨00នាក់ នៅក្នុងការស៊ើបអង្កេត ហើយមានលិខិតចាត់ឲ្យសួរជំនួស៥00។ ដូច្នេះ គឺថាយើងបានពិនិត្យមើលពីរថ្ងៃកន្លងទៅហើយ គឺវាមាន៩៦ ឬក៏លើសពីហ្នឹង ដែលនិយាយជាក់លាក់អំពីតួនាទីរបស់ជនជាប់ចោទរូបនេះនៅក្នុងអំពើឧក្រិដ្ឋមួយចំនួន ដែលបានដាក់ជូននៅក្នុងដីកាបញ្ជូនរឿងទៅជម្រះ។

មូលដ្ឋានគួរឲ្យជឿជាក់បាននៅថ្ងៃ២៦ ខែមិថុនា ហើយក៏បន្តនៅមានរហូតមកដល់ថ្ងៃនេះ។ ហើយខ្ញុំសូមបញ្ជាក់ឡើងវិញប្រយោគមួយដែលមេធាវីការពារបានលើកឡើង នូវពីដីកាសម្រេចថ្ងៃ២៦ មិថុនា។ នៅពេលដែលមូលដ្ឋានគួរឲ្យជឿជាក់-- រកឃើញឲ្យជឿជាក់បាននោះ កាលនោះលើកលែងតែភ័ស្តុតាងដោះបន្ទុក ដែលថាដើម្បីយកកំណត់រំលាយភ័ស្តុតាងនោះទេ នោះវាមានលក្ខណៈតម្រូវនៃវិធាន៦៣.៣(ក) នៅក្នុងដំណាក់កាលមុនអង្គសេចក្តីនៃរឿងក្តី។

ឥឡូវនេះគឺយើងនៅក្នុងដំណាក់កាលនេះ ហើយការជំនុំជម្រះគឺថាអាចនឹងចាប់ផ្តើមក្នុងពីរ បីខែខាងមុខនេះ។ ហើយឬក៏ថា អាចនឹងត្រូវបញ្ជូនទៅជម្រះ ឬមិនបញ្ជូនទៅជម្រះ។ អ៊ីចឹងហើយ គឺនឹងមានភ័ស្តុតាងហ្នឹង គឺវាមានគ្រប់គ្រាន់នៅក្នុងសំណុំរឿង គឺតាមវិធាន៦៣.៣(ក) នោះឯង។

ចំណុចមួយទៀតដែលខ្ញុំនឹងលើកឡើងដែលទាក់ទងទៅនឹងទឡ្ហីករណ៍នៃបណ្តឹងឧទ្ធរណ៍ក្នុងពេលនេះ លោក លោកស្រីចៅក្រមនោះបានដឹងនៅក្នុងថ្ងៃទី២៦ មិថុនា ឆ្នាំ២០០៩ នោះបានបញ្ជាក់ថា មាន

លក្ខខណ្ឌបីនៃវិធាន៦៣.៣(ខ) បានបំពេញទាំងស្រុង។ ដើម្បីធានាវត្តមានរបស់ជនត្រូវចោទនៅក្នុងដំណើរការនីតិវិធី ដើម្បីការពារសន្តិសុខរបស់ជនត្រូវចោទ ហើយចំណុចសំខាន់មួយដែលទាក់ទងនឹងអង្គហេតុនៅថ្ងៃនេះ គឺការពាររក្សារៀបរយសាធារណៈ។

[១៣:៣៣:០២]

ជាថ្មីម្តងទៀត គឺយើងមានពេលតិចតួចដែលថា ចាប់ពី២៦ មិថុនា ឆ្នាំ២០០៩ ហើយនៅពេលដែលសហចៅក្រមស៊ើបអង្កេតលោកបានរកឃើញថា មិនមានអ្វីកែប្រែជាសំខាន់នៅក្នុងកាលៈទេសៈនោះទេ។ ដូច្នេះហើយ ខ្ញុំមិនបង្ហាញពីទឡ្ហីករណ៍ផ្សេងទៀតនៅចំណុចបីនេះទេ ពីព្រោះថា យើបានបញ្ជាក់នៅក្នុងឆ្លើយតបបណ្តឹងឧទ្ធរណ៍នេះហើយ។ ប៉ុន្តែ ខ្ញុំសូមចាប់អារម្មណ៍ថា មានទឡ្ហីករណ៍មួយដែលមេធាវីការពារបានលើកឡើងនោះ យើងទទួលដំណឹងថាមេធាវីការពារហ្នឹង គឺបានបញ្ជាក់ថា គេមិនមានអារម្មណ៍ធូរស្រាលទេថ្ងៃនេះ។ តែអ្វីដែលគេអង្គុយនោះ គឺថាគេចង់បាន អ្វីចង់បានការឃុំខ្លួនក្នុងផ្ទះទៅវិញ។

អ៊ីចឹងហើយ តើអ្វីជាទឡ្ហីករណ៍ដោះស្រាយ? ទាក់ទងទៅក្នុងដំណាក់កាលលើកចុងក្រោយដែលថារឿងក្តី ឌុច នោះ។ ក្នុងដំណាក់កាល-- ទំព័រចុងក្រោយនោះ ឌុច បានស្នើសុំៗឲ្យប្តូរការឃុំខ្លួនបណ្តោះអាសន្ននោះ ហើយគាត់ស្នើសុំអង្គបុរេថា មិនស្វែងរក ឬក៏បញ្ចប់ការឃុំខ្លួនបណ្តោះអាសន្ននោះទេ គ្រាន់តែប្តូរទៅជាការឃុំខ្លួនក្នុងផ្ទះវិញ។

ដូច្នេះ មេធាវីការពារសុំឲ្យមានការឃុំខ្លួននៅផ្ទះនោះ ជាការសំខាន់នោះខ្លួនបានយល់ព្រមថា វិធាន៦៣.៣នោះ គឺដែលថាលក្ខខណ្ឌនោះត្រូវបានបំពេញ ហើយនៅតែមានជាបន្ត។ នោះហើយដែលជាមូលហេតុដែលថា គាត់មិនសុំឲ្យនៅក្រៅឃុំជាបណ្តោះអាសន្នទេ តែផ្ទុយទៅវិញប្តូរទៅជាការឃុំខ្លួនក្នុងផ្ទះវិញនោះ។

**លោក អាង ឧត្តមៈ**

ខ្ញុំបាទសូមអនុញ្ញាតឲ្យលោក អៀង សារី ទៅសម្រាកនៅបន្ទប់ក្រោម ពីព្រោះគាត់មានបញ្ហាឆ្អឹងខ្នងហើយអង្គុយលែងបាន ប៉ុន្តែសវនាការនេះអាចបន្តបាន ដោយអវត្តមានគាត់បានទាន។

**ប្រធានអង្គបុរេៈ**

តុលាការអនុញ្ញាតតាមការស្នើសុំ។

លោកស្រី?

**ចៅក្រម ខាទីនខា ឡាហ៊្វូស៖**

លោក អៀង សារី ឥឡូវនេះនឹងចាកចេញពីសវនាការ ឬក៏គាត់អាចនឹងត្រឡប់មកវិញនៅក្នុងដំណាក់កាលចុងក្រោយ។ តើគាត់ត្រឡប់មកវិញដែរឬទេ?

**លោក អាង ឧត្តម៖**

គាត់សុំទៅសម្រាក សុំចេញសម្រាកនៅបន្ទប់ខាងក្រោម។ យ៉ាងណា គាត់អាចមានឱកាសតាមដានសវនាការនេះតាមរយៈទូរទស្សន៍បាននៅខាងក្រោម។ ហើយគាត់ដរាបណាគាត់មិនប្រសើរឡើងវិញទេ គាត់សុំស្នាក់នៅទីនោះរហូតដល់ចប់នីតិវិធីតែម្តង។

[១៣:៣៦:១៤]

**លោក អានីស អះមេដ៖**

សូមអរគុណលោកមេធាវី។

លោក លោកស្រីចៅក្រម ខ្ញុំសូមបំភ្លឺបន្ថែមដើម្បីកត់ត្រាបញ្ជាក់ថា ជនត្រូវចោទ គាត់បានដកសិទ្ធិក្នុងការវត្តមាននៅក្នុងសវនាការនេះ ត្រូវបានអនុញ្ញាត។ ដូច្នេះ យើងបានកត់ត្រាទុកជាឯកសារ ហើយ ខ្ញុំនឹងបន្តទឡ្ហីករណ៍។

តើការកែប្រែនូវទឡ្ហីករណ៍នេះ-- ខ្ញុំមានទឡ្ហីករណ៍មួយចំនួនដែលបានលើកឡើង ហើយតាម--បានលើកឡើងនៅក្នុងបណ្តឹងឧទ្ធរណ៍ ប៉ុន្តែជាទឡ្ហីករណ៍ដ៏សំខាន់ចំពោះអង្គបុរេជំនុំជម្រះ។ ទីមួយគាត់មិនបានស្វែងរកការនៅក្រៅឃុំជាបណ្តោះអាសន្នទេ ប៉ុន្តែឃុំខ្លួននៅក្នុងផ្ទះ ដោយបញ្ជាក់ថា គាត់អាយុ ៨៤ឆ្នាំ គាត់សុខភាពមិនល្អ គាត់សុខភាពចុះខ្សោយ គប្បីតែឃុំខ្លួនក្នុងផ្ទះវិញ។

ខ្ញុំមានបំណងនឹងគាំទ្រ ហើយនិងអះអាងថា សុខភាពមិនមែនជាបញ្ហាចម្បងនៃបណ្តឹងឧទ្ធរណ៍នេះទេ។ បណ្តឹងឧទ្ធរណ៍នេះ គឺមានបំណងផ្តោះទៅរកសេចក្តីសម្រេចរបស់ចៅក្រមស៊ើបអង្កេតនៅក្នុងវិធាន២៣.៣(ក) នោះ គឺថានៅក្នុងប្រយោគមួយដែលជំទាស់ទៅលើសេចក្តីសម្រេចខែតុលា ឆ្នាំ២០០៩ គឺថាកន្លះប្រយោគនិយាយថា បណ្តឹងឧទ្ធរណ៍គឺប្រឆាំងសេចក្តីសម្រេចថ្ងៃទី៧ ធ្នូ ឆ្នាំ២០០៩។ អ៊ីចឹងហើយមិនបានលើកឡើងពីបញ្ហាសុខភាពទេ។ ហើយខ្ញុំមិនគាំទ្រដែលថាឲ្យនៅក្រៅឃុំដោយផ្អែកទៅលើតែសុខភាពមួយមុខនោះទេ សូមពិចារណាអាយុចាស់ ហើយនិងសុខភាពខ្សោយ ហើយបញ្ជូនគាត់ឲ្យឃុំខ្លួនក្នុងផ្ទះវិញ។

ឥឡូវនេះ ខ្ញុំនឹងបញ្ជាក់ជូនអំពីបញ្ហាទាក់ទងទៅនឹងការឃុំខ្លួននៅក្នុងផ្ទះ។ បញ្ហានេះ ក៏ត្រូវបាន

ដាក់ចំពោះមុខអង្គបុរេជំនុំជម្រះ ហើយក៏បានដោះស្រាយរួចហើយដែរ ក៏មិនមែនជាបញ្ហាថ្មីនោះទេ។

លោក លោកស្រីចៅក្រមបានពិចារណាថា ក្នុងករណីទាំងពីរនូវសេចក្តីសម្រេចថ្ងៃទី១៧ តុលា ២០០៨ នោះ ហើយនៅថ្ងៃទី២៦ មិថុនា ២០០៩ ក៏បានរកឃើញថា វិធានផ្ទៃក្នុងតុលាការ ហើយនិងនីតិវិធីព្រហ្មទណ្ឌរបស់កម្ពុជា ហើយវាផ្ទុយពីអ្វីដែលលោក អាង ឧត្តម លើកឡើងថ្ងៃនេះមិនបានបញ្ជាក់អំពី ខ បញ្ញត្តិ អំពីការឃុំខ្លួនក្នុងផ្ទះទេ។ វិធាន៦៦ និយាយអំពីការឲ្យនៅក្រៅឃុំ ឬក៏ស្ថិតនៅក្រោមការត្រួតពិនិត្យរបស់តុលាការនោះ។

បើសិនជាលក្ខខណ្ឌនៃការឃុំខ្លួនបណ្តោះអាសន្នក្នុងចំណោមប្រាំនោះ នៅក្នុងវិធាន៦៣.៣(ខ) នោះ បញ្ហានៅក្រៅឃុំ ក្រោមការត្រួតពិនិត្យរបស់តុលាការនោះមិនមែនជាលក្ខខណ្ឌទេ។ ដូច្នេះ នៅមានន័យថា ដើម្បីផ្តល់ការគាំទ្រដល់ជនត្រូវចោទប្រសិនបើគាត់ត្រូវការ។ អ៊ីចឹង ទាក់ទងទៅនឹងនីតិវិធីព្រហ្មទណ្ឌ ហើយនិងវិធានផ្ទៃក្នុងមិនបានចែងអំពីការឃុំខ្លួននៅក្នុងផ្ទះទេ យើងនឹងមើលនៅក្នុងច្បាប់អន្តរជាតិនៅក្នុងបរិបទនៅក្នុងការឃុំខ្លួនក្នុងផ្ទះវិញ។

[១៣:៣៩:៤៥]

មិនមានសាលាក្តីអន្តរជាតិណាមួយទេ រាប់ទាំង អាយ.ស៊ី.ស៊ី តុលាការពិសេសរបស់សេរ៉ាឡេអូន ឬក៏ អាយ.ស៊ី.ធី.អ ដែលបានផ្តល់ឲ្យមានការ ឃុំខ្លួនក្នុងផ្ទះជនណាម្នាក់នៅក្នុងទីនោះទេ លើកលែងតែមានរឿងក្តីពីរ ឬបីចំពោះតុលាការ អាយ.ស៊ី.ធី.វ៉ាយ ដែលខ្ញុំនឹងជម្រាបជូនដែលជាករណីលើកលែង។ នេះវាកើតឡើងនៅក្នុងពីដំបូងរបស់តុលាការ អាយ.ស៊ី.ធី.វ៉ាយ ក្រោយមកក៏បានបញ្ឈប់នៅក្នុងឆ្នាំទី៣ ឬឆ្នាំ៤នៃការងារតុលាការនោះ។ ហើយជារឿងក្តីដែលបានរៀបចំត្រឹមត្រូវអំពីគំហាត់គំលំនៅនេះ គឺនៅក្នុងរឿង *ប្លាស្កេច (Blascic)* នៅក្នុងឆ្នាំ១៩៩៦ នៅក្នុងលក្ខណៈនេះនៅថ្ងៃទី២៨ មេសា ឆ្នាំ១៩៩៦ អាយ.ស៊ី.ធី.វ៉ាយ បានរកឃើញថា លក្ខខណ្ឌនិងកត្តានោះក៏ត្រូវតែបំពេញ ប្រសិនបើការឃុំខ្លួនក្នុងផ្ទះត្រូវបានអនុញ្ញាត។ អង្គបុរេជំនុំជម្រះជ្រាបហើយ គឺថាឆ្នាំ១៩៩៦ គឺថាជាងដប់ឆ្នាំមកហើយ។ ដូច្នេះកត្តាប្រាំហ្នឹង គឺថា ដូចខាងក្រោម៖

- មិនមានភ័ស្តុតាងថា ជនចុងចម្លើយនឹងគេចខ្លួនទេ ទីមួយ។
- នៅទីនេះមិនរកឃើញនៅទីនេះ គឺថាយើងរកឃើញថា គាត់អាចនឹងគេចខ្លួន។
- មិនមានភវនីភាពដែលថា គាត់អាចនឹងបំផ្លាញ ឬក៏គាប់សង្កត់ទៅលើសាក្សី។
- មិនមានភវនីភាពថា គាត់នឹងបន្តឧក្រិដ្ឋកម្ម ហើយនិងត្រូវតែគ្មានការគំរាមកំហែងទៅលើ

សន្តិភាព ឬសន្តិសុខ។

- អ៊ីចឹងហើយគឺថា មួយទៀតគឺមិនប៉ះពាល់របៀបរៀបរយសាធារណៈ។

អៀង សារី វិញ ដូចអង្គបុរេបានសម្រេច ដូចសហចៅក្រមស៊ើបអង្កេតបានសម្រេចស្របជាមួយគ្នានោះដែរ អៀង សារី គឺមិនស្ថិតនៅក្នុងលក្ខខណ្ឌទាំងនេះទេ គាត់អាចជាមនុស្សចាស់។ ប៉ុន្តែ ការឃុំខ្លួនមិនមែនជាការគំរាមកំហែងដល់ជីវិតគាត់ទេ។

បើតាមពិតគឺថា សំណើមួយចំនួនមេធាវីរបស់លោក អៀង សារី បានស្នើសុំតាមរយៈសហចៅក្រមស៊ើបអង្កេត ហើយសំណើមួយចំនួនត្រូវបានឯកភាពឲ្យរក្សាសុខភាពរបស់គាត់។ ប៉ុន្តែ ដោយមេធាវីការពារដែលមិនជំទាស់ទៅនឹងការពិភាក្សាពីរឿងសុខភាពរបស់គាត់នៅក្នុងសាធារណៈ ប៉ុន្តែការទទួលការព្យាបាលដោយចលនាមួយចំនួនច្រើនក៏បានផ្តល់។ ហើយក៏បានបង្កើតភ្នាក់ងារដែលឲ្យគាត់នៅក្នុងកន្លែងឃុំខ្លួនរបស់គាត់ ដើម្បីសម្រួលដល់ការគាត់នោះ គឺថា កុងតាក់ ឬបញ្ហាពីចម្ងាយក៏បានដើម្បីហៅពេទ្យជាជំនួយបាន។

វេជ្ជបណ្ឌិត២៧រូប គឺប្រចាំការ២៤ម៉ោង ដើម្បីតម្រូវការសុខភាពរូបគាត់។ គិលានុបដ្ឋាយិកា និងរថយន្តសង្គ្រោះក៏មានជានិច្ច មានបុគ្គលិកគឺផ្តល់អាហារគ្រប់គ្រាន់សម្រាប់ជនត្រូវចោទរូបនេះ គឺថាដោយមូលហេតុទាំងនេះ គឺថាពីរខែកន្លងទៅហើយ គឺភាពសមស្របដើម្បីប្រឈមទៅនឹងការចោទប្រកាន់ គឺមានបានធ្វើការវាយតម្លៃ ហើយនៅក្នុងថ្មីៗនេះ គឺថាបានបញ្ជាក់ឲ្យឃើញថា លក្ខខណ្ឌសុខភាពរបស់គាត់គឺចាប់តាំងពីពេលដែលគាត់ឃុំខ្លួននោះគឺថា ហើយនៅតែមានបញ្ជាក់តាមផ្លូវវេជ្ជសាស្ត្រ ដែលថាគាត់មានភាពស័ក្តិសម ដើម្បីប្រឈមនៅមុខ ការជំនុំជម្រះបានតាមគោលការណ៍សុខភាព។

[១៣:៤៣:៣៣]

សូមជម្រាបអង្គបុរេជំនុំជម្រះថា យើងមានបញ្ហាបីសំខាន់ៗទាក់ទងនឹងជនត្រូវចោទរូបនេះដែលបានរកឃើញតាំងពីខែវិច្ឆិកា ឆ្នាំ២០០៧ តាំងពីបង្ហាញខ្លួនចំពោះសហចៅក្រមស៊ើបអង្កេត។

ទីមួយគឺបញ្ហាបេះដូង គឺថាវាមានមុនពេលឃាត់ខ្លួនរបស់គាត់ដែលមានការវះកាត់បញ្ហាបេះដូង។ បញ្ហាមួយទៀត គឺការឈឺឆ្អឹងខ្នងបានលើកឡើងមួយចំនួនហើយខាងដើម។ បញ្ហាទីបី គឺបញ្ហាតម្រងនោម ដែលគាត់ថាមានការលំបាក គឺថាវាមានបញ្ហាស្មុគស្មាញ។

ប៉ុន្តែ មិនមានវេជ្ជបណ្ឌិតណាមួយបានពិនិត្យគាត់ ដែលថាក្នុងរយៈពេលពីរឆ្នាំនៃការឃុំខ្លួន ដែលយល់ថា ការឃុំខ្លួននេះជាអាចនឹងធ្វើឲ្យសុខភាពរបស់ចុះថយទេ។ ប៉ុន្តែ នៅក្នុងរបាយការណ៍ខែឧសភា

ឆ្នាំ២០០៨ នោះ គឺថាមានលក្ខខណ្ឌតែមួយដែលដុកទ័រ ម៉ាហ្សង់ គាត់និយាយបានរកឃើញនោះ គឺថាត្រូវឲ្យបន្ទប់ទឹកនៅជិតបន្ទប់របស់គាត់ ដើម្បីឲ្យគាត់បានទៅស្រួល ហើយមានគ្រែសម្រាប់គាត់សម្រាន្ត កុំឲ្យគាត់ឈឺខ្នង មានពូក។

ដូច្នេះ ហើយមានឧបករណ៍គ្រប់គ្រាន់នៅក្នុងមន្ទីរឃុំឃាំងរបស់ អ.វ.ត.ក ហើយនិងសេវាវេជ្ជ-សាស្ត្រនៅកាល់ម៉ែត្រ គឺគ្រប់គ្រាន់សម្រាប់ជនត្រូវចោទ ដូច្នេះហើយមិនមានលក្ខខណ្ឌតម្រូវ ពិសេស អ្វីដែលថា គាត់ត្រូវព្យាបាលខុសពីហ្នឹង ឬក៏ដាក់កន្លែងណាផ្សេងដែលថាត្រូវមានអ្វីដែលប្រសើរជាងមន្ទីរពេទ្យកាល់ម៉ែត្រ ឬក៏នៅទីនេះនោះទេ។

ឥឡូវនេះ លោក លោកស្រីចៅក្រម គឺជាព័ត៌មានមូលដ្ឋានជាភ័ស្តុតាងគឺថា ខ្ញុំមានតែប្រាំមីនុត ឬក៏ប្រាំពីរមីនុតទៀតទេ គឺលក្ខខណ្ឌសុខភាពក្នុងលក្ខខណ្ឌបែបនេះនោះ អាចផ្តល់ឲ្យអង្គបុរេជំនុំជម្រះ ឧទាហរណ៍ថា ឲ្យជនត្រូវចោទស្វែងរកការនៅក្រៅឃុំបណ្តោះអាសន្ននោះ។ បើចាត់ទុកថាកត្តានោះជាជម្រើសតែមួយនោះ ដូចជាករណីផ្សេងៗទៀតដែលអង្គបុរេជំនុំជម្រះដែលជួបប្រទះ គឺថាមិនដែលកើតឡើងក្នុងពេលណាមួយក្នុងអន្តរជាតិនោះទេ ជាពិសេសនៅក្នុងករណីដែលជនត្រូវចោទមានអាយុច្រើននោះ។

លក្ខខណ្ឌវិនិច្ឆ័យបីយ៉ាង ដែលបានបង្កើតឡើងដោយយុត្តិសាស្ត្រសាលាក្តីអន្តរជាតិនោះ បានសម្រេចមួយចំនួនទាក់ទងទៅនឹងការដាក់ឲ្យនៅក្រោមការត្រួតពិនិត្យរបស់តុលាការ។ បើមិនមានអង្គ-ភាពឃុំខ្លួនត្រឹមត្រូវទេ ឬក៏កន្លែងនោះវាជាទីមានជម្លោះ។ ដូចជាក្នុងករណីសេរ៉ាឡេអូន ដែលថាគេបញ្ជូនជនម្នាក់ទៅសេណេហ្កាល់ ដោយសារមិនមានទីតាំងឃុំខ្លួនត្រឹមត្រូវ ហើយតុលាការនៅព្រីថោន នោះ តាមពិតនៅក្នុងសេរ៉ាឡេអូនជាដើម។

បញ្ហាទាំងស្រុងដូចជាតុលាការ អាយ.ស៊ី.ធី.វ៉ាយ នៅឆ្នាំ២០០៤ នៅក្នុងរឿងស្តាខេសនោះ គឺថាមិនមានការព្យាបាលគ្រប់គ្រាន់នៅក្នុងមន្ទីរឃុំឃាំងដូចរឿងក្តីមីឡូស្វីកនៅអាយ.ស៊ី.ធី.វ៉ាយ តុលាការរកឃើញថា វេជ្ជសាស្ត្រ ហើយនិងការឃុំខ្លួននៅក្នុងឡាអេនោះ ហើយតាមពិតនៅក្នុងហូឡង់ គឺគ្រប់គ្រាន់ គឺមិនមានលក្ខខណ្ឌតម្រូវដែលថា ត្រូវបញ្ជូនគាត់ទៅរុស្ស៊ីដូចដែលគាត់បានស្នើសុំនោះទេ។

លក្ខណៈវិនិច្ឆ័យទីពីរ ដែលយុត្តិសាស្ត្រសាលាក្តីអន្តរជាតិបានកំណត់គឺដូចខាងក្រោម៖ ថាតើនៅលើមូលហេតុមនុស្សធម៌ សុខភាពរបស់ជនត្រូវចោទ គឺថាវាមានលក្ខណៈធ្ងន់ធ្ងរ។ នៅពេលដែលគេសម្រេចបែបនោះ តុលាការសម្រេចថា ការធ្ងន់-- ជំងឺធ្ងន់ធ្ងរដោយខ្លួនឯងហ្នឹង ខ្ញុំអានជាទឡ្ហីករណ៍នៅ

ក្នុងរឿងក្តីនោះ គឺថាជំងឺធ្ងន់ដោយជំងឺខ្លួននោះ មិនមែនជាមូលដ្ឋានដោះឲ្យនៅក្រៅឃុំដែរ។ លើកលែងតែវាមានការគំរាមកំហែងដល់ជីវិតភ្លាមៗ ហើយជាជំងឺមិនអាចព្យាបាលនៅក្នុងមន្ទីរឃុំឃាំងបាន។

[១៣:៤៧:៥៧]

នេះហើយជាលក្ខខណ្ឌបីដែលថា ទាំងបីហ្នឹងត្រូវតែបំពេញ គឺលក្ខណៈជំងឺហ្នឹងគឺថា ផ្តាច់ផ្តិលវេជ្ជបណ្ឌិតក្នុងបច្ចុប្បន្ននេះ គឺថាមិនអាចកែខៃបានទេ គឺជាជំងឺដែលផ្តាច់ផ្តិល។ ហើយវាមានការគំរាមកំហែងដល់ជីវិត ហើយជាជំងឺដែលមិនអាចព្យាបាលដោយថ្នាំអ្វី ដោយដុកទ័រអ្វីបាន។ បើរកឃើញថានៅកាល់ម៉ែត្រមិនអាចមាន ទីណាមិនអាចមាន អាហ្នឹងគឺថាអាចជាកត្តាដែលអាច-- បើមានលក្ខខណ្ឌទាំងបីនេះបំពេញហើយ អាចឲ្យនៅក្រៅឃុំបាន ប៉ុន្តែបើមិនបំពេញទាំងបីទេ មិនអាចបានទេ។

លក្ខខណ្ឌទីបី ដែលសាលាក្តីផ្សេងៗបានដោះលែងជនត្រូវចោទនោះ នៅពេលដែលជនត្រូវចោទគាត់មិនមានសម្បទាមិនក្នុងការទទួលការជំនុំជម្រះ។ ចំណុចនេះត្រូវបានគេយកមកពិចារណានៅក្នុងរឿងក្តីស្ត្រូហ្គ័រ ដូចដែលសហមេធាវីការពារក្តីបានលើកឡើងនៅក្នុងរឿងក្តីដទៃទៀត។

ជាថ្មីម្តងទៀតតុលាការ អាយ.ស៊ី.ធី.វ៉ាយ រកឃើញថា បញ្ហានោះមិនមែនថា ជនត្រូវចោទនោះទទួលបញ្ហាផ្លូវស្មារតីនោះទេ ប៉ុន្តែថាតើជនត្រូវចោទមានសមត្ថភាពក្នុងការអនុវត្តសិទ្ធិរបស់ខ្លួននៅក្នុងនីតិវិធីរបស់ខ្លួនដែលឬទេ? នេះជាសម្បទាក្នុងការទទួលការជំនុំជម្រះ ជនត្រូវចោទរូបនេះមានសម្បទាគ្រប់គ្រាន់ មិនមានវេជ្ជបណ្ឌិតណាមួយបានរកឃើញថា គាត់មិនមានសម្បទាបែបនេះក្នុងរយៈពេលខ្លីឬក៏គាត់មិនអាចជួយជ្រោមជ្រែងទៅដល់មេធាវីការពារក្តីរបស់គាត់ ឬក៏មិនអាចចូលរួមនៅក្នុងនីតិវិធីឲ្យមានប្រសិទ្ធភាពនោះបានទេ ឬក៏គេត្រូវភ្ជាប់ទំនាក់ទំនងរវាងការវិភាគ ដែលវាប៉ះពាល់ទៅដល់សម្បទារបស់ជនត្រូវចោទ។ តុលាការបានបង្ហាញហួសពីចំណុចហ្នឹង ទោះបីជាមានសមត្ថភាព មិនមានសមត្ថភាពខាងផ្លូវចិត្តក៏ដោយ វាត្រូវតែមានការជាប់ពាក់ព័ន្ធគ្នា ថាតើសមត្ថភាពនោះ សម្បទានោះវាប៉ះពាល់ទៅដល់ការទទួលការជំនុំជម្រះដែរឬទេ?

នៅក្រោមច្បាប់អន្តរជាតិ នៅពេលដែលជនត្រូវចោទត្រូវបានដោះលែងសម្រាប់ការព្យាបាលជនត្រូវចោទត្រូវបានដោះលែងសម្រាប់ការព្យាបាលវេជ្ជសាស្ត្រតែប៉ុណ្ណោះ មិនត្រូវដោះលែងក្នុងលក្ខណៈណាផ្សេងនោះទេ។ ដូច្នេះការដោះលែងជនត្រូវចោទ គឺត្រូវដោះលែងឲ្យទៅមន្ទីរពេទ្យដូចជា នៅក្នុងមុងតេក្រូ ហើយគេត្រូវត្រឡប់មកវិញ ក្រោយពីការបញ្ចប់ការព្យាបាលទៅដល់ជនត្រូវចោទ។ ដូច្នេះករណីនេះ យើងបានអនុវត្តទៅកាន់ជនត្រូវចោទ ហើយមេធាវីបានដឹងលើបញ្ហានេះយូរមកហើយ ហើយរយៈ

ពេលនៃការព្យាបាលនោះវាមានរយៈពេលយូរ ហើយគាត់ចំណាយពេលព្យាបាលខ្លួននៅកាល់ម៉ែត្រ ហើយទទួលបាននូវការវិលត្រឡប់មកវិញ។

[១៣:៥១:០៥]

ដូច្នេះ បញ្ហាថាតើសិទ្ធិទទួលការជំនុំជម្រះដោយយុត្តិធម៌ គឺវាទាក់ទងទៅនឹងថា តើមេធាវីអាចចូលជួបកូនក្តីរបស់ខ្លួននៅមន្ទីរពេទ្យដែរឬទេ? វាមិនមែនស្ថិតនៅក្នុងវិសាលភាពនៃករណីនេះទេ។ យើងត្រូវគិតពិចារណាថា តើជនត្រូវចោទវាមានការប៉ះពាល់ទៅដល់ស្មារតីផ្លូវចិត្តនិងសុខភាពរបស់ខ្លួនដែរឬទេ? រឿងក្តីដែលខ្ញុំបានលើកឡើង គឺវាអនុញ្ញាតឲ្យមានការជួបគ្រួសារ។ គេមិនអនុញ្ញាតឲ្យជួបគ្រួសារនោះទេ គឺគេអនុញ្ញាតឲ្យជួបឲ្យទទួលការព្យាបាលវេជ្ជសាស្ត្រ លើកលែងតែករណីដែលព្យាបាលលែងជា ហើយត្រូវស្លាប់ក្នុងរយៈពេលមួយខែ បានន័យថា វាជាជំងឺមួយព្យាបាលមិនជាគេអនុញ្ញាតឲ្យចាកចេញបាន។ នេះគឺជាចំណុចដែលខ្ញុំលើកឡើងទាក់ទងទៅនឹងបញ្ហាមន្ទីរពេទ្យនិងការឃុំនៅក្នុងផ្ទះ។

យើងបានលើកឡើងសេចក្តីសន្និដ្ឋានទាំងអស់នេះនៅក្នុងការឆ្លើយតបរបស់យើង ហើយវិធានលក្ខខណ្ឌក្នុងវិធាន៦៣.៣(ខ) បីនោះគឺបានបំពេញ ហើយលោក លោកស្រីចៅក្រមបានសម្រេចហើយថា មិនអាចអនុញ្ញាតឲ្យមានការឃុំខ្លួននោះបានទេ ដោយសារតែវាបានបំពេញលក្ខខណ្ឌទាំងបីនៅក្នុងវិធាន៦៣.៣(ខ)។

ខ្ញុំនឹងសូមបញ្ចប់ ដោយសូមយោងទៅលើ ការយោងរបស់លោក អាង ឧត្តម ដែលលោកបានលើកឡើងរឿងក្តីអន្តរជាតិ។ ដោយសារតែជនជាប់ចោទនៅពេលនោះត្រូវបានគេដោះលែង ដែលអ្នកទាំងអស់នោះទទួលនូវការចោទប្រកាន់ទៅលើឧក្រិដ្ឋកម្មសង្គ្រាម បទប្រល័យពូជសាសន៍ និងបទប្រល័យដទៃៗទៀត ហើយខ្ញុំនឹងលើកឡើងអំពីករណី ជា វិជ្ជា។

នៅក្នុងករណី ជា វិជ្ជា តុលាការកំពូលបានលើកឡើងថា វាមានជំនុំជម្រះខុស។ នៅក្នុងការរកឃើញដូចហេតុនោះហើយ ទើបគេធ្វើការដោះលែង។ គឺគេបានលើកឡើងអំពីការជំនុំជម្រះខុស ប៉ុន្តែនៅក្នុងរឿងក្តីរបស់យើងនេះវាមិនមែនជាការជំនុំជម្រះខុសនោះទេ ហើយនៅក្នុងករណីរបស់យើងគឺវាទាក់ទងទៅនឹងកិច្ចរបស់សហចៅក្រមស៊ើបអង្កេត ហើយចៅក្រមស៊ើបអង្កេតបានលើកឡើងទៅលើចំណុចទាំងអស់នេះ។

[១៣:៥៣:២៥]

ទទ្បីករណ៍ទាំងឡាយ យើងឃើញថា ភាគច្រើនគឺត្រូវបានទាត់ចោលដោយអង្គបុរេជំនុំជម្រះ

ហើយខ្ញុំនឹងលើកឡើងអំពីទឡ្ហីករណ៍ចំនួនប្រាំ ដែលមេធាវីការពារក្តីបានលើកឡើងបដិសេធចំពោះសុច្ចវិតភាពនៃការស៊ើបអង្កេត។ គាត់បានលើកឡើងអំពីករណីសហចៅក្រមស៊ើបអង្កេតអន្តរជាតិ ហើយមានរឿងមួយដែលនៅចំពោះមុខអង្គបុរេជំនុំជម្រះ ដែលគេចោទប្រកាន់ទាក់ទងទៅនឹងសហចៅក្រមស៊ើបអង្កេតដែលរកតែភ័ស្តុតាងដាក់បន្ទុក។ ហើយក៏មានការលើកឡើងអំពីការលម្អៀងរបស់លោក ដេវីដប៊យ ដែលយើងបានដោះស្រាយយូរមកហើយ ហើយយើងក៏បានលើកឡើងនៅក្នុងទឡ្ហីករណ៍ទាំងអស់នោះ។

ដូច្នេះហើយការតវ៉ាទៅលើការឃុំខ្លួននេះមិនមានភាពសមស្រប ហើយការដែលយើងលើកឡើងអំពីការលូកលាន់នៅក្នុងកិច្ចការតុលាការ ក៏កំពុងរង់ចាំការជំនុំជម្រះផងដែរនៅចំពោះមុខសវនាការអង្គបុរេជំនុំជម្រះ។ ដូច្នេះ ការស្នើសុំអំពីការប្រើប្រាស់ភ័ស្តុតាងទាក់ទងទៅនឹងទារុណកម្មក៏បានទាត់ចោលដោយអង្គបុរេជំនុំជម្រះ ហើយសហចៅក្រមស៊ើបអង្កេតបានធ្វើការគាំទ្រទៅលើចំណុចទាំងអស់នេះ។ ហើយទាក់ទងទៅនឹងការរកភ័ស្តុតាងដោះបន្ទុកនោះ គឺជាករណីដែលសហមេធាវីការពារក្តីជាអ្នកគិតទៅលើបញ្ហាហ្នឹង គាត់ជ្រើសរើសមិនធ្វើការប្តឹងទៅលើចំណុចហ្នឹង។

ដូច្នេះ ខ្ញុំសូមលើកឡើងថា បណ្តឹងឧទ្ធរណ៍របស់មេធាវីក្តី គួរតែបដិសេធចោល ហើយអង្គបុរេជំនុំជម្រះត្រូវពិចារណាទៅលើវិសាលភាពនៃបណ្តឹងឧទ្ធរណ៍ ហើយត្រូវពិចារណាឲ្យបានហ្មត់ចត់ថាតើគួរតែផ្តល់ការឃុំខ្លួននៅក្នុងផ្ទះដែរឬទេ? ហើយត្រូវពិចារណាអំពីកាលៈទេសៈជាក់ស្តែង និងមូលដ្ឋានផ្សេងៗទៀត ដែលយើងត្រូវពិចារណា។

ខ្ញុំសូមអរគុណ លោក លោកស្រី ចៅក្រម។

**ប្រធានអង្គបុរេ៖**

បាទ។

**ចៅក្រម ខាទីនខា ឡាហ្វ៊ីស៖**

ខ្ញុំសូមឲ្យសហព្រះរាជអាជ្ញាធ្វើការកត់សម្គាល់មួយចំនួន ទាក់ទងទៅនឹងការដាក់ឯកសារដែលបានលើកឡើងកាលពីដើមព្រឹកមិញ។ ដែលសហមេធាវីការពារក្តី គាត់បានលើកយោបល់របស់គាត់ ហើយ ទាក់ទងទៅនឹងការដាក់ឯកសារនោះ។

**លោក អានីស អះមេដ៖**

ខ្ញុំសូមអភ័យទោស ខ្ញុំគួរតែលើកទៅលើចំណុចហ្នឹងដោយខ្លួនឯង។ នៅក្នុងសេចក្តីសម្រេចថ្ងៃទី

៣ ខែកក្កដា ឆ្នាំ២០០៩ ដែលវាទាក់ទងទៅនឹងការបណ្តឹងឧទ្ធរណ៍នៃការឃុំខ្លួនបណ្តោះអាសន្នលោក ខៀវ សំផន លោក លោកស្រីចៅក្រមបានសង្កេតឃើញថា ហើយផ្អែកទៅលើរបាយការណ៍ទាក់ទងទៅនឹងសន្តិទស្សន៍ សន្តិភាព របាយការណ៍ចុះឆ្នាំ២០០៨ ហើយរបាយការណ៍នេះ គឺមាននៅក្នុងសំណុំរឿងរួចមកហើយ។

របាយការណ៍ថ្មីមួយបានលេចចេញមក វាចេញបន្ទាប់ពីមានរបាយការណ៍ឆ្នាំ២០០៨ ដូច្នេះហើយយើងគិតថា វាមានភាពសមស្របដែលយើងត្រូវដាក់ចូលនៅក្នុងសំណុំរឿង។ ហើយវាក៏ទាក់ទងទៅនឹងបណ្តឹងឧទ្ធរណ៍-- សវនាការបណ្តឹងឧទ្ធរណ៍ថ្ងៃនេះ ថ្ងៃស្អែក និងថ្ងៃច័ន្ទ ដែលយើងត្រូវយោង។ ហេតុផលដែលយើងដាក់ឯកសារនេះ គឺដោយសារតែយើងមិនចង់ឲ្យមានការបាត់បង់នូវការប្រុងប្រយ័ត្ន យើងចង់គាំទ្រនូវទឡ្ហីករណ៍របស់យើង។ យើងក៏មិនមែនយកឯកសារនេះធ្វើជាឯកសារមូលដ្ឋានចម្បងដែរ យើងគ្រាន់តែយកមកដាក់ជាឯកសារមូលដ្ឋានបន្ទាប់បន្សំតែប៉ុណ្ណោះ។

តាមដីកាសម្រេចរបស់សហចៅក្រមស៊ើបអង្កេត នៅថ្ងៃទី១៩ ខែមីនា ឆ្នាំ២០០៩ ដែលនៅក្នុងដីកានោះ សហចៅក្រមស៊ើបអង្កេតបានលើកឡើងថា ទាក់ទងទៅនឹងឯកសារសាធារណៈដែលមិនទាក់ទងទៅនឹងអង្គហេតុ ដែលវាមាននៅក្នុងដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរ ភាគីអង្គជំនុំជម្រះអាចផ្អែកទៅលើឯកសារសាធារណៈទាំងអស់នោះ នៅពេលដែលខ្លួនមានបំណងដោយមិនចាំបាច់ដាក់នៅក្នុងសំណុំរឿងឡើង។ តាមរយៈដីកានេះ គឺដីកាចុះថ្ងៃ១៩ ខែមីនា ចុះហត្ថលេខាដោយសហចៅក្រមម៉ាកសែល ឡឺម៉ុងដ៍ និងយូ ប៊ុនឡេង យើងទទួលបានសិទ្ធិនេះក្នុងការប្រើប្រាស់ឯកសារសាធារណៈទាំងអស់នោះ។ ទោះបីជាឯកសារទាំងអស់នោះ មិនគាំទ្រអង្គហេតុនៅក្នុងដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរក៏ដោយ វាគ្រាន់តែគាំទ្រអង្គហេតុ ដែលវាជាមូលដ្ឋាននៃទឡ្ហីករណ៍ចំពោះបណ្តឹងឧទ្ធរណ៍លើការឃុំខ្លួនបណ្តោះអាសន្ន ដូច្នេះហើយគឺវាមានការពាក់ព័ន្ធ។

នៅពេលដែលយើងផ្អែកនៅលើឯកសារនេះ យើងនឹងយោងទៅលើឯកសារនេះ ហើយខ្ញុំមិនអានឯកសារហ្នឹងនៅថ្ងៃនេះទេ ហើយយើងនឹងយោងទៅលើឯកសារនេះ ហើយវាជាការគួរសមទៅដល់មេធាវីការពារក្តីដើម្បីឲ្យគាត់បានដឹង ហើយយើងចង់ដាក់នៅក្នុងសំណុំរឿង។

[១៣:៥៨:៣០]

ខ្ញុំទុកបញ្ហានេះឲ្យចៅក្រមជាអ្នកសម្រេច ហើយគោលបំណងរបស់យើងនៅថ្ងៃនេះ ហើយយើងគិតថាវាមិនមានកាលៈទេសៈដាក់ស្តែងផ្លាស់ប្តូរនោះទេទៅលើបណ្តឹងឧទ្ធរណ៍។ ហើយចំពោះពេលដែល

យើងបើសវនាការនៅថ្ងៃស្អែកនិងថ្ងៃបន្ទាប់ទៀត ខ្ញុំនឹងប្រើប្រាស់នូវឯកសារយោងនេះផងដែរ ហើយយើងក៏មិនចង់ឲ្យមានការមិនប្រុងប្រយ័ត្ននោះដែរ ដូច្នេះទើបយើងជូនដំណឹងអំពីឯកសារទាំងអស់នេះឲ្យមេធាវីការពារក្តីគាត់បានជ្រាប។

នេះជាអ្វីដែលខ្ញុំចង់លើកឡើងឆ្លើយតបទៅនឹងឯកសារដាក់កាលពីព្រឹកមិញនេះ សូមអរគុណ។

**ចៅក្រម ខាទីនខា ឡាហ្វ៊ីស៖**

ខ្ញុំសូមឲ្យលោកលើកឡើងអំពីបញ្ហា ដែលលើកឡើងដោយមេធាវីការពារក្តីទាក់ទងទៅនឹងការដាក់ឯកសារយឺតផងដែរ។

**លោក អានីស អះមេដ៖**

ការដែលយើងដាក់យឺតនេះ គឺវាមិនមានលក្ខណៈជាក់ស្តែងនោះទេ ខ្ញុំដាក់ឯកសារនេះគ្រាន់តែជាការគោរព ហើយជាការជូនដំណឹងទៅដល់មេធាវីការពារក្តីដែលថា វាជាឯកសារសាធារណៈ ហើយភាគីទាំងអស់មានឯកសារទាំងអស់នេះ។ ហើយសហព្រះរាជអាជ្ញា ឬក៏ភាគីដទៃទៀត ដែលយើងត្រូវតែសម្តែងការគួរសមបែបនេះ ហើយជូនដំណឹងទៅដល់មេធាវីការពារក្តី។ យើងមិនមែនយោងទៅលើឯកសារដែលជាឯកសារស៊ើបអង្កេតរបស់សហចៅក្រមស៊ើបអង្កេតនោះទេ វាគ្រាន់ជាឯកសារសាធារណៈតែប៉ុណ្ណោះ។ ហើយវាអាស្រ័យទៅលើចៅក្រមជាអ្នកកំណត់ទៅលើទម្ងន់នៃឯកសារនេះ។

សូមអរគុណ។

**ប្រធានអង្គបុរេ៖**

ជាបន្តទៀត សូមអញ្ជើញសហមេធាវីដើមបណ្តឹងរដ្ឋប្បវេណី ឡើងធ្វើសេចក្តីសន្និដ្ឋានរយៈពេលមួយម៉ោង។ សូមអញ្ជើញ។

**លោក នី ចាន់ឌី៖**

សូមអរគុណ។ ហើយសូមគោរពលោកប្រធាន លោក លោកស្រីចៅក្រម និងសូមគោរពអង្គសវនាការទាំងមូលនៅថ្ងៃនេះ។

ខ្ញុំបាទ នី ចាន់ឌី ជាសហមេធាវីរបស់ដើមបណ្តឹងរដ្ឋប្បវេណី សូមធ្វើការឆ្លើយតបចំពោះបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាសម្រេចបន្តការឃុំខ្លួនរបស់ជនត្រូវចោទ ដែលបច្ចុប្បន្នគាត់សុំសម្រាកនៅខាងក្រៅ។ មុននឹងធ្វើការឆ្លើយតបចំពោះបណ្តឹងឧទ្ធរណ៍នេះ ខ្ញុំសូមធ្វើការចាប់អារម្មណ៍បន្តិច ចំពោះសំណើរបស់សហព្រះរាជអាជ្ញាដែលបានដាក់បញ្ចូលនៅក្នុងសំណុំរឿង ហើយដែលកាលពីព្រឹកមិញនេះ អង្គ

បុរេជំនុំជម្រះបានស្នើសុំឲ្យភាគីធ្វើការផ្តល់ជាគំនិត ក៏ប៉ុន្តែនៅពេលដែលអង្គបុរេជំនុំជម្រះផ្តល់នាទីនេះទៅឲ្យសហមេធាវីការពារក្តីផ្តល់ជាគំនិតហើយអត់បានផ្តល់ពេលវេលាឲ្យមេធាវីដើមបណ្តឹងរដ្ឋប្បវេណីផ្តល់ជាគំនិតដូចភាគីមួយទៀតទេ។ អ៊ីចឹង ខាងភាគីដើមបណ្តឹងរដ្ឋប្បវេណី សុំមិនផ្តល់ជាទស្សនៈយោបល់របស់ខ្លួន ចំពោះការស្នើសុំដាក់បញ្ចូលឯកសារទៅក្នុងសំណុំរឿងនេះទេ ក៏ប៉ុន្តែស្នើទៅអង្គបុរេជំនុំជម្រះថា នៅពេលដែលមានការស្នើសុំរបៀបទៅនឹងសំណើរបស់សហព្រះរាជអាជ្ញាបានលើកឡើងកាលពីព្រឹកមិញនេះគឺថា ស្នើសុំឲ្យអង្គបុរេប្រគល់តួនាទី ឬពេលវេលាឲ្យសហមេធាវីដើមបណ្តឹងរដ្ឋប្បវេណី ធ្វើការបង្ហាញអំពីការយល់ឃើញរបស់ខ្លួនផង។

ជាដំបូង ខ្ញុំសូមអនុញ្ញាតជម្រាបជូនដល់អង្គបុរេជំនុំជម្រះថា ខ្ញុំក្នុងឋានៈជាសហមេធាវីជាតិរបស់ដើមបណ្តឹងរដ្ឋប្បវេណី នឹងធ្វើការឆ្លើយតបដោយផ្ទាល់មាត់ទៅបណ្តឹងឧទ្ធរណ៍របស់ជនត្រូវចោទ ហើយសហមេធាវីអន្តរជាតិខ្ញុំ គឺលោក ដេវីដ ប្លេកមេន លោកនឹងបន្តអំពីខ្ញុំក្នុងការឆ្លើយតបនៅក្នុងបណ្តឹងឧទ្ធរណ៍នេះដែរ។ សហមេធាវីដើមបណ្តឹងរដ្ឋប្បវេណី សូមធ្វើការសម្តែងនូវការជំទាស់ទាំងស្រុង និងស្នើសុំទៅអង្គបុរេជំនុំជម្រះមេត្តាសម្រេចបដិសេធចោលនូវបណ្តឹងឧទ្ធរណ៍របស់ជនត្រូវចោទ ដែលបានដាក់ជូន កាលពីថ្ងៃទី០៧ ខែធ្នូ ឆ្នាំ២០០៩ ដែលបានធ្វើឡើងតាមរយៈមេធាវីរបស់ខ្លួន ដោយសារតែបណ្តឹងឧទ្ធរណ៍នេះ បានធ្វើការវាយតម្លៃដោយភ័ន្តច្រឡំទៅលើដីកាសម្រេចបន្តថិរវេលានៃការឃុំខ្លួនបណ្តោះអាសន្នរបស់សហចៅក្រមស៊ើបអង្កេត ចុះថ្ងៃទី១០ ខែវិច្ឆិកា ឆ្នាំ២០០៩ ហើយបណ្តឹងឧទ្ធរណ៍នេះ ពុំមានសំអាងហេតុគាំទ្រគ្រប់គ្រាន់នោះទេ។

[១៤:០៣:០០]

សហមេធាវីជនត្រូវចោទ បានលើកឡើងថា សហចៅក្រមស៊ើបអង្កេតមានកំហុសដោយសារការសំអាងទៅលើភាពចាំបាច់ដែលអនុវត្ត ដែលមានចែងនៅក្នុងវិធាន៦៣.៣(ខ)(៣) ស្តីអំពីការធានាវត្តមានរបស់ជនត្រូវចោទនៅក្នុងដំណើរការនីតិវិធី វិធាន៦៣.៣(ខ)(៤) ស្តីអំពីការការពារសន្តិសុខជនត្រូវចោទ វិធាន៦៣.៣(ខ)(៥) ស្តីអំពីការរក្សាសណ្តាប់ធ្នាប់សាធារណៈ ដែលសហចៅក្រមស៊ើបអង្កេតលើកយកធ្វើជាមូលដ្ឋានក្នុងការឃុំខ្លួនបណ្តោះអាសន្ន។ ហើយសហមេធាវីការពារក្តីក៏បានបន្ថែមថា សហចៅក្រមស៊ើបអង្កេតខកខានមិនបានពិចារណាទៅលើជម្រើសផ្សេង ក្រៅអំពីការដាក់ជនត្រូវចោទឲ្យនៅក្នុងមន្ទីរឃុំឃាំង។ ហើយជាទីបញ្ចប់សហមេធាវីការពារក្តី បានស្នើទៅអង្គបុរេជំនុំជម្រះបដិសេធដីកាសម្រេចបន្តការឃុំខ្លួន និងបញ្ចប់ការឃុំខ្លួនជនត្រូវចោទជាបណ្តោះអាសន្ន។ នេះគឺជា

សំណើជាលាយលក្ខណ៍អក្សរនៅក្នុងបណ្ដឹងឧទ្ធរណ៍ ដែលសហមេធាវីការពារក្ដីអត់បានស្នើសុំទៅអង្គបុរេជំនុំជម្រះធ្វើការពិចារណាទៅលើជម្រើសផ្សេងទេ គាត់បានស្នើទៅសហចៅក្រមស៊ើបអង្កេតនៅក្នុងការកត់សម្គាល់របស់ខ្លួន មុនពេលដែលសហចៅក្រមស៊ើបអង្កេតហ្នឹងគាត់ចេញដីកាបន្តការឃុំខ្លួនថា សុំឲ្យពិចារណាទៅលើជម្រើសផ្សេង។ ប៉ុន្តែ នៅក្នុងបណ្ដឹងឧទ្ធរណ៍ជាលាយលក្ខណ៍អក្សររបស់ខ្លួនសហមេធាវីការពារក្ដីស្នើសុំត្រឹមតែបដិសេធដីកាបន្តការឃុំខ្លួន ហើយដោះលែង ដោះលែងជនត្រូវចោទអត់មានស្នើទៅអង្គបុរេជំនុំជម្រះ ពិចារណាទៅលើជម្រើសផ្សេងទេ។

សហមេធាវីដើមបណ្ដឹងរដ្ឋប្បវេណីកត់សម្គាល់ឃើញថា សហចៅក្រមស៊ើបអង្កេតបានអនុវត្តឆន្ទានុសិទ្ធិរបស់ខ្លួនយ៉ាងត្រឹមត្រូវ នៅក្នុងការសម្រេចចេញដីកាបន្តការឃុំខ្លួនខាងលើ ដោយបានវិភាគយ៉ាងច្បាស់លាស់ទៅលើការវិវត្តន៍នៃកិច្ចស៊ើបអង្កេត អំណះអំណាង សេចក្ដីសម្រេចរបស់អង្គបុរេជំនុំជម្រះដែលបានធ្វើកន្លងមក និងភាពចាំបាច់នៃការបន្តការឃុំខ្លួនតាមគោលបំណងដែលមានចែងនៅក្នុងវិធាន៦៣.៣(ខ)។

អំពីចំណុច ៦៣.៣(ក) នៅក្នុងបណ្ដឹងឧទ្ធរណ៍របស់ខ្លួន ជនត្រូវចោទមិនបានជំទាស់ជាពិសេសទេ ទៅនឹងដីកាបន្តការឃុំខ្លួនត្រង់ចំណុចវិធាន៦៣.៣(ក) ដែលទាក់ទងទៅនឹងមូលហេតុដែលត្រូវបានជឿជាក់ថា ជនត្រូវចោទបានផ្ដាប់ប្រព្រឹត្តបទល្មើសមួយ ឬច្រើន ដូចមានចែងនៅក្នុងដីកាបញ្ជូនរឿងឲ្យស៊ើបសួរ ឬដីកាបញ្ជូនរឿងឲ្យស៊ើបសួរបន្ថែម។

[១៤:០៦:០០]

ប៉ុន្តែជនត្រូវចោទ បានត្រឹមតែលើកឡើងអំពីមូលហេតុនៃវិធាន៦៣.៣(ក) មានភាពគ្រប់គ្រាន់ឬការខ្វះភស្តុតាងដោះបន្ទុក គឺដោយសារតែកំហុសនីតិវិធីនៃការស៊ើបអង្កេតដែលជនត្រូវចោទខ្លួនឯងមិនបានធ្វើបណ្ដឹងឧទ្ធរណ៍ទេអំពីចំណុចនេះ ហើយក៏ចំណុចនេះក៏អត់មានជាប់ពាក់ព័ន្ធទៅនឹងបណ្ដឹងឧទ្ធរណ៍ដែលកំពុងតែបើកសវនាការនៅទីនេះដែរ។ ម្យ៉ាងវិញទៀត ការលើកឡើងរបស់ជនត្រូវចោទអំពីភាពលម្អៀងក្នុងកិច្ចស៊ើបសួរ គឺហាក់បីដូចជាត្រូវបានដោះស្រាយរួចហើយ ពោលគឺការចោទប្រកាន់នេះត្រូវបានបដិសេធ។ ដូច្នេះ លក្ខខណ្ឌទីមួយ ដូចមានចែងក្នុងវិធាន៦៣.៣(ក) មិនមានការជំទាស់ធំដុំឡើយពីជនត្រូវចោទ ហើយសហមេធាវីដើមបណ្ដឹងរដ្ឋប្បវេណី ក៏មិននិយាយអំពីចំណុចនេះជ្រៅដែរ ក៏ប៉ុន្តែលោក ដេវីដ ប្លេកមេន នឹងនិយាយចំណុចនេះបន្តពីខ្ញុំ ពាក់ព័ន្ធទៅនឹងវិធាន៦៣.៣(ក)។

អំពីចំណុចនៃវិធាន៦៣.៣(ខ) ទាំងសហចៅក្រមស៊ើបអង្កេត ទាំងជនត្រូវចោទបានទទួលស្គាល់

ខ្លឹមសារនៃវិធានផ្ទៃក្នុងដែលថា ប្រសិនបើគេរកឃើញមាន វិធាន៦៣.៣(ក) ចំណុចនៃវិធាន៦៣.៣(ក) ត្រូវបានបំពេញហើយនោះ ការបំពេញលក្ខខណ្ឌមួយក្នុងលក្ខខណ្ឌទាំងប្រាំ ដូចមានចែងនៅក្នុងវិធាន៦៣.៣(ខ) មានភាពគ្រប់គ្រាន់ដែលអនុញ្ញាតឲ្យសហចៅក្រមស៊ើបអង្កេត អាចចេញដីកាសម្រេចឃុំខ្លួន ឬដីកាសម្រេចបន្តការឃុំខ្លួនជាបណ្តោះអាសន្ន បើសិនជាស្ថិតនៅក្នុងករណីចាំបាច់។ ដូច្នេះ នៅក្នុងបណ្តឹងឧទ្ធរណ៍នេះ យើងនឹងពិភាក្សាលម្អិតតែទៅលើលក្ខខណ្ឌដូចដែលមានចែងនៅក្នុងវិធាន៦៣.៣(ខ) តែប៉ុណ្ណោះ។ នៅក្នុងដីកាបន្តការឃុំខ្លួនជាបណ្តោះអាសន្នទៅលើជនត្រូវចោទ សហចៅក្រមស៊ើបអង្កេត បានរកឃើញលក្ខខណ្ឌចំនួនបីប្រភេទ ដែលមានចែងនៅក្នុងវិធាន៦៣.៣(ខ) ត្រូវបានបំពេញ ដែលក្នុងនោះរួមមាន ការធានាអំពីវត្តមានរបស់ជនត្រូវចោទនៅក្នុងកិច្ចដំណើរការនីតិវិធី។ ទីពីរ គឺការធានាសន្តិសុខជនត្រូវចោទ ទីបី គឺការរក្សាសណ្តាប់ធ្នាប់សាធារណៈ។ ហើយដែលលក្ខខណ្ឌទាំងបីនេះត្រូវបានសំអាងយ៉ាងច្បាស់លាស់ដោយសហចៅក្រមស៊ើបអង្កេត ពោលគឺ លក្ខខណ្ឌត្រូវបានបំពេញតាំងពីចាប់ផ្តើមនីតិវិធីមក ហើយការកន្លងហួសនៃពេលវេលាមិនបានកាត់បន្ថយហានិភ័យដែលអាចនឹងកើតមានឡើយ។ សហមេធាវីជនត្រូវចោទបានលើកឡើងថា ជនត្រូវចោទជាមនុស្សចាស់ មានអាយុ៨៤ឆ្នាំ គាត់មានបញ្ហាសុខភាពធ្ងន់ធ្ងរ ដែលពិបាកធ្វើឲ្យគាត់ចលនាណាស់ ហើយមិនថាឡើយដល់ការរត់គេចខ្លួន សូម្បីតែដើរក៏ដើរមិនចង់រួចផង។

[១៤:០៨:៥៨]

សហមេធាវីដើមបណ្តឹងរដ្ឋប្បវេណី សូមធ្វើការកត់សម្គាល់ថា ជនត្រូវចោទដែលមានអាយុចាស់មិនមែនជាមូលដ្ឋានច្បាប់សម្រាប់គាំទ្រដល់ការនៅក្រៅឃុំ ឬតម្រូវឲ្យមានជម្រើសផ្សេងក្រៅអំពីការដាក់ឲ្យស្ថិតនៅក្នុងមន្ទីរឃុំឃាំងបណ្តោះអាសន្ននោះទេ ក្នុងករណីដែលមានលក្ខខណ្ឌចាំបាច់ដែលតម្រូវឲ្យការឃុំខ្លួនត្រូវតែធ្វើហើយនោះ។ ចំណែកឯបញ្ហាសុខភាពដូចដែលសហព្រះរាជអាជ្ញា បានលើកឡើងអម្បាញ់មិញ គឺថាពុំមានបញ្ហាចោទអីធំដុំឡើយនៅក្នុងកាលៈទេសៈនេះ ហើយវាហាក់បីដូចជាមានការធានាល្អជាងផង ក្នុងករណីដែលជនត្រូវចោទត្រូវបានរក្សានៅក្នុងមន្ទីរឃុំឃាំង ពីព្រោះនៅទីនេះការធានាសេវាសុខភាពមាន២៤ម៉ោង ហើយដែលជាកាតព្វកិច្ចទៅហើយចំពោះការធានាសេវាសុខភាពដល់ជនត្រូវចោទនេះ។

សហមេធាវីជនត្រូវចោទក៏បានលើកឡើងដែរផងថា ជនត្រូវចោទជាឥស្សរៈជនល្បីឈ្មោះ និងមិនទំនងអាចរត់គេចខ្លួនពីយុត្តាធិការដោយមិនអាចនឹងដឹងជាមុនបានទេ។ លើសពីនេះទៅទៀត អង្គជំនុំ

ជម្រះវិសាមញ្ញមាននគរបាលយុត្តិធម៌ និងមានអំណាចចេញដីកាចាប់ខ្លួនដែលខុសពីតុលាការព្រហ្មទណ្ឌអន្តរជាតិ អាយ.ស៊ី.ស៊ី តុលាការព្រហ្មទណ្ឌអន្តរជាតិសម្រាប់អតីតប្រទេសយោហ្គោស្លាវី អាយ.ធី.ស៊ី.វ៉ាយ ហើយនិងតុលាការព្រហ្មទណ្ឌអន្តរជាតិសម្រាប់ប្រទេសសេរ៉ាឡេអូន អាយ.ស៊ី.ធី.អ។

សហមេធាវីដើមបណ្តឹងរដ្ឋប្បវេណី សូមសម្តែងនូវការជំទាស់ទាំងស្រុងចំពោះការលើកឡើងខាងលើនេះ ព្រោះក្នុងឋានៈជាបុគ្គលដែលល្បីឈ្មោះមិនមែនមានន័យថា គាត់រត់គេចខ្លួនមិនបាននោះទេ ប៉ុន្តែក្នុងនាមជាជនត្រូវចោទដែលមានប្រវត្តិ និងបទពិសោធន៍នៃការតស៊ូបែបនេះ គឺគាត់អាចមានយុត្តិសាស្ត្រច្រើនក្នុងការបញ្ចៀសខ្លួនគាត់ឲ្យនៅឆ្ងាយពីក្រសែភ្នែករបស់អ្នកដទៃ។ ចំណែកឯការទទួលខុសត្រូវរបស់រដ្ឋក្នុងការផ្តល់មន្ត្រីនគរបាលយុត្តិធម៌ជួយការងារដល់អង្គជំនុំជម្រះវិសាមញ្ញមិនប្រាកដជាធានាបានចំពោះការមិនរត់គេចខ្លួនរបស់ជនត្រូវចោទនោះទេ។ ម៉្យាងវិញទៀត ជនត្រូវចោទហាក់បីដូចជាមានការគាំទ្រខ្លះនៅឡើយដោយប្រជាពលរដ្ឋមួយចំនួនតូច ហើយដោយរួមទាំងអាជ្ញាធរមូលដ្ឋានខ្លះទៀតផង។

ដូច្នេះ ការដាក់ឲ្យនៅក្រៅឃុំ ឬការបង្កើតជម្រើសផ្សេងនៃការឃុំ ក្រៅអំពីការឃុំខ្លួននៅក្នុងមន្ទីរឃុំឃាំង គឺជាវិធានការដ៏ប្រថុយប្រថានបំផុត ចំពោះហានិភ័យដែលនឹងអាចកើតមាន។ ក្នុងខណៈដែលបច្ចុប្បន្ននេះ ជនត្រូវចោទបានដឹងថា គាត់អាចប្រឈមមុខនឹងការកាត់ទោសឲ្យជាប់គុកពីរយៈពេល៥ឆ្នាំទៅអស់មួយជីវិត ប្រសិនបើគេរកឃើញថា គាត់មានពិរុទ្ធភាពនោះ។

[១៤:១១:៥៦]

សហមេធាវីការពារក្តីបានលើកឡើងថា គ្មានហេតុផលណាដែលនាំការព្រួយបារម្ភចំពោះសុវត្ថិ-ភាពរបស់ជនត្រូវចោទ ដោយសារមូលដ្ឋានហានិភ័យរបស់ ឌុច នោះទេ ប្រសិនបើមានអំពើហិង្សាមកលើ ឌុច នោះ ក៏ដោយសារតែ ឌុច បានសារភាពចំពោះឧក្រិដ្ឋកម្មរបស់ខ្លួននៅក្នុងពេលសវនាការ និងបានផ្សព្វផ្សាយជាសាធារណៈអំពីព័ត៌មាននេះ។ មេធាវីការពារក្តីបានបន្ថែមថា ជនត្រូវចោទមិនបានសារភាពចំពោះឧក្រិដ្ឋកម្មណាមួយនោះទេ ហើយដោយសារតែការជំនុំជម្រះក្តីមកលើជនត្រូវចោទ មិនទាន់បានចាប់ផ្តើមនៅឡើយនោះ។ ការផ្សព្វផ្សាយជុំវិញឧក្រិដ្ឋកម្ម ដែលបានចោទប្រកាន់លើរូបគាត់មានភាពធូរស្រាលជាងរឿង ឌុច អាស្រ័យហេតុនេះ ការគំរាមកំហែងមកលើ ឌុច មិនអាចយកមកប្រៀបធៀបជាមួយនឹងការគំរាមកំហែងមកលើជនត្រូវវចោទនោះទេ។

សហមេធាវីដើមបណ្តឹងរដ្ឋប្បវេណី បានមើលឃើញផ្ទុយពីនេះវិញ ដោយសារមេធាវីការពារក្តី

បានទទួលស្គាល់រួចមកហើយថា ជនត្រូវចោទគឺជាបុគ្គលដែលល្បីឈ្មោះ ដូច្នេះមានន័យថា ជនត្រូវចោទត្រូវបានគេស្គាល់គ្រប់ទីកន្លែង ហើយបច្ចុប្បន្នហាក់បីដូចជា ស្ថិតនៅក្នុងក្រសែភ្នែករបស់មនុស្សទូទៅផង សារព័ត៌មានជាច្រើនបានផ្សព្វផ្សាយទាំងសំឡេង ទាំងរូបភាពរបស់ជនត្រូវចោទក្នុងតួនាទីដ៏ខ្ពស់ និងមានអំណាចរបស់ជនត្រូវចោទក្នុងរបបកម្ពុជាប្រជាធិបតេយ្យ បានធ្វើឱ្យប្រជាពលរដ្ឋផ្តោតការចាប់អារម្មណ៍កាន់តែខ្លាំងទៅៗ។

ការមិនឆ្លើយសារភាពអំពីឧក្រិដ្ឋកម្មដែលត្រូវបានចោទប្រកាន់មិនមែនមានន័យថា ជាហេតុផលដែលនាំមកនូវភាពស្ងប់ស្ងាត់ ឬការផ្សះផ្សានោះទេ ប៉ុន្តែវាអាចកាន់តែជាការបង្កើននូវការឈឺចាប់ខ្លាំងជាងមុន ដល់ជនរងគ្រោះទូទាំងប្រទេស ពីព្រោះតែជនត្រូវចោទដែលមានតួនាទីជាមេដឹកនាំដ៏មានឥទ្ធិពលកាលពីសម័យនោះ ហើយដែលពេលនោះកើតមានឧក្រិដ្ឋកម្មជាច្រើននៅទូទាំងប្រទេសកម្ពុជាបែរជាជនត្រូវចោទសម្តែងនូវការមិនដឹងមិនឮ និងមិនបានសហការជាមួយអង្គជំនុំជម្រះវិសាមញ្ញសោះ។ ម្យ៉ាងវិញទៀត បើយើងប្រៀបធៀប អំពីតួនាទី និងការទទួលខុសត្រូវរវាងជនត្រូវចោទជាមួយនឹង ឌុច គឺថាជនត្រូវចោទមានការទទួលខុសត្រូវខ្ពស់ជាង ពីព្រោះគាត់ជាប់ពាក់ព័ន្ធជាមួយនឹងឧក្រិដ្ឋកម្មយ៉ាងទូលំទូលាយ ជាពិសេសគឺឧក្រិដ្ឋកម្មដែលកើតមាននៅក្នុងប្រទេសកម្ពុជាក្នុងសម័យកម្ពុជាប្រជាធិបតេយ្យ។

សហមេធាវីដើមបណ្តឹងរដ្ឋប្បវេណី សូមសម្តែងនូវការជំទាស់ផងដែរ ចំពោះការអះអាងរបស់សហមេធាវីការពារក្តីដែលថា ប្រសិនបើ ឌុច ត្រូវបានតុលាការផ្តន្ទាទោសនោះ រំពឹងថាចំណុចនេះនឹងជួយសម្រាលនៃការខឹងសម្បាដែលអាចមានក្នុងចំណោមសាធារណជន។ សហមេធាវីដើមបណ្តឹងរដ្ឋ-ប្បវេណីកត់សម្គាល់ឃើញថា ការទន្ទឹមរង់ចាំជិតសាមសិបឆ្នាំរបស់ប្រជាពលរដ្ឋខ្មែរ ចំពោះការកាត់ទោសទៅលើឧក្រិដ្ឋកម្មដែលកើតមានក្នុងសម័យកម្ពុជាប្រជាធិបតេយ្យ មិនមែនគាត់រំពឹងតែការកាត់ទោសទៅលើ ឌុច នោះទេ ក៏ប៉ុន្តែគាត់ចង់ដឹងពីព្រោះគាត់ស្គាល់ អ្នកដែលមានតួនាទីជាន់ខ្ពស់កាលពីសម័យនោះ។ ដូច្នេះ គាត់ចង់ដឹង គាត់រង់ចាំនូវការកាត់ទោសមេដឹកនាំជាន់ខ្ពស់ដែលបច្ចុប្បន្នស្ថិតនៅក្រោមការចោទប្រកាន់នៅក្នុងសំណុំរឿង០០២នេះឯង។

សហមេធាវីដើមបណ្តឹងរដ្ឋប្បវេណីកត់សម្គាល់ឃើញថា ការបន្តឃុំខ្លួនជនត្រូវចោទនៅតែជាវិធានការចាំបាច់ដើម្បីរក្សាសណ្តាប់ធ្នាប់សាធារណៈ។ សហមេធាវីការពារក្តីបានលើកឡើងថា ការឃុំខ្លួនមុនការជំនុំជម្រះក្តីមិនអាចត្រូវបានយកមកពិចារណា ជាការផ្តន្ទាទោសមុនការកាត់សេចក្តីនោះទេ ហើយក៏មិនត្រូវយកមកប្រើប្រាស់សម្រាប់គោលបំណងដាក់ទណ្ឌកម្មនោះឡើយ។ សហមេធាវីដើម

បណ្ដឹងរដ្ឋប្បវេណីទទួលស្គាល់ចំណុចនេះ ប៉ុន្ដែដីកាសម្រេចការឃុំខ្លួនដែលចេញដោយសហចៅក្រមស៊ើបអង្កេត និងសំអាងហេតុនៅក្នុងដីកានេះ មិនមែនជាសារធាតុនៃបុរេនិច្ឆ័យចំពោះការផ្ដន្ទាទោសជនត្រូវចោទនាពេលអនាគតនោះទេ។ វាគឺជាឆន្ទានុសិទ្ធិផ្ដាច់មុខរបស់សហចៅក្រមស៊ើបអង្កេតដែលមើលឃើញអំពីកាលៈទេសៈចាំបាច់ក្នុងការរក្សាសណ្ដាប់ធ្នាប់សាធារណៈ។ ម្យ៉ាងវិញទៀត តាំងពីមានចេញសេចក្ដីសម្រេចរបស់អង្គបុរេជំនុំជម្រះ ស្ដីអំពីការបន្ដការឃុំខ្លួនជនត្រូវចោទថ្ងៃទី២៦ ខែមិថុនា ឆ្នាំ ២០០៩ មក យើងពុំឃើញមានអ្វីថ្មី ដែលធ្វើឲ្យលក្ខខណ្ឌ ដែលនាំឲ្យមានការឃុំខ្លួនជនត្រូវចោទមានការប្រែប្រួលនោះទេ។ ហើយសហមេធាវីដើមបណ្ដឹងរដ្ឋប្បវេណី សូមលើកឡើងថា ទិដ្ឋភាពនៃការចាប់អារម្មណ៍របស់សាធារណជននៅក្នុងសំណុំរឿងថ្មីៗ ក្រោយៗនេះមិនអាចធ្វើការប្រៀបធៀបជាមួយនឹងសំណុំរឿងជនត្រូវចោទនេះបានឡើយ ពីព្រោះវាមានភាពខុសគ្នាទាំងភាពសម្ងាត់នៅក្នុងសំណុំ ពេលវេលានៃការស៊ើបអង្កេត ទំហំ និងការទទួលខុសត្រូវរបស់ជនត្រូវចោទ។

សហមេធាវីការពារក្ដីបានលើកឡើងថា សហចៅក្រមស៊ើបអង្កេតបានរំលោភលើឆន្ទានុសិទ្ធិរបស់ខ្លួនដោយខកខានមិនបានពិចារណាទៅលើជម្រើសឃុំឃាំងដែលមានលក្ខណៈធូរស្រាលជាងការដាក់នៅក្នុងមន្ទីរឃុំឃាំងបច្ចុប្បន្ន។ សហមេធាវីដើមបណ្ដឹងរដ្ឋប្បវេណីយល់ឃើញថា ការវាយតម្លៃរបស់សហមេធាវីការពារក្ដីខាងលើដែលថាសហចៅក្រមស៊ើបអង្កេត-- បាទ សុំទោស បាទ។

[១៤:១៨:៣៤]

សហមេធាវីដើមបណ្ដឹងរដ្ឋប្បវេណីកត់សម្គាល់ឃើញថា ការឃុំខ្លួនជនត្រូវចោទនៅក្នុងផ្ទះមិនមែនជាជម្រើសដ៏ល្អដើម្បីធានាចំពោះសន្ដិសុខជនត្រូវចោទ និងសណ្ដាប់ធ្នាប់សាធារណៈទេ បើទោះបីជាមានការដាក់កងកម្លាំងប្រដាប់អាវុធយាមកាមយ៉ាងណាក្ដី។ ម្យ៉ាងវិញទៀត ការយល់ដឹងរបស់សាធារណជនអំពីលក្ខខណ្ឌ និងនីតិវិធីច្បាប់នៅមានកម្រិតនៅឡើយ ជាពិសេសពួកគាត់អាចយល់ច្រឡំដែរថា ការដាក់ឃុំឃាំងជនត្រូវចោទនៅក្នុងផ្ទះ គឺជាការដោះលែងជនត្រូវចោទឲ្យមានសេរីភាព នៅពេលនោះអាចនឹងមានសកម្មភាពអ្វីមួយដែលជាការធ្វើឲ្យប៉ះពាល់សណ្ដាប់ធ្នាប់សាធារណៈ ហើយដែលបង្កដល់រដ្ឋាភិបាលដែលពិបាកក្នុងការគ្រប់គ្រងស្ថានការណ៍។

សហមេធាវីដើមបណ្ដឹងរដ្ឋប្បវេណី សូមលើកឡើងផងដែរថា ការដាក់ឲ្យស្ថិតនៅក្រោមការត្រួតពិនិត្យតាមផ្លូវតុលាការ មិនមែនជាទម្រង់នៃការឃុំខ្លួនទេ ពីព្រោះនៅក្នុងបណ្ដឹងឧទ្ធរណ៍ជាលាយលក្ខណ៍អក្សររបស់សហមេធាវីការពារក្ដីក៏បានលើកឡើងផងដែរថា ដែលថាសហចៅក្រមស៊ើបអង្កេត

គួរតែមានជម្រើសផ្សេង ដែលក្នុងនោះមានការឃុំខ្លួននៅក្នុងផ្ទះ ឬមួយក៏ការដាក់ឲ្យស្ថិតនៅក្រោមការត្រួតពិនិត្យរបស់តុលាការ ដែលអាចបង្គាប់ឲ្យមានការដាក់ប្រាក់ធានា និងចងលក្ខខណ្ឌផ្សេងៗទៀត ដើម្បីធានានូវវត្តមានរបស់ជនត្រូវចោទនៅក្នុងដំណើរការនីតិវិធី និងការពារជនដទៃទៀត។

ដូច្នេះសហមេធាវីដើមបណ្តឹងរដ្ឋប្បវេណី យល់ឃើញថា ការដាក់ជនត្រូវចោទឲ្យស្ថិតនៅក្រោមការត្រួតពិនិត្យរបស់តុលាការមិនមែនជាទម្រង់នៃការឃុំខ្លួនទេ ប៉ុន្តែជាការដោះលែងជនត្រូវចោទឲ្យបាននៅក្រៅឃុំ ហើយចំណុចនេះ វាបង្កើតនូវហានិភ័យកាន់តែធ្ងន់ជាងការដាក់ជនត្រូវចោទឲ្យនៅឃុំខ្លួននៅក្នុងផ្ទះទៀត។ ដូច្នេះយើងយល់ឃើញថា វាមិនអាចធានាបានចំពោះលក្ខខណ្ឌដូចដែលមានចែងនៅក្នុងវិធាន៦៣.៣(ខ)នោះទេ។ សហមេធាវីដើមបណ្តឹងរដ្ឋប្បវេណីកត់សម្គាល់ឃើញថា នៅក្នុងបណ្តឹងឧទ្ធរណ៍ជាលាយលក្ខណ៍អក្សររបស់ខ្លួន ជនត្រូវចោទមិនបានស្នើសុំឲ្យមានជម្រើសសម្រាប់ការឃុំខ្លួននោះទេ ប៉ុន្តែការស្នើសុំជាមូលដ្ឋានរបស់គាត់គឺសុំមោឃភាពដីកាបន្តការឃុំខ្លួន និងការដោះលែងខ្លួនគាត់ចេញពីមន្ទីរឃុំឃាំង។ សហមេធាវីការពារក្តីបានលើកឡើងជាច្រើនដងអំពីសេរីភាពជាសារវន្ត និងសច្ចធារណ៍នៃនិរទោសដែលជាមូលដ្ឋានគាំទ្រដល់ការមិនឃុំខ្លួន ឬក៏ការដោះលែងជនត្រូវចោទឲ្យនៅពីមន្ទីរឃុំឃាំងជាបណ្តោះអាសន្ន ដោយហាក់បីដូចជាដាក់កំហុសទៅដល់សហចៅក្រមស៊ើបអង្កេតថាមិនបានពិចារណាចំណុចនេះ និងចំណុចផ្សេងមួយចំនួនទៀតដែលបានលើកឡើងនៅខាងលើ។

[១៤:២១:៥៩]

ចំណុចនៅទីបញ្ចប់ សហមេធាវីការពារក្តីបានស្នើទៅអង្គបុរេជំនុំជម្រះ ឲ្យបដិសេធចោលដីកាបន្តការឃុំខ្លួន និងការបញ្ចប់ការឃុំខ្លួនជនត្រូវចោទ ពោលគឺមិនបានស្នើសុំទៅអង្គបុរេជំនុំជម្រះឲ្យពិចារណាចំពោះជម្រើសផ្សេងក្រៅអំពីការឃុំខ្លួននៅក្នុងពន្ធនាគារនោះទេ។ នេះអ្វីដែលបានសរសេរជាលាយលក្ខណ៍អក្សរនៅក្នុងបណ្តឹងឧទ្ធរណ៍។ ជាការពិតណាស់សហមេធាវីដើមបណ្តឹងរដ្ឋប្បវេណីយល់ឃើញប្រហាក់ប្រហែលគ្នាដែរ ដែលថាសេរីភាពជាសារវន្ត និងសច្ចធារណ៍នៃនិរទោសត្រូវមានជាប់ជាមួយនឹងជនត្រូវចោទទូទៅ ប៉ុន្តែគោលការណ៍នេះត្រូវបានលើកលែងជាមួយនឹងឧក្រិដ្ឋកម្មធ្ងន់ធ្ងរដែលថាការដាក់ជនត្រូវចោទឲ្យនៅក្រៅឃុំ ឬការបង្កើតជម្រើសផ្សេងអំពីការឃុំខ្លួននៅក្នុងមន្ទីរឃុំឃាំង អាចបង្កឲ្យមានហានិភ័យដល់ជនត្រូវចោទខ្លួនឯងផ្ទាល់ ឬសណ្តាប់ធ្នាប់សាធារណៈ ឬបង្កឲ្យមានបញ្ហានៃដំណើរការប្រព្រឹត្តិទៅដ៏រលូនរបស់អង្គជំនុំជម្រះវិសាមញ្ញ។

ម្យ៉ាងវិញទៀត ក្រៅអំពីភាពធ្ងន់ធ្ងរនៃឧក្រិដ្ឋកម្មដែលជាប់ពាក់ព័ន្ធជាមួយជនត្រូវចោទនេះ ភាព

ស្មុគស្មាញនៃសំណុំរឿងនិងការស៊ើបអង្កេតក៏ជាកត្តាមួយដែលតម្រូវឲ្យការស៊ើបអង្កេត ឬក៏ប្រើប្រាស់ពេលវេលាក្នុងការឃុំខ្លួនធ្វើឡើងឲ្យបានសមស្របផងដែរ។ ក្នុងករណីនេះ សហមេធាវីដើមបណ្ដឹងរដ្ឋប្បវេណីសូមអះអាងឡើងវិញថា ការអនុវត្តឆន្ទានុសិទ្ធិរបស់ចៅក្រមស៊ើបអង្កេត ក្នុងការសម្រេចចេញដីកាបន្តការឃុំខ្លួនជនត្រូវចោទជាបណ្ដោះអាសន្ន គឺមានភាពសមស្រប និងមានយុត្តិកម្ម។

សហមេធាវីដើមបណ្ដឹងរដ្ឋប្បវេណីសុំធ្វើការឆ្លើយតបពីរចំណុចទៀតដោយខ្លី ដែលសហមេធាវីការពារក្ដីបានលើកឡើង ហើយដែលគាត់មិនបានសរសេរនៅក្នុងបណ្ដឹងឧទ្ធរណ៍របស់គាត់។

ចំណុចទី១ គឺសហមេធាវីការពារក្ដី គឺលោក អាង ឧត្ដម បានលើកឡើងអំពីយុត្តិសាស្ត្រដែលគេប្រើចំពោះរឿងក្ដីឧក្រិដ្ឋកម្មមនុស្សឃាត ដែលជនល្មើសបានធ្វើឃាតទៅលើអតីតប្រធានសហជីពកម្មករ គឺលោក ជា វិជ្ជា។ ការពិតរវាងសំណុំរឿងឃាតកម្មដែលត្រូវបានធ្វើឡើងនៅខាងក្រៅប្រព័ន្ធតុលាការ អ៊ី.ស៊ី.ស៊ី.ស៊ី និងរឿងក្ដីរបស់ជនត្រូវចោទ ដែលកំពុងបើកសវនាការនៅថ្ងៃនេះ គឺវាមានភាពខុសគ្នាទាំងស្រុង។

[១៤:២៨:៥១]

ទីមួយ ឧក្រិដ្ឋកម្មដែលត្រូវបានធ្វើឡើងទៅលើអតីតប្រធានសហជីព ជា វិជ្ជា គឺជាឧក្រិដ្ឋកម្មធម្មតា បើទោះបីជាវាមានលក្ខណៈធ្ងន់ធ្ងរ ប៉ុន្តែកម្រិត នៃទំហំនៃឧក្រិដ្ឋកម្មនេះគឺជាឧក្រិដ្ឋកម្មមនុស្សឃាតធម្មតា ហើយជនត្រូវចោទ ជាពិសេសគឺជនរងគ្រោះ គឺលោក ជា វិជ្ជា តែម្នាក់ឯង។ ផ្ទុយមកវិញឧក្រិដ្ឋកម្មដែលត្រូវបានចោទប្រកាន់លើជនត្រូវចោទដែលស្ថិតនៅក្នុងយុត្តាធិការរបស់ អ៊ី.ស៊ី.ស៊ី.ស៊ី ជាឧក្រិដ្ឋកម្មអន្តរជាតិ ហើយការចោទប្រកាន់វាមានទំហំធំជនរងគ្រោះ យើងមិនបានធ្វើការប្រៀបធៀប ឬវាយតម្លៃចំពោះអាយុជីវិតតិច ឬច្រើនបានទេ ប៉ុន្តែយើងអាចវាយតម្លៃទៅលើទំហំនៃឧក្រិដ្ឋកម្ម។ ដូច្នេះ វាមិនអាចទៅរួចទេ ដែលយើងយករឿងទាំងពីរនេះយកមកធ្វើការប្រៀបធៀបគ្នា ហើយម្យ៉ាងវិញទៀតលោកសហព្រះរាជអាជ្ញាក៏បានលើកឡើងហើយថា ដែលថាជនត្រូវចោទ ដែលគេសម្រេចឲ្យនៅក្រៅឃុំ គឺវាត្រូវបានគេរកឃើញថា អត់ជាប់ពាក់ព័ន្ធទៅនឹងឧក្រិដ្ឋកម្ម។

ចំណុចមួយទៀតដែលលោក ម៉ៃខល កាណាវាស បានលើកឡើង គាត់បានប្រៀបធៀបរវាងចំណាត់ការរបស់រដ្ឋាភិបាលខ្មែរទៅលើអាការប្រើប្រាស់កម្លាំងការពារទឹកដីខ្មែរ ហើយនិងចំណាត់ការរបស់អង្គជំនុំជម្រះ បើអាចទៅរួចក្នុងការការពារជនត្រូវចោទនៅពេលដែលគាត់ត្រូវបានសម្រេចឲ្យនៅក្នុងឃុំខ្លួននៅក្នុងផ្ទះនោះ គឺថាវាក៏មិនអាចធ្វើការប្រៀបធៀបគ្នាដែរ ពីព្រោះរឿងការការពារទឹកដី គឺជា

រឿងរបស់ជាតិ ដែលរដ្ឋគឺជាកម្មវត្ថុនៅក្នុងរឿងនេះ ក៏ប៉ុន្តែរឿងជនត្រូវចោទ គឺតុលាការជាអ្នកទទួលខុសត្រូវ។ ដូច្នេះ មានតែតុលាការទេ ដែលជាអ្នកយល់ឃើញដោយឯករាជ្យ ដែលជាអ្នកវិនិច្ឆ័យបានចំពោះហានិភ័យដែលអាចនឹងកើតឡើង ប្រសិនបើជនត្រូវចោទអាចសម្រេចឲ្យត្រូវបាននៅក្រៅឃុំ ឬក៏ឃុំខ្លួននៅក្នុងផ្ទះ។

ដូច្នេះ ក្នុងនាមសហមេធាវីដើមបណ្តឹងរដ្ឋប្បវេណីជាតិ ខ្ញុំសូមបញ្ចប់តែប៉ុណ្ណឹង ហើយស្នើសុំទៅអង្គបុរេជំនុំជម្រះអនុញ្ញាតដល់លោក ដេវីដ ប្លេកមេន ដែលដែលសហមេធាវីអន្តរជាតិបន្តពីរូបខ្ញុំ អំពីការឆ្លើយតបចំពោះបណ្តឹងឧទ្ធរណ៍នេះ។ សូមអរគុណ។

[១៤:២៧:២៥]

**ចៅក្រម ខាទីនខា ឡាហ៊ូស៖**

ខ្ញុំសូមបញ្ជាក់បំភ្លឺ ទាក់ទងទៅនឹងឯកសារដែលបានដាក់ឡើង ដោយសហព្រះរាជអាជ្ញា អង្គបុរេជំនុំជម្រះ គឺចង់ឲ្យភាគីទាំងអស់ផ្តល់យោបល់នៅក្នុងអំឡុងពេលសវនាការនេះ។ ដូច្នេះហើយឆ្លើយតបទៅនឹងសំណើរបស់យើងខ្ញុំ គឺលោកបានធ្វើការផ្តល់យោបល់រួចហើយទាក់ទងទៅនឹងឯកសារនោះ។ នាពេលនេះសវនាការសុំធ្វើការសម្រាករយៈពេល១៥នាទី ដូចដែលបានគ្រោងទុក។ សូមអរគុណ។

**លោក ឈន ព្រលឹង៖**

សូមអញ្ជើញក្រោកឈរ!

*[សវនាការសម្រាកពីម៉ោង ១៤:២៨នាទី ដល់ម៉ោង ១៤:៤៥នាទី]*

**លោក ឈន ព្រលឹង៖**

សូមអញ្ជើញក្រោកឈរ! តុលាការចូលកាន់សាលសវនាការ។

**ប្រធានអង្គបុរេ៖**

សូមអញ្ជើញអង្គុយចុះបាទ! សូមអញ្ជើញបាទ!

**លោក ដេវីដ ប្លេកមេន៖**

លោក លោកស្រីចៅក្រម លោកប្រធានដើមបណ្តឹងរដ្ឋប្បវេណី, ខ្ញុំមានកិត្តិយសធ្វើសេចក្តីសន្និដ្ឋាននៅថ្ងៃនេះក្នុងនាមប្រជាពលរដ្ឋដែលខ្ញុំតំណាង ដោយក្នុងនោះរួមប្រជាពលរដ្ឋកម្ពុជាសញ្ជាតិអាមេរិក

ផងដែរ។ ក្នុងការបំពេញការងាររយៈពេល៣៨ឆ្នាំ នៅចំពោះមុខចៅក្រមខ្ញុំបានចូលរួមការពារ ឃាតក ចោរប្លន់ និងឧក្រិដ្ឋជនគ្រប់ប្រភេទ និងធ្លាប់បានតំណាងជនរងគ្រោះពីព្យសនៈកម្មដោយសារជាតិពល ចេញពីបំពង់ផ្សែងរោងចក្រឧស្សាហកម្ម។ ប៉ុន្តែ ខ្ញុំត្រូវនិយាយថា ខ្ញុំត្រូវនិយាយនៅចំពោះមុខសាលាក្ដី អន្តរជាតិនេះថា ខ្ញុំមានអារម្មណ៍ភ័យញ័រដូចឆ្មាដើរលើដំបូលស័ង្កសីដ៏ក្ដៅ។ វាមិនមែនជាសវនាការដែល ខ្ញុំធ្លាប់ចូលរួមដូចពីមុនទេ ប៉ុន្តែខ្ញុំមានកិត្តិយសដែលបានចូលរួម។

កាលពីបីឆ្នាំមុន ខ្ញុំមកប្រទេសកម្ពុជាចូលរួមក្នុងរឿងក្ដីឧក្រិដ្ឋកម្មជាតិប្រឆាំងមនុស្សជាតិដ៏ធ្ងន់ ធ្ងរមួយក្នុងចំណោមឧក្រិដ្ឋកម្មធ្ងន់ធ្ងរទាំងឡាយនៅលើពិភពលោក ដែលប្រព្រឹត្តដោយបក្សកុម្មុយនីស្ត កម្ពុជា។ ក្នុងរយៈពេលបីឆ្នាំនេះ ខ្ញុំបានអានដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរ ព្យាយាមពិនិត្យសំណុំ រឿង ស្ដាប់រឿងរ៉ាវផ្ទាល់ខ្លួនរបស់ជនរងគ្រោះ។ វាដូចជាគ្មាននរណាម្នាក់នៅក្នុងប្រទេសកម្ពុជាបានគេច ផុតពីរបបកម្ពុជាប្រជាធិបតេយ្យនេះទេ។ សាមសិបឆ្នាំក្រោយមកនេះ ប្រជាជនរាប់លាននាក់នៅតែជិត ជាប់ស្នាមដំបៅនៃឧក្រិដ្ឋកម្មទាំងឡាយដែលបានចោទប្រកាន់ថាបានប្រព្រឹត្តដោយជនត្រូវចោទ។ ហើយ ជនរូបនេះបានស្នើសុំឲ្យចៅក្រមកុំភ្លេចសិទ្ធិមានសេរីភាព និងសច្ចាធារណ៍និរទោសរបស់គាត់។ ជនរូប នេះស្នើសុំចំណុចនេះតាមរយៈមេធាវីការពារក្ដីរបស់ខ្លួន ហើយសុំឲ្យមានការអាណិតអាសូរ។ លោក កាណាវាស បានលើកឡើងអំពីនីតិវិធីក្នុងការរកយុត្តិធម៌ ប៉ុន្តែចំណាយពេលច្រើននិយាយអំពីការគ្មាន ភ័ស្តុតាងសំខាន់។ ប្រជាពលរដ្ឋកម្ពុជាសញ្ជាតិអាមេរិកមានជំងឺផ្លូវចិត្ត និងផ្លូវកាយដែលពេលវេលាមិន អាចព្យាបាលបាន។ ពួកគេបាត់បង់គ្រួសារ កូនចៅដោយសារការអត់បាយ និងភាពឃោរឃៅ។ ពួកគេ ត្រូវបានបង្ខិតបង្ខំមិនឲ្យមានសេចក្ដីស្រលាញ់ មិនឲ្យខ្វល់ពីមនុស្សម្នា។

[១៤:៤៧:៣៧]

លោក អៀង សារី មានអាយុ ៨៤ឆ្នាំ។ នៅក្នុងមន្ទីរឃុំឃាំង អ.វ.ត.ក ជនត្រូវចោទទទួលបាន ការយកចិត្តទុកដាក់ល្អបំផុត។ ហើយវាជាឱកាសល្អមួយដែលគាត់អាចរៀបចំខ្លួនដ៏សមស្រប ហើយ អាចចូលរួមសវនាការក្នុងជារៀងរាល់ថ្ងៃ ជារៀងរាល់ខែ ជារៀងរាល់ឆ្នាំនៅក្នុងរឿងក្ដីនេះ។ ថាតើយើង អាចគិតដែរឬទេប្រសិនបើគេដោះលែងឲ្យគាត់នៅផ្ទះ ហើយមានប៉ូលិសយាម មានមន្ត្រីនគរបាល យាម ថាតើមានជនរងគ្រោះគាត់នឹងធ្វើយ៉ាងម៉េច? ជនរងគ្រោះនឹងឃើញជនត្រូវចោទទទួលបាននូវសិទ្ធិ សេរីភាពដើរតាមផ្លូវមានគេយាម។ ដូច្នេះ នេះវាជាចំណុចមួយដែលវាទាក់ទងនឹងការឃុំខ្លួននៅផ្ទះ។ ហើយជនត្រូវចោទមិនអាចរៀបចំខ្លួននៅព្រឹកព្រលឹមបានដើម្បីចូលរួមសវនាការ។ ដូច្នេះ សំណើសុំ

ដូច្នោះវាមិនអាចទទួលយកបាន ហើយមិនអាចមានភាពសមស្របនៅក្នុងដំណាក់កាលនេះ។ ដូចដែលតុលាការនេះបានសម្រេចពីរដងរួចមកហើយ ភាពធ្ងន់ធ្ងរនៃឧក្រិដ្ឋកម្មដែលចោទប្រកាន់មានសារសំខាន់ ហើយមានហេតុផលត្រឹមត្រូវជឿថា ជនត្រូវចោទបានប្រព្រឹត្តឧក្រិដ្ឋកម្មទាំងនេះ។

នៅក្នុងរឿងក្តីនេះ ជនត្រូវចោទ អៀង សារី គឺជាមេដឹកនាំខ្មែរក្រហមមួយរូបផងដែរ។ យើងមិនអាចតវ៉ាទៅលើចំណុចនេះបានទេ។ ចំពោះរូបខ្ញុំ ចំពោះមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី កត្តាដែលសំខាន់បំផុតនោះគឺធានាឲ្យជនត្រូវចោទមានវត្តមានរៀងរាល់ថ្ងៃរហូតដល់ថ្ងៃចេញសាលក្រមដែលនៅពេលនោះ ជំពូកខ្មៅនៅក្នុងប្រវត្តិសាស្ត្រខ្មែរបានរលាយបាត់ ហើយឲ្យជីវិតទាំងឡាយអាចបន្តទៅមុខទៀត ហើយធ្វើឲ្យស្រមោលខ្មែរក្រហមបាត់រលាយសូន្យក្លាយទៅជាពន្លឺថ្មីឡើងវិញ។

ថ្ងៃដ៏ភ្លឺស្វាងនេះកំពុងចូលមកដល់ហើយ ហើយការឃុំខ្លួននៅមន្ទីរឃុំឃាំងរបស់អ.វ.ត.ក រហូតដល់ថ្ងៃនោះគឺធានាដើម្បីឲ្យគាត់អាចចូលរួម។ ការឃុំខ្លួននៅផ្ទះ ឬទម្រង់ផ្សេងនឹងរារាំងដល់ការបញ្ចប់នីតិវិធីនេះដោយជោគជ័យ។ ដូច្នេះ ខ្ញុំសូមស្នើសុំក្នុងនាមដើមបណ្តឹងរដ្ឋប្បវេណី ខ្ញុំសូមស្នើសុំឲ្យបដិសេធចោលសំណើសុំឲ្យដាក់ឃុំខ្លួននៅក្នុងផ្ទះ ដោយយើងមិនអាចចោទជាសំណួរថាហេតុអ្វីបានឡើយ គ្រាន់តែខ្ញុំស្នើសុំឲ្យបដិសេធសំណើនេះចោល។ សូមអរគុណ។

ខ្ញុំបានស្នើសុំដោយឲ្យលើកឡើង ថាសហសេវិករបស់ខ្ញុំស្នើសុំឲ្យលើកឡើងអំពីរឿងក្តីដែលថាទាក់ទងទៅនឹងតុលាការក្នុងស្រុកនោះ។ បញ្ហានោះគឺវាមិនមានសារសំខាន់នោះទេ។ ប៉ុន្តែ គ្រាន់តែគេបដិសេធនៅការសម្រេចនៅពេលនោះ នៅក្នុងតុលាការក្នុងស្រុក សូមអរគុណ។

ប្រធានអង្គបុរេ៖

សូមអញ្ជើញលោកមេធាវីជនត្រូវចោទឡើងធ្វើការឆ្លើយតប។

**លោក ម៉ៃខល ការណាវ៉ាស៖**

សូមអរគុណលោកប្រធាន។ សូមជម្រាបសួរលោក លោកស្រីចៅក្រម អង្គបុរេជំនុំជម្រះ និងសាធារណជន សហព្រះរាជអាជ្ញា។ ខ្ញុំនឹងនិយាយដោយសង្ខេប ហើយខ្ញុំនឹងនិយាយអំពីចំណុចនីមួយៗ ខ្ញុំសង្ឃឹមថាក្នុងរយៈពេលប្រាំមីនុតខ្ញុំអាចធ្វើដូច្នោះបាន។ ខ្ញុំសូមអនុញ្ញាតចាប់ផ្តើមជាបឋមអំពីទឡ្ហីករណ៍ដែលថាជាការអះអាងមួយចំនួនដែលយើងបានប្តូរតាក់ទិកខុសពីមុន ប្រសិនបើយើងមើលនៅក្នុងទឡ្ហីករណ៍ជាសារណារបស់យើង យើងបានស្នើសុំយ៉ាងហោចណាស់ជាវិធានការជំនួសដែលថាខុសពីការឃុំខ្លួននៅទីនេះ។ ដូច្នេះ ខ្ញុំជឿថាសេចក្តីសន្និដ្ឋានរបស់យើងនៅថ្ងៃនេះគឺស្របជាមួយអ្វីដែលយើងបានដាក់ជូន

នៅក្នុងបណ្តឹងឧទ្ធរណ៍នេះ ហើយស្នើសុំឲ្យមានការឃុំខ្លួននៅក្នុងផ្ទះគឺជាទម្រង់នៃការឃុំខ្លួន គឺជាវាមានលក្ខណៈធូរស្រាលជាងការឃុំខ្លួននាបច្ចុប្បន្ននេះ។ ប៉ុន្តែ ខ្ញុំជឿជាក់ថា យើងបានបញ្ជាក់ នៅក្នុងបណ្តឹងសាទររបស់យើងខ្ញុំហើយ។ ដូច្នេះហើយមានសមស្របដែលយើងបានបញ្ជាក់ជាថ្មីម្តងទៀតនៅទីនេះ។ ការឃុំខ្លួនក្នុងផ្ទះ ខ្ញុំមានការភ្ញាក់ផ្អើលណាស់ដែលថា សហព្រះរាជអាជ្ញានៅក្នុងនោះ បានលើកឡើងរឿងក្តី*ប្លាស្កេច* គាត់ជាសមាជិកនៃជម្រើសមួយដែលសហព្រះរាជអាជ្ញា អាយ.ស៊ី.ធី.វ៉ាយ ហើយគាត់បានអះអាងថា នៅ*ប្លាស្កេច* នេះដែលគាត់បានលើកឡើងនេះគឺថាវាមានលក្ខណៈពិសេស។ តាមដែលខ្ញុំចាំត្រឹមត្រូវនោះគឺ *ប្លាស្កេច នោះ*គឺត្រូវបានអនុញ្ញាតឲ្យនៅឃុំខ្លួនក្នុងផ្ទះនៅប្រទេសហុល្លង់។ ប៉ុន្តែជីវិតនៅទីនោះគឺថា យើងមានកិច្ចព្រមព្រៀងជាមួយអង្គការសហប្រជាជាតិ។ ផ្នែកមួយនៃកិច្ចព្រមព្រៀងនោះថា ជនជាប់ចោទមួយណាហ្នឹងត្រូវឃុំខ្លួន មិនមានទម្រង់នៃការនៅក្រៅឃុំ ដោយធានានោះនៅពេលដែលជនជាប់ចោទត្រូវបាននៅក្នុងហុល្លង់ដោយសារលក្ខខណ្ឌសុវត្ថិភាព។ ដូច្នេះហើយវាក៏បានលើកឡើងនៅក្នុង *បាកូយ៉ូហ្វិច* នោះដែរ នៅពេលអង្គជំនុំជម្រះក្នុងចំណុចមួយដែល ថាអាចនឹងអនុញ្ញាតឲ្យនៅក្រៅឃុំជាបណ្តោះអាសន្ន ប៉ុន្តែរដ្ឋាភិបាលហុល្លង់បានបញ្ជូនតំណាងទៅអង្គបុរេជំនុំជម្រះ ប៉ុន្តែគេមិនមានសមត្ថភាពនឹងដោះលែងឲ្យនៅក្រៅឃុំ ដោយសារមានកិច្ចព្រមព្រៀងបែបនេះ។ ក្នុងករណីនោះគឺមិនសមស្របក្នុងករណីយើងទេព្រោះនៅក្នុងរឿងក្តី ប្លាស្កេច នេះវិញគឺថាវាមានលក្ខណៈគួរឲ្យចាប់អារម្មណ៍ណាស់។ ហើយជាថ្មីម្តងទៀត ដែលខ្ញុំចាំនោះគឺនៅក្នុងឆ្នាំ២០០១, ២០០២ និង២០០៣ នៅក្នុងរវាងឆ្នាំទាំងហ្នឹង ជននោះគឺថា រួមជាមួយ*ក្រាស្និក និងខារាផិក* ហើយនៅ ក្នុងរឿងក្តី *ត្រយកា* នៅក្នុង*បូស្នៀហើហ្សេកូវីណា* ជារឿងក្តីធំមួយ។ គេត្រូវបានអនុញ្ញាត ត្រូវបានចាប់ខ្លួននៅ *ប៊ែលគ្រេដ* នៅក្នុងពេលមួយដែល *ស៊ើប៊ី* មិនសហការជាមួយតុលាការ អាយ.ស៊ី.ធី.វ៉ាយ។ ប៉ុន្តែផ្ទុយទៅវិញគេអនុញ្ញាតឲ្យជននោះស្ថិតនៅក្នុងការឃុំខ្លួនក្នុងផ្ទះ។ នៅក្នុងរឿងក្តីនោះ រង់ចាំការសម្រេចបានសារភាពពីពិរុទ្ធភាព ហើយនិងធ្វើការកាត់ទោស។ ហើយប៉ុន្តែគាត់បាននៅខាងក្រៅ ហើយនៅក្រៅឃុំ ប៉ុន្តែគេសារភាពថា ពិរុទ្ធភាព ហើយក៏បញ្ជូនទៅ*ប៊ែលគ្រេដ* ឲ្យស្ថិតនៅក្នុងការឃុំខ្លួនក្នុងផ្ទះ។ ប៉ុន្តែ ខ្ញុំសូមជម្រាបអង្គបុរេជំនុំជម្រះថា ការឃុំខ្លួនក្នុងផ្ទះមិនមែនជាការនៅក្រៅឃុំបណ្តោះអាសន្នទេ វាជាការឃុំខ្លួនមួយគឺថាវាមានចែងនៅក្នុងច្បាប់នៅចំពោះមុខអង្គជំនុំជម្រះវិសាមញ្ញ។ កាលណាវាឆ្លើយតបទៅនឹងលក្ខខណ្ឌដែលសហព្រះរាជអាជ្ញាបានបញ្ជាក់ថា សាលាក្តីចំពោះកិច្ចរបស់អន្តរជាតិគឺថាអាចនឹងមិនមែនលក្ខណៈជាក់លាក់ទៅនឹងនីតិវិធីព្រហ្មទណ្ឌរបស់កម្ពុជា។ គេបានបញ្ជាក់ថា ដោយការវិភាគគឺថាយើង

អាចប្រើបែបនោះ។ ប៉ុន្តែ ការអះអាង ក៏ប៉ុន្តែមិនមានលក្ខណៈជាក់លាក់ទេ ប៉ុន្តែត្រូវបានហាមឃាត់ទៅវិញ។ ប៉ុន្តែ ប្រសិនបើអង្គបុរេជំនុំជម្រះយល់ឃើញថាសមស្របក៏ខ្លួនអាចសម្រេចចេញឱ្យនៅឃុំខ្លួនក្នុងផ្ទះ។ ប៉ុន្តែ នេះជាឆន្ទានុសិទ្ធិរបស់អង្គបុរេជំនុំជម្រះ។ ប៉ុន្តែ ខ្ញុំសូមជម្រាបជូនមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណីដែលបានលើកឡើងអំពីរឿងឃាតកម្ម ហើយការវិភាគរបស់ខ្ញុំទាក់ទងទៅនឹងអ្វីដែលបានកើតឡើងបញ្ហានៅព្រំដែន ជម្លោះរវាងកម្ពុជានិងថៃឡង់នោះ។ ចំណុចដែលខ្ញុំចង់បញ្ជាក់នេះគឺដូចខាងក្រោមនេះ៖

នេះជាតុលាការជាតិ។ អ.វ.ត.ក មិនមានកម្លាំងនគរបាលខ្លួនឯងទេ គឺពឹងផ្អែកទៅលើកម្លាំងនគរបាលជាតិគឺក្រសួងមហាផ្ទៃនៃរាជរដ្ឋាភិបាលកម្ពុជាដើម្បីផ្តល់នូវកងកម្លាំងដើម្បីផ្តល់សុវត្ថិភាពជារៀងរាល់ថ្ងៃរបស់យើង ជាពិសេសចំពោះជនត្រូវចោទផងដែរ គឺរដ្ឋាភិបាលខ្លួនឯង។ អ្វីដែលខ្ញុំចង់ជម្រាបនោះគឺជាពិសេសខ្ញុំចង់បញ្ជាក់ឱ្យបានច្បាស់ថា គឺជាហេតុការណ៍ដែលថារដ្ឋាភិបាលពិតជា មានសមត្ថភាពតាមរយៈក្រសួងមួយចំនួនរបស់ខ្លួនដើម្បីផ្តល់នូវការការពារដ៏ចាំបាច់ ប្រសិនបើអង្គបុរេជំនុំជម្រះពិនិត្យពិចារណាឃើញថា ការឃុំខ្លួននៅក្នុងផ្ទះនោះគឺជាកត្តាសមស្របនោះ នេះចំណុចដែលខ្ញុំបានព្យាយាមជម្រាបជូន។

សម្បទាដើម្បីប្រឈមនឹងការជំនុំជម្រះ ខ្ញុំនឹងព្យាយាមបញ្ជាក់អំពីបញ្ហាសតិបញ្ញារបស់ជនត្រូវចោទ។ ហើយខ្ញុំមិននិយាយអំពីកត្តាសុខភាពខាងរាងកាយ ប៉ុន្តែរបាយការណ៍ដែលរៀបរៀងឡើងដោយអ្នកជំនាញទាក់ទងទៅនឹងកូនក្តីរបស់ខ្ញុំអំពីលទ្ធភាពរបស់គាត់ក្នុងការតាមដាននីតិវិធីដូចដែលបានបញ្ជាក់។ ខ្ញុំនឹងសូមជម្រាបដោយសង្ខេបអំពីបញ្ហានេះ។ ជាបឋម វេជ្ជបណ្ឌិតបានណែនាំដោយ សហព្រះរាជអាជ្ញាមិនបានពិគ្រោះយោបល់ជាមួយមេធាវីការពារទេ ប៉ុន្តែគេមិនបានផ្តល់ឱកាសឱ្យមេធាវីការពារសង្កេត ហើយនិងការពិនិត្យសុខភាពទាំងអស់នោះទេ។ ប៉ុន្តែ មិន មានការពិនិត្យសុខភាពដូចនិយាយទេ គឺគ្រាន់តែគេបានម្តងមកម្តងពីរដង គឺថាមកសួរថា សុខសប្បាយទេ? តើស្គាល់មេធាវីទេ? នោះគឺជាទំហំនៃការជួបមិនមែនជាការវិភាគសុខភាពនោះទេ។ ប៉ុន្តែ របាយការណ៍នោះគឺថាមិនមានភ័ស្តុតាង មិនមានមូលដ្ឋានគ្រប់គ្រាន់ មិនមែនជាភ័ស្តុតាងចិត្តសាស្ត្របញ្ជាក់ពី ភាពសម្បទារបស់ជនត្រូវចោទនោះទេ កូនក្តីរបស់ខ្ញុំទេ។ អ៊ីចឹងគឺថា ព័ត៌មានដែលទាក់ទងដែលយើងឮពីសហចៅក្រមស៊ើបអង្កេតនោះដែលទាក់ទងទៅនឹងការពិនិត្យឱ្យលម្អិតទៅលើរឿងនេះ បញ្ហានេះ។

ទាក់ទងទៅនឹងរឿងការលម្អៀង អនាគតិ សហព្រះរាជអាជ្ញានោះបានកែតម្រូវបញ្ហាមួយដែល

លើកឡើងដោយអង្គបុរេជំនុំជម្រះនោះគឺជាចំណុចមួយហើយខ្ញុំបានដឹងយ៉ាងច្បាស់ថា គឺថាដោយត្រឹមត្រូវ គឺថានិយាយដោយត្រង់ៗជូនអង្គបុរេជំនុំជម្រះ។ ខ្ញុំមានការខកចិត្តខ្លាំងណាស់ពីអង្គហេតុថា ដែលយើងមិនបានទទួលនូវឱកាសដើម្បីនឹងពិនិត្យមើលនូវភស្តុតាង ហើយប្រមូលភស្តុតាង។ វាដូចជា ស៊ុតនិងមាន់អីចឹង។ យើងមានអ្នកវិភាគដ៏ជំនាញម្នាក់ពីសហចៅក្រមស៊ើបអង្កេតដែលថាថ្ងៃមួយគាត់ជាអ្នកធ្វើវិភាគដែលធ្វើការចោទប្រកាន់យ៉ាងធ្ងន់ធ្ងរដោយផ្អែកលើចំណេះដឹងផ្ទៃក្នុង ប៉ុន្តែយើងមិនមានអ្វីលើសពីហ្នឹងទេ។ យើងត្រូវការអ្នកទាំងនោះដើម្បីមកបង្ហាញខ្លួន ដើម្បីបង្ហាញភស្តុតាង ប៉ុន្តែអ្នកទាំងអស់នោះមិននិយាយជាមួយយើងសោះ ហើយគេមិនអាចមកទីនេះនៅពេលដែលឲ្យគេនិយាយជាក្នុងនាមសម្បថនោះ ប៉ុន្តែមិនមានឱកាសធ្វើបែបនោះបាន។ អ្វីដែលយើងចង់លើកឡើងនោះគឺអ្វីដែលយើងបានរកឃើញស្នើសុំឲ្យរកព័ត៌មានផ្សេងទៀតនោះយើងមិនបានជោគជ័យ ប៉ុន្តែទាក់ទងនឹងការលម្អៀងវិញ គឺថាយើងជឿជាក់ថាកាលៈទេសៈមួយចំនួននោះ វាមានការកែប្រែតាមដែលយើងគិតសហចៅក្រមស៊ើបអង្កេតមិនបានចាត់វិធានការជាស្ថានឯករាជ្យក្នុងការស៊ើបអង្កេតនោះទេ ដូចដែលយើងពិនិត្យមើលទៅ ដើម្បីព្យាយាមស្វែងរកនូវភស្តុតាងឲ្យបានស្មើភាពគ្នា ចំពោះមេធាវីការពារ ហើយនិងចំពោះសហព្រះរាជអាជ្ញាដូចទាក់ទងអំពីកត្តាប្រជាសាស្ត្រ ដែលត្រូវចាត់តាំងអ្នកវិទ្យាសាស្ត្រឲ្យចូលរួមក្នុងការជ្រើសរើស តើយើងត្រូវពិនិត្យអ្វី? គេបានទៅជួបការិយាល័យព្រះរាជអាជ្ញានៅទីក្រុងឡាអេ ដែលអតីតសហសេវិកនោះ គឺថាគេបានមកធ្វើការនៅសាលាក្តីនេះយើងដែរ។ យើងបានស្នើសុំឲ្យអ្នកប្រជាសាស្ត្រផ្សេងទៀតមកធ្វើការវាយតំលៃ ប៉ុន្តែយើងមិនបានទទួលការឯកភាពទេ ប៉ុន្តែប្រសិនបើគេមានឯករាជ្យ ប៉ុន្តែមិនមានលម្អៀង ហេតុអ្វីបានយើងមិនស្នើតាម មិនឆ្លើយតបនឹងសំណូមពររបស់យើង តែតែងគោរពតាមសហព្រះរាជអាជ្ញាជារៀងរហូតមក។

ដូច្នេះតាមការទំនាក់ទំនង គឺថាវាលើសពីទំនាក់ទំនងនោះទេ គឺដូចជាលោក គ្រេក អេតធេសាន់ គាត់ធ្វើការឲ្យ អូ.ស៊ី.ភី ឲ្យសហព្រះរាជអាជ្ញាហើយគាត់និយាយអំពីសមាជិកនៃសហចៅក្រមស៊ើបអង្កេតដើម្បីរកភស្តុតាងដាក់បន្ទុកឲ្យបានច្រើន ហើយយើងបានព័ត៌មានអំពីការវិភាគដែលបានធ្វើការឲ្យសហចៅក្រមស៊ើបអង្កេត តើយើងទទួលព័ត៌មានបានអ្វី? បើសិនជាមិនកោះគាត់អញ្ជើញមកនិយាយនៅក្នុងក្រចកសេះនោះទេ។

**ចៅក្រម ខាទីនខា ឡាហ្វ៊ូស៖**

ប្រហែលជាលោកមេធាវីការពារអាចនឹងសង្ខេប ពីព្រោះសហព្រះរាជអាជ្ញាលោកក៏នឹងត្រូវលើក

ឆ្លើយតបដែរ។

**លោក អានីស អះមេដ៖**

ខ្ញុំមិនសូមអន្តរាគមន៍ទៅនឹងមតិដែលលើកឡើងដោយលោក កាណាវាស នោះទេ។ ដោយគំនិតនេះ គាត់ដូចជាពិនិត្យឡើងវិញ លើកឡើងវិញនូវពាក្យសុំទាំងអស់ដែរថាកំពុងតែស្ថិតនៅរង់ចាំការសម្រេច ប៉ុន្តែលោក កាណាវាស គឺថាចង់ដាក់បញ្ចូលមកទាំងអស់នៅពេលនេះ ប៉ុន្តែវាខុសពីប្រធានដែលយើងនិយាយពីថ្ងៃនេះ គឺថាសេចក្តីសន្និដ្ឋាននោះវាត្រូវធ្វើនៅក្នុងរឿងផ្សេង ថាតើយើងត្រូវបញ្ចូលទទ្បីករណ៍ទាំងអស់នោះ បញ្ចូលមកនៅពេលនេះ ឬក៏ត្រូវបើកសវនាការឡើងវិញក្នុងករណីទាំងអស់ឬយ៉ាងម៉េច?

[១៥:០៣:០១]

លោក ក្រេក អេតឆេសាន់ គឺថាកំពុងរង់ចាំការសម្រេចក្នុងនីតិវិធីដាច់ដោយឡែក។ ពាក្យសុំឡឹម៉ុងដ៍ ក៏នៅក្នុងរឿងដោយឡែកដែរ។ ប៉ុន្តែ អង្គបុរេជំនុំជម្រះត្រូវសម្រេចថាតើឲ្យគាត់លើកទទ្បី-ករណ៍ទាំងអស់នេះ នៅពេលនេះ ឬក៏ឲ្យនិយាយតែទៅរឿងឧទ្ធរណ៍នៅក្នុងរឿងក្តីនេះ?

**ចៅក្រម ខាទីនខា ឡាហ៊្វស៖**

លោក កាណាវាស យើងសូមជម្រាបលោកថា លោកអាចកត់សម្គាល់ថា ខ្ញុំដូចជាមានអារម្មណ៍សង្កេតឃើញថាមិនមានសភាពការណ៍មិនល្អ។ ដូចខ្ញុំហើយ សហព្រះរាជអាជ្ញានឹងមានមតិ។

**លោក ម៉ៃខល កាណាវាស៖**

ខ្ញុំនឹងព្យាយាមឆ្លើយតបទោះបី-- ឆ្លើយតបនៅក្នុង(ឮមិនច្បាស់) ប៉ុន្តែវាការឆ្លើយដែលចំណុចនោះ យើងជឿជាក់ថាវាមានការលម្អៀងនៅក្នុងការិយាល័យសហចៅក្រមស៊ើបអង្កេតហ្នឹង គឺថាហ្នឹងហើយគឺជាកែប្រែកាលៈទេសៈ ដែរថាហេតុការណ៍មួយចំនួនដែលកើតឡើងក្នុងពីរបីខែចុងក្រោយ ពេលដែលយើងពិនិត្យមើលឃើញថា នៅពេលដែលយើងធ្វើការនៅក្នុងការវាយតម្លៃ តើមានលក្ខខណ្ឌជាក់លាក់បានកែប្រែដែរឬទេ? យើងមិនបានឃើញច្រើនទេអំពីអ្វីដែលស្ថិតនៅក្នុងសមត្ថកិច្ចរបស់សហចៅក្រមស៊ើបអង្កេត បើយើងនិយាយអំពីភ័ស្តុតាងដោះបន្ទុកវិញ។

**ចៅក្រម ខាទីនខា ឡាហ៊្វស៖**

លោក កាណាវាស អ្វីដែលលោកលើកឡើងនេះ ដូចជាលោកបានបន្តនិយាយអំពីសេចក្តីដែល

បានសម្រេចរួចហើយដោយអង្គបុរេជំនុំជម្រះ និងឬ ឬក៏តាមសមត្ថកិច្ចដែលកំពុងរង់ចាំ។ ហើយដូច្នេះ យើងមានពេលវេលាដែលលោកត្រូវគោរពនោះផងដែរ។

**លោក ម៉ៃខល កាណាវាស៖**

ប៉ុន្តែ ខ្ញុំគួរតែនិយាយថា នៅពេលដែលសហព្រះរាជអាជ្ញាលើកសេចក្តីសន្និដ្ឋានរបស់គាត់ គឺគាត់បានលើកឡើងអំពីសំណើបំពេញកិច្ចស៊ើបសួរ ទាក់ទងនឹងគំរូនៃការស៊ើបសួរ ប្រហែលគាត់ជាការលើកឡើងចំពោះខ្ញុំ ដូច្នេះគឺខ្ញុំធ្វើការឆ្លើយតបនៅពេលនេះ។ ខ្ញុំសូមបន្តទៅទៀត ចំពោះបញ្ហាដែលលើកឡើងដោយតំណាងដើមបណ្តឹងរដ្ឋប្បវេណី ខ្ញុំមានការព្រួយបារម្ភ ដោយសារតែមេធាវីបានលើកឡើងថាគាត់យល់អំពីសិទ្ធិជាមូលដ្ឋាន ប៉ុន្តែទឡ្ហីករណ៍របស់គាត់ គឺហាក់ដូចជាសន្និដ្ឋានអំពីពិរុទ្ធភាពជាមុនរួចទៅហើយ ថាកូនក្តីរបស់ខ្ញុំមានពិរុទ្ធភាព យើងបានស្តាប់ឮ។ ខ្ញុំមិនដឹងថា គាត់ធ្វើសេចក្តីសន្និដ្ឋានបញ្ចប់ ឬក៏យ៉ាងណានោះទេ? ពីមេធាវីការតំណាង ដែលលើកឡើងពីលើកទីពីរនោះ។ ហើយវាហាក់ដូចជាបង្ហាញថា ជនត្រូវចោទគាត់មានពិរុទ្ធភាព ហើយគាត់មិនទទួលបានសិទ្ធិសច្ចធារណ៍និរទោសនោះទេ។

[១៥:០៦:០៦]

នៅពេលដែលយើងមើលទៅលើជំហារ ឬស្ថានភាពនេះ វាមានភាពខុសគ្នា។ ខ្ញុំសូមលើកឡើងអំពីរឿងក្តី មីឡូសីវិច នៅ អាយ.ស៊ី.ធី.វ៉ាយ ដែលវាមានការជំនុំជម្រះរយៈពេលបីឆ្នាំនៅមុខចៅក្រមប៉ែលឡាមី ហើយគាត់គឺជាបុគ្គលម្នាក់ ដែលត្រូវបានគេជំនុំជម្រះ ហើយការិយាល័យអយ្យការនៅទីក្រុងឡាអេ គឺមិនបានធ្វើការប្តឹងនោះទេ ប្តឹងឧទ្ធរណ៍នោះទេ។ ខ្ញុំលើកឡើងទៅលើចំណុចនេះ ដោយសារតែវាទាក់ទងសច្ចធារណ៍និរទោស មិនមែនអ្វីដែលយើងចេះតែនិយាយនេះទេ។ យើងមានន័យរបស់យើង។ យើងត្រូវតែលើកឡើង ប៉ុន្តែយ៉ាងណាក៏ដោយ មិនមែនថាជនត្រូវចោទនៅពេលដែលគាត់មកទីនេះ គាត់មានពិរុទ្ធភាពនោះទេ។ ដូច្នេះ ខ្ញុំគិតថាការលើកឡើងរបស់មេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី ហាក់ដូចជាលើកជ្រុលពេក។ យើងលើកឡើងនៅក្នុងសេចក្តីសន្និដ្ឋានរបស់យើង យើងជឿថាកាលៈទេសៈបានផ្លាស់ប្តូរ ដូច្នេះក្រុមប្រឹក្សាជំនុំជម្រះមានសមត្ថភាពក្នុងការពិចារណា ហើយអាចផ្តល់វិធានការមួយផ្សេង ដែលវាអាចមាននៅពេលនេះ ដើម្បីធ្វើយ៉ាងឲ្យលោក អៀង សារី មានវត្តមាននៅក្នុងសវនាការ ហើយនិងសុវត្ថិភាពរបស់គាត់ រួមទាំងសុវត្ថិភាពរបស់អ្នកដទៃ។ ការស៊ើបអង្កេតបានធ្វើការបន្តយូរ ជាងអ្វីដែលយើងរំពឹងទុក ហើយការជំនុំជម្រះនឹងធ្វើការចាប់ផ្តើមប្រហែលជាមួយឆ្នាំទៀត-- មួយឆ្នាំក្រោយពីពេលនេះទៅ។ ដូច្នេះហើយ យើងក៏មិនចង់ឲ្យមានជនត្រូវចោទ ឬក៏ជនជាប់

ចោទ គាត់ធ្វើដំណើរមកនិយាយអំពីការជំនុំជម្រះ ឬក៏ការឃុំខ្លួននោះផងដែរ។ ប៉ុន្តែ យ៉ាងណាក៏ដោយ គឺខ្ញុំសូមទាមទារ និងលើកឡើងថាយល់ស្របជាមួយនឹងមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី ប៉ុន្តែគាត់នៅពេលដែលគាត់នៅក្នុងទីក្រុងភ្នំពេញក៏ដោយ គឺគាត់នៅតែមានលក្ខណៈងាយស្រួល ហើយវានៅតែជិតតុលាការដដែល ហើយវាមិនមានបញ្ហាទាក់ទងទៅនឹងបញ្ហាចរាចរ ឬបុគ្គលណានោះឡើយ។

សូមអរគុណលោក លោកស្រីចៅក្រម ចំពោះការយកចិត្តទុកដាក់របស់លោក លោកស្រីចៅក្រម។

**ចៅក្រម ខាទីនខា ឡាហ៊ួស៖**

លោកសហមេធាវីជាតិ យើងខ្ញុំសូមសួរថា តើកូនក្តីរបស់លោកចង់ត្រឡប់មកវិញនៅពេលនេះ ដើម្បីធ្វើសេចក្តីសន្និដ្ឋានពាក្យសម្តីចុងក្រោយ ឬក៏យ៉ាងម៉េច? ដោយសារគាត់មានសិទ្ធិនុំង។ ប៉ុន្តែយ៉ាងណាក៏ដោយ លោកមេធាវីអាចបញ្ជាក់ថាគាត់បោះបង់សិទ្ធិ ដើម្បីឲ្យយើងយល់ឲ្យបានច្បាស់។ សូមអរគុណ។

**លោក អាង ឧត្តម៖**

ខ្ញុំបានទទួលពាក្យ ហើយក៏ទទួលខុសត្រូវថាគាត់មិនចាំបាច់ឡើងមកស្តាប់ការបិទសវនាការនេះទេទាន។ លោក អៀង សារី មិនចាំបាច់ឡើងមកស្តាប់ការបិទសវនាការនៅពេលនេះទេ។

**ប្រធានអង្គបុរេ៖**

អង្គបុរេជំនុំជម្រះសូមប្រកាសជម្រាបជូនសាធារណជនថា សាលដីកាស្តីពីបណ្តឹងឧទ្ធរណ៍ដែលយើងបើកសវនាការនៅថ្ងៃនេះ អង្គបុរេជំនុំជម្រះនឹងប្រកាសជូនដំណឹងពីរថ្ងៃមុន ប្រកាសសាលដីកា។ ដូច្នេះ សវនាការនៅថ្ងៃនេះគឺសន្មតចប់តែប៉ុណ្ណេះ។ ប្រកាសបិទសវនាការ៕

**លោក ឈន ព្រលឹង៖**

សូមអញ្ជើញក្រោកឈរ!

*[សវនាការសម្រាកនៅម៉ោង១៥:១០នាទី]*